00837168

E1/108.1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 16-Aug-2012, 14:48
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១២**

**ម៉ោង ០៩:០២ នាទី**

**សវនាការលើកទី៩៦**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ឌុច ផារី

លោក ម៉ាតេអូ គ្រីប៉ា
*(Mr.Matteo CRIPPA)*

លោក រ៉ូជ័រ ហ្វីលីព *(Mr.Roger PHILLIP)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ច័ន្ទ តារាស្មី

លោក វ៉េង ហ៊ត់

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

លោក ថារីក អាប់ឌុលឡាក់
*(Mr. Tarik ABDULHAK)*

លោក ឌេល លីសាក់ (*Mr. Dale LYSAK*)

លោក រេយ៍ន័រ កែត
*(Mr. RAYNOR Keith)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ហ្សាស្ពើ ប៉ៅ*(Mr Jasper PAUW)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសេ
*(Ms. Anta GUISSÉ)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវាស
*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត
*(Ms. Elisabeth SIMONNEAU-FORT)*

លោក ឡូ ជុនធី

លោកស្រី ស៊ីន សុវ៉ន

លោកស្រី បេនី យេ *(Ms. Beini YE)*

លោក ហ្វេឌីណង់ ចាមិន ហ្សេប៉ា
*(Mr. Ferdinand DJAMMEN NZEPA)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក ហ្សាស្តេី ប៉ៅ | អង់គ្លេស |
| លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល | បារាំង |
| លោក ច័ន្ទ តាវារស្មី | ខ្មែរ |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| លោក វ៉េង ហ៊ត់ | ខ្មែរ |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |
| លោក ស្នួង ស៊ីគឿន (TCW-694) | ខ្មែរ |
| លោកស្រី ស សៀក (TCW-609) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក សួង ស៊ីគឿន ហៅ គង់ ឬ ធន** (TCW-694)

សួរបន្តដោយលោក លោក ហ្សាស្តេី ប៉ៅ ផ្តើមពី៖ ........................................................ទំព័រ ៣

សួរដោយលោក ម៉ែខល កាណាវាស ផ្តើមពី៖ ............................................................ទំព័រ ៣៩

**ការសួរសំណួរទៅសាក្សី៖ លោក ស សៀក** (TCW-609)

សួរដោយលោក ប្រធានអង្គជំនុំ ផ្តើមពី៖ ....................................................................ទំព័រ ៥៤

សួរដោយលោក វ៉េង ហ៊ត់ ផ្តើមពី៖ ..........................................................................ទំព័រ ៥៨

សួរដោយលោក ថារីក អាប់ឌុលឡាក់ ផ្តើមពី៖..............................................................ទំព័រ ៦៨

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០២:០៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយនៅព្រឹកនេះ ដូចកាលវិភាគដែលបានកំណត់កាលពីម្សិលមិញ គឺនឹងបន្តការតាំងសំណួរដេញដោលចំពោះសាក្សី សួង ស៊ីគឿន ដោយមេធាវីការពារក្ដីលោក នួន ជា។ ហើយមុននឹងផ្ដល់វេទិកាជូនទៅមេធាវីការពារក្ដី សូមអញ្ជើញលោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះអញ្ជើញ ឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន គ្រប់ភាគីទាំងអស់នៅក្នុងរឿងក្ដីនេះមានវត្តមាន លើកលែងតែជនជាប់ចោទ អៀង សារី មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមបន្ទប់សវនាការ ដោយជនជាប់ចោទបានស្នើសុំលះបង់សិទ្ធិតាមរយៈមេធាវីរបស់គាត់ ក្នុងការចូលរួមដំណើរការនីតិវិធីដោយផ្ទាល់ពីបន្ទប់សវនាការសម្រាប់រយៈពេលពេញមួយថ្ងៃនៃថ្ងៃសវនាការនេះ។ លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទបានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ ដោយឡែក សាក្សីបម្រុងសម្រាប់សវនាការនៅថ្ងៃនេះ គឺសាក្សីដែលមានរហស្សនាម TCW-609 សាក្សីរូបនេះមានវត្តមាននៅបន្ទប់រង់ចាំ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។ សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងបីរូប ឬភាគីដើមបណ្ដឹងរដ្ឋប្បវេណី ដែលបានទទួលស្គាល់ណាមួយនោះទេ។ សាក្សីបានធ្វើសម្បថរួចហើយនៅចំពោះមុខលោកតាដំបងដែក កាលពីថ្ងៃទី ១៤ ខែសីហា ឆ្នាំ២០១២ នេះ។ សូមអរគុណ។

[០៩:០៤:២៥]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ អៀង សារី។ អង្គជំនុំជម្រះបានទទួលពាក្យសុំរបស់ជនជាប់ចោទ អៀង សារី ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១២ តាមរយៈមេធាវីការពារក្ដី

របស់គាត់ សុំលះបង់សិទ្ធិចូលរួមក្នុងសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ ដោយសុំនៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមប្រព័ន្ធសោតទស្សន៍ សម្រាប់រយៈពេលដំណើរការសវនាការពេញមួយថ្ងៃនេះ។ លោកវេជ្ជបណ្ឌិត សួស សែម គ្រូពេទ្យទទួលពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅមន្ទីរឃុំឃាំង នៃ អ.វ.ត.ក បានពិនិត្យសុខភាពលោក អៀង សារី នៅព្រឹកនេះកត់សម្គាល់ឃើញថា លោក អៀង សារី មានអាការៈហត់ពិបាកទ្រាំនៅពេលធ្វើចលនាបន្តិចបន្តួច ឈឺចង្កេះពេលអង្គុយយូរ និងបានផ្តល់អនុសាសន៍ថា អង្គជំនុំជម្រះគួរអនុញ្ញាតឲ្យគាត់ នៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ខាងក្រោម។

[០៩:០៥:១៩]

អង្គជំនុំជម្រះយល់ឃើញថា នៅពេលនេះលោក អៀង សារី ដែលបានលះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការ។ គាត់មានបញ្ហាសុខភាពដូចគ្រូពេទ្យបានកត់សម្គាល់ តែរូបកាយនិងស្មារតីសមស្របអាចចូលរួមនិងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ ហើយក៏អាចសម្រួលដល់ទំនាក់ទំនងរវាងគាត់ ជាមួយនឹងក្រុមមេធាវីការពារក្តីរបស់គាត់បានដែរ។

អង្គជំនុំជម្រះសម្រេចយល់ព្រម តាមសំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលស្នើសុំលះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះឲ្យលោក អៀង សារី នៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ សម្រាប់រយៈពេលធ្វើសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ អៀង សារី អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ សម្រាប់រយៈពេលធ្វើសវនាការពេញមួយថ្ងៃនេះ។

បាទ ជាបន្ត អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី លោក នួន ជា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី ហើយអង្គជំនុំជម្រះរំឭកដល់ក្រុមមេធាវីថា គប្បីរៀបចំនូវសំណួរដេញដោលឲ្យបានសមស្រប គឺឲ្យមានភាពពាក់ព័ន្ធទៅនឹងអង្គហេតុនៃការចោទប្រកាន់ គឺក្នុងគោលបំណងស្វែងរកការពិតនៃរឿងក្តី ដើម្បីបញ្ជាក់ពីអត្ថិភាពនៃពិរុទ្ធភាព ឬអនត្ថភាពនៃពិរុទ្ធភាពនៅក្នុងរឿងក្តីនេះ ឬក៏បញ្ជាក់អំពីស្ថាននានា ដែលពាក់ព័ន្ធនឹងកិច្ចដំណើរការ ដែលមានប្រយោជន៍ដល់អង្គជំនុំជម្រះយកទៅពិចារណាសម្រេចសេចក្តីនៅពេលក្រោយ នៅពេលដែលចប់កិច្ចពិភាក្សាដេញដោល។

សូមអញ្ជើញ!

[០៩:០៧:១៤]

**លោក ហ្សាស្តេី ប៉ោ៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោក លោកស្រីចៅក្រម ហើយនិងភាគីទាំងអស់ និងសាធារណជន ហើយជម្រាបសួរលោក សួង ស៊ីគឿន ផងដែរ។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរបន្តដោយលោក ហ្សាស្តេី ប៉ោ៖**

**ស៖** កាលពីម្សិលមិញនេះ យើងបានពិភាក្សា អំពីប្រវត្តិនៃរណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ហើយនិងនិយាយពីទូរលេខ ដែលស្ថានទូតអាមេរិកបានបញ្ជូនទៅ ដែលបញ្ជាក់អំពីមនុស្សមួយចំនួនដែលពាក់ព័ន្ធនៅក្នុងរណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ដែលមានឈ្មោះលោក ហើយនិងមានឈ្មោះមនុស្សមួយចំនួនទៀត ដែលថាមានលោក គាត ឈន់ ថាគាត់គឺជាលេខាធិការនៃការិយាល័យនយោបាយរបស់រណសិរ្សរួបរួមជាតិកម្ពុជា។ យើងបាននិយាយបន្តិចដែរ អំពីការិយាល័យនយោបាយនោះកាលពីម្សិលមិញ។ លោកក៏បាននិយាយអំពីការិយា-ល័យនយោបាយនេះដែរ កាលពីមុន ជាពិសេសនៅថ្ងៃទី៨ ខែសីហា នៅតុលាការនេះនៅទំព័រ៣៤ នៃប្រតិចារឹកអង់គ្លេសទំព័រ៨ ដល់១២ ប្រតិចារឹកភាសាខ្មែរទំព័រ២៨ បន្ទាត់ទី២ ដល់ទី៨ លោកនិយាយថា "នៅក្នុងរណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ជាអង្គការនយោបាយមួយដែលមានគណៈអចិន្ត្រៃយ៍ គណៈមជ្ឈិម គឺជាការិយាល័យនយោបាយរបស់គណៈមជ្ឈិម ដែលមានសម្តេច ប៉ែន នុត គឺជាប្រធាននៃគណៈកម្មាធិការនេះ"។ នេះគឺជាចម្លើយរបស់លោក នៅថ្ងៃទី៨ ខែសីហា។ សំណួររបស់ខ្ញុំជូនទៅលោកនោះគឺថា តើនេះគឺជាការិយាល័យនយោបាយដដែល ដែលលោក គាត ឈន់ ក៏នៅក្នុងនោះដែរ នៅឆ្នាំ១៩៧១ នោះបាទ?

**លោក សួង ស៊ីគឿន៖**

**ឆ៖** បាទ លោក គាត ឈន់ ជាសមាជិកបម្រុង សមាជិកត្រៀម នៃការិយាល័យនយោបាយនៃរណសិរ្សរួបរួមជាតិកម្ពុជានៅពេលនោះដែរបាទ។

**ស៖** សូមអរគុណ។ សំណួរចុងក្រោយទាក់ទងនឹងប្រធានបទនេះ ទាក់ទងនឹងទូរលេខនេះ។ លោកនៅចាំថា ម្សិលមិញ ខ្ញុំបានអានជូននៅទំព័រទី១ នៃទូរលេខនេះ។ ទូរលេខនេះបាននិយាយថា

"មនុស្សមួយចំនួន ដែលដាក់សញ្ញាផ្កាយ គឺជាមនុស្សដែលត្រូវបានណែនាំដោយសម្តេច សីហនុ ដើម្បីឲ្យបង្កើតរដ្ឋាភិបាលកម្ពុជា នៅឆ្នាំ១៩៦០ ហើយអ្នកទាំងអស់នោះ គឺជាមនុស្សឆ្វេងនិយមជ្រុល ហើយនិងជាមនុស្សដែលចូលរួមចលនានោះ ហើយលោក គាត ឈន់ គាត់មានសញ្ញាផ្កាយនៅឈ្មោះគាត់ដែរ។ សំណួររបស់ខ្ញុំជូនលោកគឺថា តើលោក គាត ឈន់ ជាមនុស្សម្នាក់ក្នុងចំណោម ៣៤នាក់ ដែលព្រះអង្គបានចាត់តាំងឲ្យបង្កើតរដ្ឋាភិបាលតាំងពីឆ្នាំ៦០ហ្នឹងមកដែរឬទេ?

[០៩:១០:៤១]

**ឆ៖** ខ្ញុំមិនបានដឹងទេបាទ ព្រោះពេលនោះ ខ្ញុំនៅកំពុងសិក្សានៅប្រទេសបារាំង។

**ស៖** សូមអរគុណ។ ឥឡូវនេះ ខ្ញុំនឹងចូលទៅប្រធានបទថ្មីមួយទៀត ដែលថានៅពេលក្រោយគឺរយៈទាក់ទងទៅនឹងការជម្លៀសទីក្រុងភ្នំពេញ លោកបាននិយាយហើយថា នៅខែឧសភា ឆ្នាំ១៩៧៥ លោកបានមកភ្នំពេញ បន្ទាប់ពីមានការជម្លៀសភ្នំពេញរួចហើយ។ នៅពេលដែលមកដល់ទីក្រុង តើលោកនៅចាំដែរឬទេ ថាតើទីក្រុងនោះស្ងប់ស្ងាត់ ឬក៏មានការវាយប្រហារចំកន្លែងណាដាច់ដោយឡែកនៅកន្លែងណាដែរឬទេ ពេលលោកមកដល់នោះ?

**ឆ៖** ពេលថ្ងៃដែលខ្ញុំមកដល់ទីក្រុងភ្នំពេញ គឺនៅថ្ងៃ២៥ ខែឧសភា ឆ្នាំ១៩៧៥ ខ្ញុំឃើញភ្នំពេញហ្នឹងមាន -- មិនមានប្រជាជនអីកុះករដូចធម្មតាទេ គឺមានសភាពស្ងាត់ជ្រងំ មានតែនារីដឹកជញ្ជូនដែលគាត់ដឹក លី អង្ករចេញពីកប៉ាល់ ឡើងមកច្រាំងនៅកំពង់ផែទីក្រុងភ្នំពេញប៉ុណ្ណោះបាទ។

**ស៖** ខ្ញុំសូមអានសេចក្តីដកស្រង់ជូនលោកស្តាប់អំពីសៀវភៅអតីតប្រពន្ធរបស់លោក ឡូរ៉ង់ ពិចគាត់បានសរសេរសៀវភៅមួយគឺថា "ផ្កាយហួសពីជើងមេឃ"។ ខ្ញុំនឹងដកស្រង់សេចក្តីពាក់ព័ន្ធនៅលើអេក្រង់ ឯកសារ IS3.7 អង់គ្លេស ERN 00754756 ដល់ 78 -- អង់គ្លេសគឺ ERN -- ខ្មែរ ERN គឺ 00103479 រហូតដល់ 72 នៅខាងចុង។

**លោក ហ្សាស្តើ ប៉ោះ៖**

សូមអនុញ្ញាត គឺថាអត្ថបទភាសាខ្មែរនៅលើអេក្រង់ ហើយខ្ញុំមានអត្ថបទជាភាសាខ្មែរ និងបារាំងជាឯកសារលើក្រដាសជូនសាក្សីពិនិត្យផងដែរបាទ។

[០៩:១៣:២៥]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារក្រដាសពីលោកមេធាវីយកជូនសាក្សីពិនិត្យ!

**សួរដោយលោក ហ្សាស្តេី ប៉ោ៖**

**ស៖** លោកសាក្សីយើងឃើញសម្រង់ ខ្ញុំនឹងអានសេចក្តីដកស្រង់ ខ្ញុំអានជាភាសាអង់គ្លេស សូមដកស្រង់ទំព័រ៥៣ ភាសាអង់គ្លេស គឺថា ទំព័រភាសាបារាំង ៦០ បាទ។ ខ្មែរទំព័រនេះ ហើយចំណុចសំខាន់គឺថា "គឺបញ្ហាសន្តិសុខគឺនៅដដែល ការសម្លាប់គឺយុទ្ធជនគឺថាការចាប់ខ្លួនតែងតែធ្វើឡើង ហើយនិងនៅក្នុងតំបន់មួយចំនួន។ បន្ទាប់ពីការជម្លៀសភ្នំពេញ គេបានធ្វើផែកឆេរគ្រប់កៀនកោះនៃទីក្រុងភ្នំពេញដើម្បីស្វែងរកពួកអ្នកចចេសក្បាលរឹង។ ប៉ុន្មានអាទិត្យក្រោយមកនៃការរំដោះនោះ គេនៅរកឃើញពួកនេះពួននៅតាមចន្លោះ កន្លៀត ដែលពួកនេះបានលាក់ស្បៀងទុកនៅឡើយ។ អ្វីដែលឲ្យយុទ្ធជនសើចសប្បាយនោះ គឺប្រការដែលគេឃើញជនរួមជាតិមានសាច់ឡើងស ជាដើមនោះ"។

[០៩:១៤:៥០]

លោក សួង ស៊ីគឿង តើអ្វីនេះ ដែលខ្ញុំលើកនេះ ធ្វើឲ្យលោកនឹកឃើញឡើងវិញដែរឬទេ ដែលថាលោកមិនបាននៅទីក្រុងនៅពេលនោះ ដោយលោកមកដល់ទៅក្រុងថ្ងៃទី២៥ ឧសភា ឆ្នាំ៧៥ ប៉ុន្តែពេលដែលលោកអានស្តាប់ខ្លឹមសារនេះ តើលោកអាចនៅចាំទេ ដែលថា មានពួកយុទ្ធជនខ្លះអាចនឹងលាក់ខ្លួននៅក្នុងទីក្រុងភ្នំពេញនៅឡើយរបស់ភាគីម្ខាងទៀតនោះ?

**លោក សួង ស៊ីគឿន៖**

**ឆ៖** តាមខ្ញុំដឹង គឺពាក្យសម្តីទាំងនេះ គឺថាអតីតភរិយារបស់ខ្ញុំ គាត់បានឮពីការនិយាយតៗគ្នាពីយុទ្ធជន និងយុទ្ធនារី ដែលគាត់ប្រាស្រ័យទាក់ទងនៅពេលនោះបាទ។ ដែលខ្ញុំអាច -- ហើយសម្តីនេះគឺខ្ញុំក៏ធ្លាប់បានឮដែរ គឺថាចំណុចដែលនាំឲ្យបងប្អូន គឺថាដូចថា មិនថារីករាយទេ ថាបងប្អូន ដូចថា ផ្ទុះសំណើចហ្នឹង ដោយឃើញពួកនេះ មានពណ៌សម្បុរស ប៉ុន្តែនេះមិនមែនជាយុទ្ធជនទេ នេះគឺច្រើនតែមិនជាច្រើនទេ មានម្នាក់ពីរនាក់ គឺថាជាប្រជាជនបាទ។

[០៩:១៦:៣០]

**ស៖** សូមអរគុណលោកសាក្សី។ នេះជាចម្លើយច្បាស់លាស់ បន្ទាប់ទៅទៀត ខ្ញុំនឹងចូលបន្តិចទៅ ពេលខាងមុខបន្តិចទៀត ទាក់ទងទៅនឹងការបង្កើតមន្ទីរ ប-១ ក្រសួងការបរទេសនៅកាលនោះ។ លោកបាននិយាយថា លោកៗបានធ្វើការងារនោះជាមួយពួកបញ្ញវន្តមួយចំនួនមកពីសហភាពសូវៀត ហើយនិងលោក គាត ឈន់។ ហើយខ្ញុំចង់បង្ហាញជូនឯកសារមួយដល់លោក គឺសៀវភៅរបស់លោក

ដែលសរសេរ គឺនិយាយថា បញ្ញវន្តដែលចូលមកកម្ពុជាប្រជាធិបតេយ្យនោះ ហើយឯកសារ IS3.9 ហើយ E3.40។ អង់គ្លេស ERN 00813077, បារាំង ERN 007898689 (ស៊ីក), ហើយខ្មែរ ERN 00586040 រហូតទៅដល់ 636។

**លោក ហ្សាស្កើ ប៉ោះ**

ហើយខ្ញុំសុំអនុញ្ញាតបង្ហាញអេក្រង់ឯកសារខ្មែរទៅលើ -- នៅលើអេក្រង់ ហើយនិងជូនឯកសារលើក្រដាសជូនសាក្សីផងដែរ លោកប្រធាន បាទ។

[០៩:១៨:០៨]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីមេធាវី យកជូនសាក្សីពិនិត្យ!

**លោក ហ្សាស្កើ ប៉ោះ**

**ស៖** ដូចពីមុនដែរ ខ្ញុំនឹងអានសេចក្ដីដកស្រង់នៅក្នុងអង់គ្លេស ERN 00813084, ខ្មែរ ERN 00583613, បារាំង ERN 0008799 (ស៊ីក) ហើយខ្ញុំសូមដកស្រង់ "នៅពេលដែល អ៊ិន សុភាព ទៅធ្វើការនៅក្រសួងព័ត៌មាន ខ្ញុំនៅជាមួយលោក គាត ឈន់ និង កែវ បូរី វិស្វករមកពីក្រុងមូស្គូ ដើម្បីរៀបចំក្រសួងឡើងវិញ។ នៅក្នុងនោះ គឺថាយើងរស់នៅក្នុងផ្ទះផ្កាឈូក ជិតបរមរាជវាំង អស់រយៈពេលពេញមួយខែ ក្នុងឆ្នាំ១៩៧៥។ នេះ គឺជាភូមិគ្រឹះដ៏ស្រស់ស្អាត។ ជាកម្មសិទ្ធិរបស់ព្រះអង្គម្ចាស់ ស្រីពៅជាមហេសីមួយអង្គរបស់សម្តេច នរោត្តម សីហនុ។ នៅក្នុងរបបសាធារណរដ្ឋខ្មែរ ភូមិគ្រឹះនេះ ត្រូវបានជាការិយាល័យរបស់អនុពន្ធយោធានៃរាជាណាចក្រថៃ។ ពួកយើងទាំងបីនាក់ ខ្ញុំ, គាត ឈន់ និង បូរី ជាស្នូលនៃអ្វីដែលក្រោយមកក្លាយជាក្រសួងការបរទេស នៃកម្ពុជាប្រជាធិបតេយ្យ។ លោក អៀង សារី ដែលជាចៅហ្វាយនាយរបស់ពួកយើង បានមកសួរសុខទុក្ខពួកយើងម្តងម្កាល នៅដើមខែកញ្ញា។ លោក អៀង សារី បានប្រាប់ខ្ញុំថា លោក គាត ឈន់ ថាពួកយើងចូលរួមគណៈប្រតិភូតកម្ពុជា"។

អ៊ីចឹង ថាតើអត្ថន័យដូចម្តេច ដែលនិយាយថាទាំងបីនាក់ លោក, លោក គាត ឈន់ និង បូរី បានបង្កើតជាក្រុមស្នូលសម្រាប់ចលនា ឬក៏សម្រាប់ស្ថាប័នទៅអនាគតនោះ។ តើលោកអាចពន្យល់តុលាការបានទេ?

[០៩:២០:០០]

**លោក ស្វង ស៊ីគៀន៖**

**ឆ៖** បាទ យើងខ្ញុំទាំងបីគឺលោក អៀង សារី បានតាក់ -- បានចាត់តាំងឲ្យជាក្រុមយកព័ត៌មានពីប្រភពព័ត៌មានផ្សេងៗ ជាពិសេសពីវិទ្យុបរទេស ហើយធ្វើទស្សនៈសភាពការណ៍មួយខែម្តងជូនគាត់។ ក្នុងទស្សនៈសភាពការណ៍ហ្នឹងគឺថា យើងក៏មានមតិអំពី -- យើងក៏មានធ្វើការវិភាគអំពីសភាពការណ៍នៃការតស៊ូរបស់ប្រជាជនកម្ពុជាយើង និងកម្ពុជាពេលនុំងមិនទាន់ក្លាយទៅកម្ពុជាប្រជាធិបតេយ្យទេ។ គឺថាសភាពភាពការ -- ធ្វើការវិភាគនៃសភាពការណ៍តស៊ូហ្នឹង ហើយនិងឥទ្ធិពលនៃមាតុភូមិយើងដែលទើបបានរំដោះថ្មីៗនេះនៅលើឆាកអន្តរជាតិ។ សេចក្តីព័ត៌ -- ការតាក់តែងព័ត៌មាននេះគឺថាលោក គាត ឈន់ គាត់ជាប្រធាន ហើយគាត់ប្រគល់ជូនលោក អៀង សារី មួយខែម្តងៗបាទ។

[០៩:២១:៣៣]

**ស៖** នៅពេលដែលលោកប្រើពាក្យថា “ក្រុមស្នូល” ជាស្នូលនេះ គឺតើលោកចង់សំដៅយកអ្វី? តើមានន័យថាលោកជាមនុស្សដំបូងដែលត្រូវចាប់ផ្តើមរៀបចំក្រសួង ហើយនិងប្រមូលអ្នកផ្សេងទៀតដើម្បីឲ្យមកធ្វើការ ឬក៏យ៉ាងដូចម្តេច?

**ឆ៖** ស្នូល មានន័យថា គឺយើងតាមដានសភាពការណ៍អន្តរជាតិ ការវិវត្តន៍នៃសភាពការណ៍អន្តរជាតិដែលទាក់ទងផ្ទាល់ដល់ដំណើររីកលូតលាស់នៃការតស៊ូរបស់យើងនៅក្នុងប្រទេស ក្រោយពីថ្ងៃរំដោះទី១៧ មេសា ១៩៧៥។ ហើយចេញពីការវិភាគនៃសភាពការណ៍នេះ គឺនាំជាជំនួយដល់អ្នកដឹកនាំរបស់យើងរៀបចំ ហើយនិងកំណត់មាគ៌ានយោបាយបរទេសរបស់រដ្ឋថ្មី ដែលទើបនឹងកើតឡើងនេះបាទ។

**ស៖** សូមអរគុណ។ ហើយប្រសិនបើ ខ្ញុំសូមអានសេចក្តីដកស្រង់ ដូច ចេញពីឯកសារនេះដែលលោកមានចំពោះមុខហើយនៅក្នុងទំព័រ១៥ ភាសាអង់គ្លេស ERN 00813091, ខ្មែរ ERN 00583621 ដល់ 22, បារាំង ERN 00079013។

**លោក ហ្សាស្តេី ប៉ោ៖**

សូមមន្ត្រីតុលាការជួយ។

**សួរដោយលោក ហ្សាស្តេី ប៉ោ៖**

**ស៖** ហើយខ្ញុំនឹងអានមួយបន្ទាត់ទេពីរទំពីរនេះ។ ទំព័រនេះ គឺលោកបានសរសេរថា ដូច គាត ឈន់ ដែរ ប្រសិទ្ធិ គឺជាអ្នកចាត់ចែងម្នាក់នៅក្នុងក្រសួង ទោះបីជាគាត់មិនមានឋានៈជាផ្លូវការណាមួយ

ក៏ដោយ។

[០៩:២៣:៥៧]

លោក សួង ស៊ីគឿន តើថ្ងៃនេះលោកអាចបញ្ជាក់បានទេ ថា គាត ឈន់ ហើយនិងលោក ប្រសិទ្ធិ គឺជាខួរក្បាលដ៏សំខាន់នៃក្រសួង? តើអ្នកមនុស្សសំខាន់របស់ក្រសួង តើលោកមានន័យដូចម្ដេច បាទ?

**លោក សួង ស៊ីគឿន៖**

**ឆ៖** ន័យសំខាន់ គឺថាមានន័យថា លោក គាត ឈន់ ក៏គាត់ជា -- គាត់ធ្លាប់ធ្វើជារដ្ឋមន្ត្រី ហើយគាត់បំពេញលក្ខណៈសម្បត្តិមួយដែលកម្រមានដែរ នៅក្នុងចំណោមពួកបញ្ញាជនយើងហ្នឹង។

[០៩:២៤:៥៥]

ទី១ គាត់ជាមនុស្សឈ្លាសវៃ ជាអ្នកដែលឈ្មុសឈ្មុលស្រាវជ្រាវ ហើយរកយល់ រកដឹង រកស៊ីជម្រៅចំពោះបញ្ហាមួយដែលកើតឡើង។ ទី២ គាត់មានអត្តចរិតមួយគឺ ទូលាយ ចិត្តទូលាយ សន្ដោស ហើយអាចប្រមែប្រមូលចងក្រងមនុស្សបានច្រើន មិន -- តាមខ្ញុំដឹង ក្នុងកិច្ចការរបស់គាត់ គាត់មិនដែលមានសត្រូវផ្ទាល់ខ្លួនអីទេ។ ដូច្នេះ គាត់បំពេញលក្ខណៈមួយដែលស្រួលនឹងប្រាស្រ័យទាក់ទង ស្រួលនឹងសហការ ហើយគាត់ជាមនុស្សត្រង់ដែរ។ គាត់ឃើញអ្វី គាត់យល់អ្វី គាត់តែងតែបញ្ចេញមតិរបស់គាត់ មិនលាក់លៀមទេ អស់ពីពោះពីពុង ក៏ប៉ុន្តែគាត់មិនចេះតែមានមតិជាទូទៅទេ គាត់មានមតិចំពោះតែអ្នកណាដែលជាអ្នកទទួលខុសត្រូវរបស់គាត់ផ្ទាល់ដែរ។ ហើយក្នុងពេលនេះ លោក អៀង សារី គាត់ជាមនុស្សដែលស្ដាប់មតិអ្នកដទៃ ហើយគាត់អំពាវនាវឲ្យសហការីរបស់គាត់ហ្នឹងមានមតិលើគ្រប់បញ្ហា ហើយកុំមានដូចថាបារម្ភ ព្រួយបារម្ភ ឬក៏ខ្លាចរំពៃអីឲ្យមានមតិ ក៏ប៉ុន្តែត្រូវតែឲ្យមានស្មារតីទទួលខុសត្រូវ។ គាត់តែងតែណែនាំយើងថា បើមានមតិអ្វី ត្រូវគិតគូរថាតើយើងមានមតិទៅវាមានបច្ច័យយ៉ាងណា ព្រោះយើងនៅជិតអ្នកដឹកនាំ--

[០៩:២៧:១៧]

**ស៖** លោកសួង ស៊ីគឿន -- បាទ លោកសាក្សីខ្ញុំសូមអរគុណដែលលោកបានព្យាយាម ៗឆ្លើយពិស្ដារ ប៉ុន្តែសំណួរគឺទាក់ទងទៅនឹងលោក អៀង សារី នោះទេ។ ប្រហែលជាមេធាវីរបស់គាត់នឹងសួរលោកនៅពេលក្រោយ។ ប៉ុន្តែខ្ញុំផ្ដោតតែលើអំពីថ្នាក់ក្រោមនៅក្នុងមន្ទីរប-១ ហើយនិងសួរសំណួរបន្តទៅទៀតគឺទាក់ទងទៅនឹង -- ពីមុននឹងខ្ញុំសួរនោះគឺថាតើលោក គាត ឈន់ គឺជាអតីតរដ្ឋមន្ត្រី តើលោកប្រាប់

ខ្ញុំបានទេ ថាតើ តើគាត់ជាអតីតរដ្ឋមន្ត្រីហ្នឹងរបស់ក្រសួងណា? ផ្នែកណា? ឬក៏ស្ថាប័នណា?

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយទេ! មិនមានពាក់ព័ន្ធនឹងអង្គហេតុចោទប្រកាន់ជនជាប់ចោទ ដែលយកមកសវនាការនេះទេ។ ហើយការផ្តល់សក្ខីកម្មចំពោះសំណួរនេះទំនងជាមិនផ្តល់វិភាគទានអ្វីក្នុងការស្វែងរកការពិតក្នុងរឿងក្តីនេះទេ។ យើងបានជម្រាបជូនលោក រំឭកលោករួចហើយ លោកមេធាវីគប្បីខិតខំព្យាយាមចំណាយពេលវេលាដ៏មានតម្លៃនេះ សួរដេញដោលឲ្យមានការពាក់ព័ន្ធទៅនឹងអង្គហេតុទាំងឡាយដែលចោទប្រកាន់ទៅលើជនជាប់ចោទ ដើម្បីឲ្យមានខ្លឹមសារក្នុងការផ្ទុះបញ្ជាំងអំពីលទ្ធភាព ឬអត្ថិភាពនៃពិរុទ្ធភាពទៅលើជនជាប់ចោទ ឬក៏ស្ថានផ្សេងទៀត នាំឲ្យមានការប្រែប្រួលនៅក្នុងការពិចារណាសម្រេចសេចក្តីរបស់តុលាការនាពេលចប់កិច្ចពិភាក្សាដេញដោល។

[០៩:២៩:០៨]

**លោក ហ្សាស្តើ ប៉ោ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ហ្សាស្តើ ប៉ោ៖**

**ស៖** ហើយខ្ញុំនឹងសួរឲ្យច្បាស់លាស់ គឺថាភាពពាក់ព័ន្ធគឺអាចនឹងច្បាស់ជាងនេះ ក្នុងករណីដែលយើងពិនិត្យមើលប្រវត្តិសាស្ត្របក្សកុម្មុយនីស្តកម្ពុជា នៅក្នុងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងរណសិរ្សរួបរួមជាតិកម្ពុជានោះ តើលោកអាចប្រាប់ខ្ញុំបានទេ តើលោក គាត ឈន់ ជារដ្ឋមន្ត្រីនៅក្នុងហ្វុង នៅក្នុងហ្គ្រុងហ្នឹងដែរឬទេ?

**ប្រធានអង្គជំនុំ៖**

មិនបាច់ឆ្លើយតបទេ! សំណួរនេះគឺមិនពាក់ព័ន្ធនឹងអង្គហេតុចោទប្រកាន់ទេ ឆ្ងាយណាស់។

[០៩:២៩:៥១]

**សួរដោយលោក ហ្សាស្តើ ប៉ោ៖**

**ស៖** លោក គាត ឈន់ -- ខ្ញុំនឹងបង្ហាញជូនលោកនូវសេចក្តីដកស្រង់ អំពីបទសម្ភាសន៍របស់លោក ដែលលោកបានផ្តល់ទៅសហចៅក្រមស៊ើបអង្កេតគឺថ្ងៃទី -- នៅក្នុងខែមីនា ឆ្នាំ២០០៩ ឯកសារ E3/871 ឯកសារ D13 អង់គ្លេស ERN 00 -- បារាំង ERN 00288240, ខ្មែរ ERN 00288233។ ហើយខ្ញុំសូមដកស្រង់នៅទំព័រ៥ ដែលនិយាយអំពី -- អង់គ្លេស ERN -- បាទដែល 46 ។

**លោក ហ្សាស្តេី ប៉ោ៖**

ហើយខ្ញុំសូមអនុញ្ញាតបង្ហាញនៅលើអេក្រង់ ជាភាសាខ្មែរ ហើយនិងសូមអនុញ្ញាតជូនឯកសារលើក្រដាសជូនលោកសាក្សីផងដែរបាទ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការមុននឹងដាក់ឯកសារលើអេក្រង់ រង់ចាំយើងសម្រេចជាមុនសិន មិនអនុញ្ញាតឲ្យដាក់មុនពេលយើងសម្រេចទេ។ មន្ត្រីបុគ្គលិកជំនួយការមេធាវី។

អនុញ្ញាតមន្ត្រីតុលាការទទួលឯកសារជាក្រដាសពីសាក្សី អ៎! ពីមេធាវីយកជូនសាក្សីពិនិត្យ!

*(មន្ត្រីតុលាការយកឯកសារជូនសាក្សី)*

[០៩:៣១:៤៦]

**សួរដោយលោក ហ្សាស្តេី ប៉ោ៖**

**ស៖** បាទ លោកសាក្សីឯកសារខ្ញុំនឹងអានជូនលោកផ្នែកដែលពាក់ព័ន្ធ សូមដកស្រង់ នេះជាចម្លើយរបស់លោកទៅសហចៅក្រមស៊ើបអង្កេត "ដូចដែលខ្ញុំបានបញ្ជាក់រួចហើយមនុស្សផ្សេងទៀតត្រូវបានចាប់ជាអាទិ៍ គាត ឈន់ និង ជួន ប្រសិទ្ធិ ហើយ អៀង សារី បានជំទាស់ដោយពន្យល់ប្រាប់ ប៉ុល ពត ថា ប្រសិនបើអ្នកទាំងពីរនេះត្រូវចាប់ខ្លួន ក្រសួងការបរទេសត្រូវតែលុបចោលតែម្តងទៅ"។ ចប់សេចក្តីដកស្រង់។ លោកសាក្សី តើចម្លើយរបស់លោកនេះបង្ហាញថា អៀង សារី គិតថាបុគ្គលទាំងពីរនាក់នេះ គាត ឈន់ និង ជួន ប្រសិទ្ធិ នោះគឺជាមនុស្សសំខាន់នៅប-១ ដែរឬទេ? ប៉ុន្តែខ្ញុំចង់បានមតិរបស់លោក ការយល់ដឹងរបស់លោកពីការបញ្ហានេះ តាមមតិរបស់លោក តើ គាត ឈន់ ហើយនិង ជួន ប្រសិទ្ធិ ជាមនុស្សសំខាន់ខ្លាំងដែរឬទេនៅប-១ កាលណោះ?

[០៩:៣៣:០៥]

**លោក សួង ស៊ីគឿន៖**

លោកប្រធាន ខ្ញុំ -- មុននឹងឆ្លើយសំណួរហ្នឹង ខ្ញុំចង់ពិគ្រោះយោបល់ជាមួយនឹងមេធាវីរបស់ខ្ញុំ។ សូមអនុញ្ញាតពីលោកប្រធានបាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះមិនអនុញ្ញាតទេ សំណួរនេះមិនមានដាក់ពិរុទ្ធភាពទៅលើលោកៗទេ លោកអាចពិគ្រោះនៅពេលដែលសំណួរណា ដែលចម្លើយរបស់លោកនាំឲ្យលោកដាក់ពិរុទ្ធភាពបានន័យថា ទម្លាក់

កំហុសទៅលើលោកតែប៉ុណ្ណោះ។ សំណួរនេះលោកអាចមិនឆ្លើយក៏បាន ពីព្រោះជាសំណួរច្រំដែលទេ។

**លោក សួង ស៊ីគឿន៖**

**ឆ៖** លោកមេធាវីបញ្ជាក់ថា "ខ្លាំង" ហ្នឹងយ៉ាងម៉េចទៅ "ខ្លាំង"?

**ប្រធានអង្គជំនុំ៖**

លោកមេធាវីតាំងសំណួរសាជាថ្មីម្ដងទៀតឲ្យបានច្បាស់លាស់ ហើយសំណួរនេះទំនងជាដដែលទេ ព្រោះមានសំណួរបានសួររួចហើយ។

[០៩:៣៤:២៥]

**លោក ហ្សាស្តេី ប៉ៅ៖**

លោកប្រធាន ខ្ញុំនឹងសួរសំណួរឡើងវិញដោយសម្រួលឃ្លា។

**សួរដោយលោក ហ្សាស្តេី ប៉ៅ៖**

**ស៖** លោក សួង ស៊ីគឿន តើលោកយល់គំនិតដូចលោក អៀង សារី ដែរឬទេថា គាត ឈន់ ហើយនិង ជួន ប្រសិទ្ធិ គឺជាមនុស្សសំខាន់ បុគ្គលិកសំខាន់នៅប-១ នោះ?

**លោក សួង ស៊ីគឿន៖**

លោកប្រធាន អត់ទោស តើខ្ញុំអាច -- អានេះមិនសួរសំណួរសួរ--

**ប្រធានអង្គជំនុំ៖**

មិនបាច់ឆ្លើយទេ មិនពាក់ព័ន្ធអីទេ!

**លោក ហ្សាស្តេី ប៉ៅ៖**

លោកប្រធាន ខ្ញុំសូមការបំភ្លឺ ពីព្រោះថា ខ្ញុំមិនបានពួចម្លើយលោក សួង ស៊ីគឿន នោះទេ។ ខ្ញុំបាន--

**ប្រធានអង្គជំនុំ៖**

យើងអត់ឲ្យសាក្សីឆ្លើយទេ ពីព្រោះវាជា ក្រៅអង្គហេតុ មិនពាក់ព័ន្ធនឹងបទចោទប្រកាន់ជាបន្ទុកទៅលើជនជាប់ចោទដែលជាកូនក្ដីរបស់លោកទេ។

[០៩:៣៥:៥៦]

**សួរដោយលោក ហ្សាស្តេី ប៉ៅ៖**

**ស៖** ខ្ញុំនឹងចូលទៅប្រធានបទ ហើយនិងទៅចម្លើយមួយទៀតរបស់លោក សួង ស៊ីគឿន គឺ

ឯកសារ E3/42 ជាឯកសារ D167 នៅថ្ងៃទី៦ ឧសភា ២០០៩ ហើយខ្ញុំមានឯកសារលើក្រដាសជាភាសាខ្មែរ។

**លោក ហ្សាស្តើ ប៉ោ៖**

សូមអនុញ្ញាតឲ្យមន្ត្រីតុលាការជូនទៅលោក ទៅសាក្សីដើម្បី -- អង់គ្លេស ERN គឺ 003272 12, ហើយបារាំង ERN 00232722, ហើយខ្មែរ ERN 003270200 (ស៊ីក)។ ហើយខ្ញុំសូមអនុញ្ញាតបង្ហាញលើអេក្រង់នៅទំព័រ៨ បាទ ជាភាសាខ្មែរ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមន្ត្រី -- អំ តំណាងសហព្រះរាជអាជ្ញា!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

ជម្រាបសួរអស់លោក លោកស្រីចៅក្រមជាទីគោរព។ បាទ ខ្ញុំមានសំណួរទាក់ទងនឹងវិធីសាស្ត្រទាក់ទងនឹងការដកស្រង់របស់លោកមេធាវីនោះ។ ដែលការដកស្រង់ចុងក្រោយនោះ មិនត្រូវបានដកស្រង់ពាក្យពេចន៍ដូចបេះបិទនោះទេជាភាសាបារាំង ពីព្រោះថា ទំព័រនោះមិនត្រូវបានផ្តល់ជូនទៅអ្នកបកប្រែទេ។ គឺឯកសារ D2167 អ៊ីចឹងសូមឲ្យលោកមេធាវីផ្តល់ទំព័រពាក់ព័ន្ធ ហើយនិងសម្រង់ដែលត្រូវអាននោះធ្វើយ៉ាងណា ដើម្បីឲ្យអ្នកបកប្រែអាចតាមទាន់ បើមិនដូច្នោះទេ អ្នកបកប្រែមិនអាចតាមទាន់ទេគឺ ឯកសារ អម្បាញ់មិញនេះ គឺឯកសារ D167 ហើយនិង E3/142។

[០៩:៣៧:៥៤]

**លោក ហ្សាស្តើ ប៉ោ៖**

លោកប្រធាន ខ្ញុំអាចជូនជាឯកសារ ERN ជាភាសាបារាំងគឺ 0032722 (ស៊ីក) រហូតដល់ 00327230។ បាទ អ៊ីចឹងសំណួរនេះគឺខ្ញុំ ពាក់ព័ន្ធនឹងឯកសារនេះ គឺខ្ញុំបានចង់សួរដែលខ្ញុំលើកចេញពីឯកសារ ជាភាសាបារាំង។ ប៉ុន្តែយើងមានឯកសារមួយចំនួន មានតែជាភាសាអង់គ្លេស និងភាសាខ្មែរដូចដែលព្រះរាជអាជ្ញាបានលើកឡើងអ៊ីចឹង។ ហើយខ្ញុំបាន -- ប៉ុន្តែឯកសារយោងជាក់ស្តែងហ្នឹង គឺយើងអត់ដឹងច្បាស់លាស់ទេ ព្រោះដោយសារតែយើងអត់ទាន់មានឯកសារនេះ ជាភាសាបារាំងនៅឡើយ ហើយយើងក៏មិនទាន់បានស្រាវជ្រាវ អំពីឯកសារនេះដែរ ទាក់ទងទៅនឹងភាសាបារាំង។ ដូច្នេះ ប្រសិនជាខ្ញុំអាចដកស្រង់នូវឯកសារនេះបាន អ៊ីចឹងខ្ញុំគិតថា ប្រហែលជាឯកសារនេះអាចត្រូវបានបកប្រែជាភាសាបារាំងនៅពេលក្រោយ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីមេធាវី យកជូនសាក្សីពិនិត្យ! ហើយអនុញ្ញាតឲ្យដាក់បង្ហាញឯកសារលើអេក្រង់ទូរទស្សន៍ និងកុំព្យូទ័រ។

**លោក ហ្សាស្តេ ប៉ោ៖**

សូមអរគុណ។

[០៩:៣៩:១២]

**សួរដោយលោក ហ្សាស្តេ ប៉ោ៖**

**ស៖** មុនពេលដែលខ្ញុំចាប់ផ្តើមពន្យល់ ខ្ញុំចង់ពន្យល់ទៅសាក្សីថា នេះគឺជាសំណួរដែលពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធនៃប-១ ដែលវាពាក់ព័ន្ធនៅក្នុងការវាយតម្លៃទៅលើរចនាសម្ព័ន្ធ និងសមាសភាពនៃអ្នកដែលធ្វើការនៅទីនោះ ក៏ដូចជាទំនួលខុសត្រូវរបស់ពួកគាត់។ ហើយសំណួរនេះ ក៏នឹងឆ្លើយតបទៅ -- សង្ឃឹមថា នឹងបានចម្លើយពីសាក្សីនេះ។ ឥឡូវ ខ្ញុំចង់លើកនូវដំណកស្រង់ហ្នឹងពីទំព័រនេះ៖ “អៀង សារី បានពន្យល់ថា នៅក្នុងការជួបប្រជុំគ្នានៅក្នុងនាយកដ្ឋានគោលនយោបាយហ្នឹង គាត់បានពន្យល់ថា ជួន ប្រាសិទ្ធ, គាត ឈន់, ហើយនិង តូច ខាំឌឿន, អ៊ុក សុគន្ធ ហើយ ចាន់ យូរ៉ាន់, ទេព ប៊ុនរិទ្ធ, ហើយនិង ខ្ញុំខ្លួនឯង និងក៏ដូចជាលោក សួរ សេ (ស៊ីក) ដែលជាអគ្គលេខាធិការ -- អ៎! ដែលជាលេខានៃបក្សហ្នឹង។ លោក ជួន ប្រសិទ្ធិ ហើយនិង គាត ឈន់ ត្រូវបានគេចោទប្រកាន់ថា ជាសមាជិករបស់ភ្នាក់ងារ សេ.អ៊ី.អា ហើយគណៈកម្មាធិការសន្តិសុខបានសម្រេចចាប់ខ្លួនពួកគាត់។ ហើយ អៀង សារី បានពន្យល់ថា ក្រសួងមិនអាចដំណើរការបានដោយគ្មានពួកគេទេ។ ដូច្នេះបានន័យថា យើង -- គាត់មានជំនឿទុកចិត្តទាំងស្រុងទៅលើពួកគេ។ ហើយម្យ៉ាងទៀត ពួកគាត់គឺ អ្នកទាំងនោះគឺ ដូចជាខ្លួនគាត់ដែរ គឺស្ថិតនៅក្នុងរង់ម៉ាក្ស-ឡេនីន ដែល អៀង សារី ជាស្ថាបនិកម្នាក់ ហើយលោក កេង វ៉ាន់សាក់ ហើយនិង រ័ត្ន សាមឿន ក៏នៅក្នុងហ្នឹងដែរ”។

ដូច្នេះ ដើម្បីបន្តសំណួររបស់ខ្ញុំ លោក សួង ស៊ីគឿន ដូចដែលខ្ញុំៗ ចង់យល់បន្ថែមទៀតអំពីរចនាសម្ព័ន្ធប-១ ហើយនិងកម្រិតនៃការទទួលខុសត្រូវនៅទីនោះ។ តើលោកយល់ដូច អៀង សារី ទេ ដែលថាក្រសួងការបរទេសហ្នឹងគាត់មិនអាចដំណើរការទៅបានទេ ប្រសិនបើអត់មានវត្តមានរបស់លោក គាត ឈន់ និងលោក ជួន ប្រសិទ្ធិ នោះ?

[០៩:៤១:០៩]

**ឆ៖** លោកប្រធាន តើនេះមិនជាសំណួរទេ សួរពីយោបល់របស់ខ្ញុំ។ តើខ្ញុំត្រូវឆ្លើយ ឬមិនត្រូវអាហ្នឹង?

**ប្រធានអង្គជំនុំ៖**

មិនបាច់ឆ្លើយតបទេ។ លោកមិនអាចបញ្ចេញមតិយោបល់ផ្ទាល់ខ្លួនរបស់លោកតបទៅនឹងសំណួរទេ គឺលោក អ្វីដែលលោកបានឃើញ បានដឹង បានឮ បានចងចាំ អាហ្នឹងសឹមលោកឆ្លើយ ហើយម្យ៉ាងទៀតសំណួរនេះច្រំដែលនឹងសំណួរអម្បាញ់មិញទេ។

**សួរដោយលោក ហ្សាស្តេ ប៉ោ៖**

**ស៖** លោក សួង ស៊ីគឿន ខ្ញុំមិនមែនសូមសួរនូវយោបល់របស់លោកទេ ប៉ុន្តែខ្ញុំចង់ឲ្យលោកផ្អែកនៅចម្លើយរបស់លោកហ្នឹងទៅតាមបទពិសោធន៍របស់លោកដែលលោកធ្លាប់ធ្វើការនៅ ប-១ អស់រយៈពេលជាច្រើនឆ្នាំនោះ។ នៅក្នុងការវាយតម្លៃរបស់លោក តើអាចក្រសួង -- ថាក្រសួងការបរទេសហ្នឹង តើអាចដំណើរការទៅបានទេ បើសិនជាអត់មាន គាត ឈន់ ហើយនិង ជួន ប្រាសិទ្ធ ហ្នឹង ដែលវាគឺជាយោបល់ ឬក៏គំនិតរបស់លោក អៀង សារី ដែរ ដែលថាបើគ្មានអ្នកទាំងពីរនាក់ហ្នឹង គឺក្រសួងមិនអាចដំណើរការទៅបាននោះ។

[០៩:៤២:២១]

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយតបទេ! សំណួរមិនអាច -- លោកមិនមែនជាអ្នកជំនាញអាចវាយតម្លៃបញ្ហាអ្វីបានទេ នៅក្នុងតុលាការ ព្រោះលោកជាសាក្សី។ ទី២ សំណួរនេះ បានសួរម្តងរួចហើយ ជាសំណួរច្រំដែល។

**លោក ហ្សាស្តេ ប៉ោ៖**

សូមអរគុណលោកប្រធាន។

ខ្ញុំនឹងចូលទៅដល់ប្រធានបទមួយទៀតពាក់ព័ន្ធនឹងឯកសារថ្មី ដែលវានៅតែពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធការងារនៅប-១ ហើយខ្ញុំសូមលើកនូវសៀវភៅរបស់លោក ហ្វីលីព ស្សូត ហើយនៅ "*អាណាតូមី អហ្វ ណាយម័រ*" ដែលអង់គ្លេស -- ERN ជាភាសាអង់គ្លេស ហើយនិង ឯកសារ គឺ E3/9 ហើយ ERN ជាភាសាអង់គ្លេសគឺ 0039671 (ស៊ីក) ហើយ ERN ជាភាសាបារាំងគឺ 00639445 នេះគឺជាឯកសារដែលមានតែជាភាសាទាំងពីរទេ ដែលមាននៅក្នុងសំណុំរឿងរបស់យើង។

ហើយការយោងទៅលើឯកសារនេះ គឺជាភាសាអង់គ្លេស ERN គឺ 00036547 រហូតដល់ 48។ ហើយសម្រាប់ភាសាបារាំងវិញ គឺ ERN ដែលពាក់ព័ន្ធនឹងគឺ 00639901។ ហើយប្រសិនជាលោកប្រធានអនុញ្ញាតខ្ញុំសូមបង្ហាញនូវឯកសារនេះ នៅលើអេក្រង់ទូរទស្សន៍ ហើយខ្ញុំសូមអនុញ្ញាតឲ្យលោកប្រធានឲ្យយកឯកសារកូពីជូនទៅសាក្សី ជាភាសាបារាំងបាទ។

[០៩:៤៤:១៥]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីមេធាវី យកជូនសាក្សីពិនិត្យ ហើយនិងអនុញ្ញាតឲ្យបង្ហាញឯកសារនេះនៅលើអេក្រង់ទូរទស្សន៍ និងកុំព្យូទ័រ។

**លោក ហ្វាស្តើ ប៉ោ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ហ្វាស្តើ ប៉ោ៖**

**ស៖** នៅក្នុងពេលជាមួយគ្នានេះ ខ្ញុំចង់អាននូវដំណកស្រង់ចេញពីសៀវភៅនេះ ដើម្បីឲ្យសាក្សីគាត់ផ្តល់ការអត្ថាធិប្បាយ។ នេះគឺជាឯកសារមួយដែលលើកឡើង អំពី ប៉ុល ពត ដែលមានភាសា -- នៅក្នុងភាសាអង់គ្លេសហ្នឹង គឺលេខ 339 នេះគឺសំដៅលើ ប៉ុល ពល លទ្ធផលដែលថាគាត់មានការខកចិត្តដោយសាកូនចៅរបស់គាត់ហ្នឹង គឺសមត្ថភាពរបស់អ្នកនៅក្រោមបង្គាប់របស់គាត់ ប៉ុន្តែគាត់មានអារម្មណ៍ថា ចាំបាច់ត្រូវមានការបោសសម្អាតនៅធាតុផ្សំ -- នូវសមាសភាពមួយចំនួន ហើយដូចសីហនុ ដែរ គឺគាត់ចាំបាច់ត្រូវតែពិនិត្យមើលអ្នកណាខ្លះដែលគាត់ត្រូវចូលរួមនៅក្នុងពិធីជប់លៀងធំៗអីមួយចំនួន ហើយនិងមានការណែនាំផ្សេងទៀត ទៅដល់មន្ត្រីនៅតាមបណ្តាខេត្តដែលគាត់ត្រូវទទួលបដិសណ្ឋាកិច្ចរបស់ភ្ញៀវ ហើយមានការផ្សាយតាមវិទ្យុ ទូរទស្សន៍ ហើយនិងការបញ្ចាក់អំពីកម្មវិធី និងកាលវិភាគនៃកម្មវិធី។ ហើយការងាររបស់ជាមួយនឹងព្រះមហាក្សត្រហ្នឹង គឺទាក់ទងទៅនឹងការងារច្បាប់ ហើយ សួង ស៊ីគៀង គាត់គ្រប់គ្រងទៅលើការងារតូចតាចមួយចំនួន ដែលទាក់ទងទៅនឹងការអនុវត្តតាមការបញ្ជារបស់មេដឹកនាំ។ ហើយគាត់មិនមានការ -- លោក សួង ស៊ីគៀង លោក ហ្វីលីព ស្សូត គាត់បានដកស្រង់នូវពាក្យសម្តីរបស់លោកនៅទីនេះ ហើយសំណួររបស់ខ្ញុំទី១ គឺថាតើលោកនៅចាំទេ ថាលោកបានធ្លាប់និយាយជាមួយនឹងលោក ហ្វីលីព ស្សូត អំពីរបបកម្ពុជាប្រជាធិបតេយ្យ?

[០៩:៤៦:៣៧]

**ឆ៖** ហ្វីលីព ស្បូត គឺថាគាត់ធ្លាប់ធ្វើជាតំណាងរបស់ទីភ្នាក់ងារព័ត៌មានអង់គ្លេស ប៊ី.ប៊ី.ស៊ី នៅប៉េកាំង នៅពេលដែលខ្ញុំនៅធ្វើជាការងារនៅប៉េកាំង។ ដូច្នោះ ខ្ញុំធ្លាប់ស្គាល់គាត់ដែរ ហើយមុននឹងគាត់សរសេរសៀវភៅគាត់នេះ គឺថា ខ្ញុំបានជូនដំណើរគាត់ដើម្បីជួបអ្នកដឹកនាំកម្ពុជាប្រជាធិបតេយ្យធំៗ ជាពិសេសពួកខាងកងទ័ព ដូចថាដើម្បីសម្រួលកិច្ចការរបស់គាត់ ខ្ញុំបានជូនគាត់។ ដូច្នោះ ខ្ញុំមិនអាចបដិសេធទេ ថាក្នុងពេលដំណើរនេះ ខ្ញុំមិនបាននិយាយអី អំពីកម្ពុជាប្រជាធិបតេយ្យបាទ។

**ស៖** សូមអរគុណលោក ស្វួង ស៊ីគឿន។ នេះគឺជាចម្លើយដែលច្បាស់លាស់សម្រាប់ខ្ញុំ។ សំណួរបន្តបន្ទាប់ទៀតនេះ គឺលោក ហ្វីលីព ស្បូត ហ្នឹង បានលើកឡើងការ -- នូវការលើកឡើងរបស់លោកពី ប៉ុល ពត ដូចថាការគ្រប់គ្រងទៅលើចំណុចតូចៗលម្អិតទៀតហ្នឹង--

**អ្នកបកប្រែ៖**

សូមទោសលោកប្រធាន តើអាចអនុញ្ញាតឲ្យមេធាវី គាត់អានឡើងវិញ ដោយសារដំណកស្រង់គាត់អានលឿន យើងខ្ញុំបកអត់ទាន់បាទ។

[០៩:៤៨:០៣]

**ប្រធានអង្គជំនុំ៖**

លោកមេធាវី អានការដកស្រង់នេះឡើងវិញ ហើយសូមឲ្យយឺតៗ ពីព្រោះអ្នកបកប្រែ បកប្រែមិនទាន់ទេ!

**លោក ហ្សាស្តើ ប៉ោ៖**

សូមអធ្យាស្រ័យ លោកប្រធាន ខ្ញុំនឹងព្យាយាម។

**សួរដោយលោក ហ្សាស្តើ ប៉ោ៖**

**ស៖** លោក ស្វួង ស៊ីគឿន ខ្ញុំកំពុងតែដកស្រង់នូវពាក្យសម្តីរបស់លោក ដែលលោកបាននិយាយជាមួយនឹងលោក ហ្វីលីព ស្បូត ហើយខ្ញុំសូមដកស្រង់នៅពេលដែលលោកលើកឡើងអំពី ប៉ុល ពត។

[០៩:៤៨:៣៤]

អ៊ីចឹង ខ្ញុំសូមដកស្រង់ដូចខាងក្រោម៖ "ការគ្រប់គ្រងនូវចំណុចលម្អិតតូចៗ វាគឺជាចំណុចមួយដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ -- គ្រប់គ្រង ហើយចំណែកឯ ប៉ុល ពត គឺគាត់ចង់ធ្វើការគ្រប់គ្រងផ្តាច់មុខទៅលើ គ្រប់អ្វីៗទាំងអស់"។ ជាសំណួររបស់ខ្ញុំ លោក ស្វួង ស៊ីគឿន តើលោកនៅតែរក្សានូវការយល់ឃើញរបស់លោក ដូច្នេះចំពោះ ប៉ុល ពត រហូតដល់សព្វថ្ងៃនេះ?

**លោក ស្នួង ស៊ីគឿន៖**

**ឆ៖** លោកប្រធាន អាហ្នឹង ជាសំណួរចំពោះការយល់ដឹងរបស់ខ្ញុំ។ អាហ្នឹងដូចជាមិនពាក់ព័ន្ធដល់ខ្ញុំទេ ក្នុងឋានៈជាសាក្សីបាទ។

**ប្រធានអង្គជំនុំ៖**

ប៉ុន្តែនេះជាសៀវភៅ តើលោកធ្លាប់ឆ្លើយឆ្លងជាមួយនឹងអ្នកសរសេរសៀវភៅនេះដែរឬទេ? ខ្លឹមសារនេះ ខ្លឹមសារដែលលោកមើល លោកអានបានទេ ព្រោះជាភាសាបារាំង? លោកចងចាំនឹកឃើញទេ?

**លោក ស្នួង ស៊ីគឿន៖**

ខ្ញុំសុំជា -- ខ្ញុំចេះមើលអង់គ្លេសដែរតើ ម៉េចមិនយកអាភាសាដើមមើល៍ ឲ្យខ្ញុំ អាហ្នឹង ខ្ញុំស្រួល ប៉ុន្តែអាបកប្រែនេះ ខ្ញុំចង់បានភាសាដើមជាអង់គ្លេស។ ព្រោះគាត់ជាសរសេរជាអង់គ្លេស។

**ប្រធានអង្គជំនុំ៖**

មាន១ឯកសារជាអង់គ្លេសទេ លោកមេធាវី?

**លោក ហ្សាស្តេ ប៉ោ៖**

លោក ស្នួង ស៊ីគឿន ខ្ញុំគិតថាលោកមានឯកសារហ្នឹងហើយ ខ្ញុំមានឯកសារហ្នឹង អ៊ីចឹង ប្រហែលមន្ត្រីតុលាការគាត់អាចឲ្យលោកមើលជាភាសាបារាំង ព្រោះយើងភាសាបារាំងយើងមានជាឯកសារក្រដាសជូនលោកហើយ។

[០៩:៥១:៣៣]

**លោក ស្នួង ស៊ីគឿន៖**

**ឆ៖** ខ្ញុំអាចឆ្លើយបានថា អ្វីដែល ហ្វីលីព ស្សត សរសេរនេះ គឺវាបញ្ជាំងនូវការសង្កេតរបស់ខ្ញុំអំពីការដឹកនាំរបស់ ប៉ុល ពត បាទ ព្រោះខ្ញុំធ្លាប់បានរស់នៅជាមួយគាត់ពីរឆ្នាំដែរ ហើយបន្តមកក៏ក្នុងការងារបំពេញភារកិច្ចរបស់ខ្ញុំ ខ្ញុំក៏ -- ពេលខ្លះ ខ្ញុំក៏ទទួលបញ្ជាផ្ទាល់ពីគាត់ដែរ។ គឺអ្វី១គឺគាត់ហ្មត់ចត់ណាស់ គាត់គិតគូរតាំងពីអាការបន្តិចបន្តួច។ ឧទាហរណ៍ឧបមាថា ភ្ញៀវធំ១ដូចជាប្រមុខរដ្ឋ រដ្ឋមន្ត្រីទី១ អំពីម្ហូបអាហារដែលទទួលភ្ញៀវនេះ គឺថាគាត់ពិនិត្យផ្ទាល់ខ្លួនគាត់តែម្តងបាទ។ គឺបារាំងហៅថា *ម៉ឺនុយ*។ អ្នកណាត្រូវដាក់ជា *អងដឺ* មុន ហើយអ្នកជាម្ហូបសំខាន់ *ឡាដឺរ៉េស៊ីស្តង់* ស្អីហ្នឹងគាត់ គឺគិតគូរផ្ទាល់របស់គាត់។ ដូចជាអត្ថបទផ្សាយក្នុងវិទ្យុក៏ដូចគ្នានេះដែរ។ ត្រូវអ្នកណានិយាយសុន្ទរ --អ៎! វិចារណកថា

ហើយត្រូវកាត់ដោយចម្រៀងអ្វី កាត់អត្ថបទដោយចម្រៀងអី ហើយអ្នកណាត្រូវច្រៀងអី គាត់គិតគូរផ្ទាល់របស់គាត់។ នេះជារបៀបដឹកនាំរបស់គាត់បាទ។

[០៩:៥៣:៣៥]

**សួរដោយលោក ហ្វាស្តើ ប៉ោះ៖**

**ស៖** សូមអរគុណលោក សួង ស៊ីគឿន ចំពោះចម្លើយរបស់លោក។ ឥឡូវខ្ញុំចង់បន្តទៅនឹងឯកសារមួយទៀត គឺឯកសារ D199/26.2.80។ ERN ជាភាសាអង់គ្លេសគឺ 00442300, ជាភាសាបារាំង 00386798, ខ្មែរ ជាភាសាខ្មែរគឺ 00820658។

**លោក ហ្វាស្តើ ប៉ោះ៖**

ហើយខ្ញុំសូមអនុញ្ញាតលោកប្រធាន បង្ហាញឯកសារនេះ យើងមានជាភាសាបារាំង ហើយនិងជាភាសាខ្មែរសម្រាប់ឲ្យសាក្សីគាត់ពិនិត្យមើល ជាឯកសារក្រដាស។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីលោកមេធាវីយកជូនសាក្សីពិនិត្យ! និងអនុញ្ញាតឲ្យបង្ហាញឯកសារនៅលើអេក្រង់កុំព្យូទ័រ។

**លោក ហ្វាស្តើ ប៉ោះ៖**

សូមអរគុណលោកប្រធាន។ នៅពេលដែលសាក្សី គាត់កំពុងតែមើលឯកសារនេះ ខ្ញុំសូមពន្យល់បន្តិច ថានេះគឺជាតួលេខដែលធ្វើនៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៧៨ ចេញពីក្រសួងការបរទេស ដែលពាក់ព័ន្ធទៅនឹងការធ្វើទស្សនកិច្ចរបស់គណៈប្រតិភូថៃ មកកាន់កម្ពុជាប្រជាធិបតេយ្យនៅក្នុងដើមឆ្នាំ១៩៧៨។

ពេលសាក្សីកំពុងតែអានឯកសារនេះ ខ្ញុំសូមអាននូវតួលេខនេះ។ កម្មវត្ថុហ្នឹងគឺដំណើរទស្សនកិច្ចមកកាន់ប្រទេសកម្ពុជារបស់រដ្ឋមន្ត្រីការបរទេសថៃ ហើយយើងនិយាយអំពីឥស្សរជនខ្មែរ ដែលជាចំណងជើងតូច។ ហើយខ្ញុំសូមលើកនូវតួលេខលេខ២១៧ “គណៈប្រតិភូថៃត្រូវបានទទួលបដិសណ្ឋារកិច្ចជាផ្លូវការដោយលោក អៀង សារី ឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងការបរទេស លោក ប៉ុល ពត ដែលជានាយករដ្ឋមន្ត្រី គាត់ -- លោកបានជួបជាមួយនឹងលោក អ៊ុយ ប៉ាឌី ហើយនិងគណៈប្រតិភូអមដំណើររបស់គាត់ ហើយគាត់មិនបានជួបជាមួយនឹង -- សម្តែងការគួរសមជាមួយនឹងប្រមុខរដ្ឋលោក ខៀវ សំផន ទេ។

[០៩:៥៦:១២]

លោកប៉ុល ពត ហ្នឹងគឺត្រូវបានគេមើលឃើញថា ជាមនុស្សម្នាក់ដែលមានសមត្ថភាពមុតមាំនៅក្នុងការសម្រេចចិត្ត និងការ -- និងមានទំនុកចិត្តចំពោះខ្លួនឯង។ ហើយនិយាយដោយប្រើសព្វនាមជាបុរសទី១នោះ គាត់ដូចជាចង់បង្ហាញឲ្យឃើញច្បាស់ថា គាត់បានដឹកនាំកិច្ចការរបស់ខ្លួន របស់ប្រទេសខ្លួនតាំងពីឆ្នាំ១៩៧៥មក។ ដូចគ្នានេះដែរ គាត់ក៏ចង់បង្ហាញផងដែរថា គាត់គឺជាមនុស្សដែលសម្រេចអនុមត្តិឲ្យនយោបាយមិត្តភាពកម្ពុជា-ថៃហ្នឹង ដោយបានបញ្ជាក់ថា រូបគាត់គឺជាអ្នកបញ្ចេញសម្រេចបញ្ជូនលោក អៀង សារី ទៅកាន់ក្រុងបាងកក នៅក្នុងឆ្នាំ៧៥។ ដូច្នេះគឺគាត់ស្តាប់សំណួរដោយហ្មត់ចត់ ហើយគាត់កម្រនឹងឆ្លើយសំណួរដោយលឿនណាស់ ប៉ុន្តែគាត់ត្រូវស្តាប់ឲ្យបានច្បាស់លាស់នៅពេលដែលមានការពិភាក្សាម្តងៗ។

នៅក្នុងអំឡុងពេលនៃការពិភាក្សាជាមួយលោក អៀង សារី គាត់ក៏បានផ្អែកទៅលើគំនិតរបស់លោក ជួន ប្រសិទ្ធិ ហើយនិងលោក គាត ឈន់ ដែលជាឥស្សរជនចាស់ទុំ ប៉ុន្តែពួកគាត់មិនត្រូវបានគេបញ្ជាក់ពីមុខងារនៅក្នុងការក្រសួងការបរទេសនោះទេ។ គេចាំបានថា លោក គាត ឈន់ គឺជាអតីតឧបនាយករដ្ឋមន្ត្រីមួយរូបនៃរដ្ឋាភិបាលហ្វ្រុង ហើយលោក ជួន ប្រសិទ្ធិ ជាអតីតរដ្ឋមន្ត្រីមួយរូបនៃហ្វ្រុងផងដែរ ដែលជាប្អូនប្រុសរបស់លោក ជួន ជឿន ដែលសព្វថ្ងៃជាមន្ត្រីក្រសួងសុខាភិបាល ហើយធ្លាប់បានអមដំណើរលោក អៀង សារី ក្នុងដំណើរទស្សនកិច្ចនៅក្នុងបណ្តាប្រទេសអាស៊ាន នាទិយរដូវឆ្នាំ៧៧ និងដំណើរទស្សនកិច្ចទៅអង្គការសហប្រជាជាតិ”។

[០៩:៥៧:៥០]

ដូច្នេះ ខ្ញុំអាចដកស្រង់ -- សុំឈប់ដោយសារៗយើងឃើញមានជំទាស់ពីភាគី។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវីសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងអង្គសវនាការទាំងមូល។ មេធាវីការពារក្តីអន្តរជាតិរបស់លោក នួន ជា បានអានឯកសារនេះហើយ ក៏ប៉ុន្តែមុននឹងមានការឆ្លើយតបលើការធ្វើអត្ថាធិប្បាយណាមួយពីលោកសាក្សីនេះ ខ្ញុំបាទសូមស្នើសុំឲ្យខាងមេធាវីលោក នួន ជា ឬក៏ឲ្យសាក្សីបញ្ជាក់បន្តិចថាតើ ឯកសារនេះសាក្សីធ្លាប់បានឃើញពីមុនដែរឬទេ? មុននឹងធ្វើការពិភាក្សានៅ

លើខ្លឹមសារនៃឯកសារនេះ។ បាទ សូមអរគុណ។

[០៩:៥៨:៥៥]

**លោក ហ្សាស្តេី ប៉ោ៖**

ខ្ញុំគិតថា គឺវាពាក់ព័ន្ធទៅនឹងសំណួរហើយ។ ខ្ញុំមិនជំទាស់ទៅនឹងគំនិត ដែលថាយើងសួរសំណួរទៅសាក្សីនេះនោះទេ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ ហើយលោក សួង ស៊ីគៀន ឯកសារដែលលោកអាននេះ ដែលស្នើសុំដោយមេធាវីការពារក្តីលោក នួន ជា ដែលដាក់ដេញដោលនាពេលនេះ ដែលលោកកំពុងអាននេះ តើលោកធ្លាប់ឃើញឯកសារនេះដែរឬទេ?

**លោក សួង ស៊ីគៀន៖**

ខ្ញុំមិនដែលឃើញឯកសារនេះទេបាទ។

**ប្រធានអង្គជំនុំ៖**

បើមិនដែលឃើញទេ គឺមេ -- មន្ត្រីរដ្ឋបាលតុលាការទទួល -- ដកឯកសារអម្បាញ់មិញពីសាក្សី ហើយឲ្យបុគ្គលិកជំនួយការមេធាវីដកឯកសារអម្បាញ់មិញចេញពីអេក្រង់កុំព្យូទ័រ!

លោកមេធាវីចង់សួរអ្វីសួរបាន ដោយដកស្រង់នូវខ្លឹមសារ នៃឯកសារមកសួរដេញដោល ដូចករណីដែលយើងបានអនុវត្តកន្លងមកជាច្រើនលើកហើយ។

**លោក ហ្សាស្តេី ប៉ោ៖**

សូមអរគុណលោកប្រធាន។

[១០:០០:៣៣]

**សួរដោយលោក ហ្សាស្តេី ប៉ោ៖**

**ស៖** លោក សួង ស៊ីគៀន។ សំណួររបស់ខ្ញុំទី១ ទៅលោកនោះថាតើលោកប្រហែលជាបានចូលរួមការប្រជុំ ដែលគេរៀបរាប់នៅក្នុងទូរលេខនេះ ថាទស្សនកិច្ចរបស់គណៈប្រតិភូថៃមកកម្ពុជា នៅដើមឆ្នាំ១៩៧៨ ហ្នឹងដែរឬទេ?

**លោក សួង ស៊ីគៀន៖**

**ឆ៖** ខ្ញុំបានចូលរួមក្នុងពេលដែលរដ្ឋមន្ត្រីក្រសួងការបរទេសថៃ លោក ឧប្រាឌិត ហ្នឹង គឺថា

គាត់មកសម្តែងការគួរសម ហើយនិងពិភាក្សាជាមួយនឹងលោក អៀង សារី ពេលនោះជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកការងារបរទេស។ ប៉ុន្តែក្រៅពីនេះ ខ្ញុំមិនដែលចូលរួមជាមួយការជួប ការសន្ទនារវាងលោក រដ្ឋមន្ត្រីការបរទេសថៃ ជាមួយនឹង ប៉ុល ពត ទេបាទ។

**ស៖** ដូច្នេះ ខ្ញុំឮថា លោកមិនបានចូលរួមកិច្ចប្រជុំ ដែល ប៉ុល ពត បានជួបជាមួយគណៈប្រតិភូថៃ ហើយនិងរដ្ឋមន្ត្រីនោះទេ។ អ៊ីចឹង ខ្ញុំមិនសួរសំណួរទាក់ទងនឹងប្រធានបទនេះទេ។ នៅក្នុងទូរលេខនេះ មានការបញ្ជាក់ថា លោក គាត ឈន់ អនុលោមតាមក្រសួងការបរទេសបារាំងនោះគឺថា ជាអតីតឧបនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា។ តើត្រូវអ៊ីចឹងដែរឬទេ តាមក្រសួងការបរទេសបារាំង ដែលគេបញ្ជាក់នោះ?

**ប្រធានអង្គជំនុំ៖**

មិនបាច់ឆ្លើយតបទេ! សំណួរនេះមិនពាក់ព័ន្ធទេ មិនមានប្រយោជន៍អ្វីក្នុងការរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្តីនេះទេ។

[១០:០៣:០៦]

**លោក ហ្សាស្តើ ប៉ោ៖**

សូមអរគុណលោកប្រធាន។ ដើម្បីកំណត់ត្រាតុលាការ ខ្ញុំសូមកត់សម្គាល់ថា យើងបានព្យាយាមបង្ហាញភស្តុតាង អំពីប្រវត្តិសាស្ត្រ នៃរណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋារួបរួមជាតិកម្ពុជា។ នេះហើយជាគោលបំណង ដែលខ្ញុំបានធ្វើហើយ ហើយមេធាវីការពារលោក ខៀវ សំផន បានព្យាយាម ហើយតុលាការទំនងជាមិនអនុញ្ញាតឲ្យយើងសួរពីផ្នែកនេះ។ អ៊ីចឹង ខ្ញុំនឹងបន្តទៅផ្នែកផ្សេង ដោយសារមានការជំទាស់ផងដែរ។

**សួរដោយលោក ហ្សាស្តើ ប៉ោ៖**

**ស៖** លោក សួង ស៊ីគឿន នៅមន្ទីរប-១ តើមានការិយាល័យមួយ ឬក៏ផ្នែកមួយដែលហៅថាគណៈដឹកនាំរួមដែរឬទេ?

**លោក សួង ស៊ីគឿន៖**

**ឆ៖** ខ្ញុំមិនដែលឮទេបាទ ព្រោះខាងផ្នែកខ្ញុំអ្នកដឹកនាំ គឺកន្លែងខ្ញុំគឺអ្នកដឹកនាំ គឺលោក មានតែលោក អៀង សារី ម្នាក់ហ្នឹង។

**សះ** បាទ អរគុណ។ ខ្ញុំមិនសួរសំណួរអ្វីទៀត ទាក់ទងនឹងប្រធានបទនេះទេ។ លោក សួង ស៊ីគឿន ឥឡូវនិយាយអំពីរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា និងរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ឯកសារ D22/185.5 បារាំង ERN 00387616 រហូតទៅដល់ 617។ ឯកសារហ្នឹងមានតែជាភាសាបារាំងទេ ហើយជាឧបសម្ព័ន្ធទៅនឹងពាក្យសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី ហើយខ្ញុំសូមអនុញ្ញាតពីតុលាការដើម្បីបង្ហាញលើអេក្រង់ផងដែរ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារ ជាក្រដាសពីលោកមេធាវីយកជូនសាក្សីពិនិត្យ!

*(មន្ត្រីតុលាការយកឯកសារជូនសាក្សី)*

[១០:០៥:៥១]

**លោក ហ្សាស្តើ ប៉ោ៖**

នៅពេលដែលលោកសាក្សីកំពុងតែអាននោះ ខ្ញុំចង់សួរសំណួរអំពី ERN 00387617--

**ប្រធានអង្គជំនុំ៖**

លោកមេធាវីគប្បីសួរសាក្សី ថាតើឯកសារនេះ សាក្សីធ្លាប់បានឃើញ បានអានពីមុនមកដែរឬទេ? លោកបង្ហាញអំពីការដែលធ្លាប់បានឃើញ បានអាន ជាមុនសិន នោះទើបអាចជូនទៅសាក្សីពិនិត្យមើលឯកសារ ហើយដេញដោលបាន។ បើសាក្សីមិនធ្លាប់ស្គាល់ មិនធ្លាប់ឃើញឯកសារនេះទេ ធ្វើដូចករណីអម្បាញ់មិញ ឲ្យដកមកវិញ ហើយនិងដកចេញពីអេក្រង់កុំព្យូទ័រ។

**លោក ហ្សាស្តើ ប៉ោ៖**

លោកប្រធាន តាមពិតខ្ញុំនឹងគោរពការសម្រេចនេះ ប៉ុន្តែលោកដូចជាបានច្រានចោលសេចក្តីសម្រេចពីមុនដែលថា គេបាន -- យើងបានប្រើវិធីនេះទាក់ទងទៅនឹងនីតិវិធី គឺថាទាក់ទងនឹងកម្មវត្ថុឯកសារហ្នឹងគាត់អាចអាន ហើយគាត់អាចមើល ហើយបើអង្គជំនុំជម្រះប្រកាន់ជំហរនេះ វាផ្ទុយទៅនឹងគំនិតខាងដើម។ ដូច្នេះ ខ្ញុំនឹងគោរពទៅតាមសេចក្តីសម្រេចថ្មី ប៉ុន្តែដើម្បីឲ្យសមស្របនៅក្នុងការប្តូរនីតិវិធី ហើយខ្ញុំចង់បន្តទៅតាមវិធីណាមួយដែលតុលាការបង្គាប់បាទ។

[១០:០៧:២៧]

**ប្រធានអង្គជំនុំ៖**

លោករកមើលឯកសារណាដែលពីមុនមកដែលឲ្យចាត់ការដូច្នេះ ហើយមានការផ្ទុយនេះបង្ហាញយើងឥឡូវនេះ ដើម្បីយើងសម្រេច!

**លោក ហ្សាស្តើ ប៉ោ៖**

យើងខ្ញុំនឹងបង្ហាញបែបនោះ ប៉ុន្តែជាថ្មីម្តងទៀត--

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះសម្រេចសិន រក១ សិនមក ពីព្រោះឥឡូវលោកបានលើកហើយ ដើម្បីឲ្យយើងឃើញយើងសម្រេចករណីនេះតែម្តងឲ្យបានត្រឹមត្រូវ។

**លោក ហ្សាស្តើ ប៉ោ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនឹងធ្វើសំណើជាលាយលក្ខណ៍អក្សរ នេះជាវិធីមួយដែលលោកប្រធានចង់ឲ្យយើងខ្ញុំធ្វើ។ ឥឡូវនេះ ខ្ញុំនឹងសួរសំណួរសាក្សី--

[១០:០៨:១៥]

**ប្រធានអង្គជំនុំ៖**

យើងមិនឲ្យធ្វើទេ! អំមិញលោកថា មាននីតិវិធីចាស់ ដែលធ្លាប់បានធ្វើផ្ទុយពីនេះ។ អ៊ីចឹងសូមលោកផ្តល់នូវភស្តុតាងជាឯកសារ ដើម្បីយើងពិនិត្យ ពីព្រោះបញ្ហាវាច្រើន យើងបានសម្រេចរួចហើយ ប៉ុន្តែអម្បាញ់មិញនេះ គឺមានការជំទាស់។ យើងបានសម្រេចរួចហើយដែលលក្ខខណ្ឌដូចគ្នានេះ គឺការបង្ហាញឯកសារទៅលើសាក្សី ហើយសាក្សីមិនដែលឃើញឯកសារនោះ គឺមិនអនុញ្ញាតឲ្យសាក្សីមើលឯកសារនោះ ហើយសួរដេញដោលនោះទេ គឺដកឯកសារចេញ។ ចំពោះការដកឯកសារស្រង់ខ្លឹមសារនៃឯកសារនោះ សួរដេញដោលសាក្សី គឺជានីតិវិធីមួយទៀត ដែលអនុវត្តជាទូទៅកន្លងមកហើយ។

មានទេ? មានឯកសារទេ? ព្រោះអំមិញថា នីតិវិធីដែលយើងបានអនុវត្តពីមុនមកវាផ្ទុយពីនេះ។ លោក សួង ស៊ីគឿន តើលោកដែលឃើញឯកសារនេះពីមុនមកដែរឬទេ?

**លោក សួង ស៊ីគឿន៖**

**ឆ៖** ខ្ញុំមិនដែលបានឃើញឯកសារនេះទេបាទ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការដកឯកសារហ្នឹងចេញពីសាក្សី ហើយនិងបុគ្គលិកជំនួយការដកឯកសារ

ចេញពីអេក្រង់កុំព្យូទ័រ!

លោកមេធាវីអាចតាំងសំណួរទៅលើខ្លឹមសារ ដោយមិនអនុញ្ញាតឲ្យ *ខ្ញូត* ដោយដកស្រង់ទាំងស្រុងនូវឯកសារនេះមកសួរដេញដោលសាក្សីទេ!

**លោក ហ្វាស្តេី ប៉ោះ**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ហ្វាស្តេី ប៉ោះ**

**ស៖** នៅក្នុងឯកសារនេះ នៅក្នុងចំណងជើងទី៣ ដែលមានចំណងជើងថា ជាភាសាបារាំង "ហ្គូវើណឺម៉ង់ ប៉ុល ពត" ថ្ងៃទី៦ មករា ឆ្នាំ១៩៧៩ ដែលមានសរសេរដូចខាងក្រោមនេះ "នាយករដ្ឋមន្ត្រី ប៉ុល ពត--

[១០:១០:២៩]

(អានជាភាសាបារាំង៖) "ឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីការបរទេស អៀង សារី។ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការពារជាតិ សុន សេន។ រដ្ឋមន្ត្រីអមគណៈរដ្ឋមន្ត្រី គាត ឈន់។ រដ្ឋមន្ត្រីប្រជាសាស្ត្រ ជួន មុំ។ រដ្ឋមន្ត្រីក្រសួងសុខាភិបាល ជួន ជឿន។ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ខៀវ ធីរិទ្ធ។ រដ្ឋមន្ត្រីវប្បធម៌អប់រំ និងសិក្សាធិការ យុន យ៉ាត"។ (បញ្ចប់ការអានជាភាសាបារាំង)

[១០:១១:១៥]

ចប់សេចក្តីដកស្រង់។ លោក សួង ស៊ីគឿន ផ្អែកលើការដឹងរបស់លោកអំពីកម្ពុជាប្រជាធិបតេយ្យ តើនេះជាសមត្ថភាពរបស់រដ្ឋាភិបាល ប៉ុល ពត នៅថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ឬទេ?

**លោក សួង ស៊ីគឿន៖**

**ឆ៖** សូមបញ្ជាក់កាលបរិច្ឆេទបន្តិចបាទ ខ្ញុំស្តាប់ ដូចអត់ច្បាស់ម៉េច។

**ស៖** គឺថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ គឺពេលប្រហាក់ប្រហែលគ្នានឹងពេលដែលវៀតណាមមកដណ្តើមអំណាចនៅកម្ពុជានោះឯង?

**ឆ៖** ខ្ញុំឃើញមានឈ្មោះពីរ អត់មានទាក់ទងអីរដ្ឋាភិបាល ប៉ុល ពត ទេ។ ឈ្មោះ លោក គាត ឈន់ ហើយឈ្មោះលោក ជួន មុំ។ ព្រោះពេលហ្នឹងក្នុងរយៈពេលហ្នឹង លោក គាត ឈន់ នៅជាមួយខ្ញុំ ដូច្នោះមានឋានៈប្រហែលនឹងខ្ញុំដែរបាទ។ អត់ជារដ្ឋមន្ត្រីអីទេបាទ។ ខ្ញុំមិនដឹងលោកមេធាវីបានឯកសារនេះមកពីណាទេបាទ។

**សៈ** សូមអរគុណលោកដែលលោកបានឆ្លើយ។ ហើយនេះជាឧបសម្ព័ន្ធរបស់ពាក្យសុំដើមបណ្តឹងរដ្ឋប្បវេណី ហើយដើម្បីកំណត់ត្រាតុលាការ ខ្ញុំនឹងកត់សម្គាល់ថា នៅក្នុងឯកសារដដែលនេះ បានសរសេរជាបារាំង 0037161 (ស៊ីក)។ បាទ ឯកសារហ្នឹង គឺថានៅថ្ងៃទី០៣ ឆ្នាំ១៩៨៣ គឺថា នាយករដ្ឋមន្ត្រី--

[១០:១៣:៣១]

(អានជាភាសាបារាំង៖) "រដ្ឋមន្ត្រី -- ឧបនាយករដ្ឋមន្ត្រី មន្ត្រីការពារជាតិ ខៀវ សំផន។ រដ្ឋមន្ត្រីប្រតិភូ លោក គាត ឈន់"។ (បញ្ចប់ការអានជាភាសាបារាំង)

គឺជាការបញ្ជាក់ទី៣ នៅលើឯកសារ ខ្ញុំមិនបង្ហាញឯកសារជូនលោកទេ ហើយខ្ញុំមិនសួរសំណួរទាក់ទងលម្អិតនឹងឯកសារនេះទេ។ ឯកសារដូចតទៅនេះ ខ្ញុំនឹងបង្ហាញជូនលោក គឺៗឯកសារដែលមានលេខ E3/1435។ អង់គ្លេស ERN 00017976, បារាំង ERN 00597811, ហើយខ្មែរ ERN គឺ 00595262។

**លោក ហ្វ្រាស្តេ ប៉ៅ៖**

សូមអនុញ្ញាតពីលោកប្រធាន ដើម្បីបង្ហាញឯកសារទី១ នៅលើអេក្រង់ គឺសេចក្តីប្រកាសរបស់សមាជនៅខែធ្នូ ថ្ងៃទី១៨ ឆ្នាំ១៩៧៩។ ខ្ញុំនឹងសូមអនុញ្ញាតបង្ហាញឯកសារលើក្រដាសទៅសាក្សីផងដែរបាទ។

[១០:១៥:០១]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីមេធាវីជូនសាក្សីពិនិត្យ!

**សួរដោយលោក ហ្វ្រាស្តេ ប៉ៅ៖**

**សៈ** សំណួរទី១ របស់ខ្ញុំ តើលោកបានឃើញឯកសារនេះពីមុនមកដែរឬទេ? លោក ស្វួង ស៊ីគឿន តើលោកពិនិត្យមើលឯកសារជាភាសាខ្មែរ ជាភាសាអង់គ្លេសផងដែរ ហើយនិងប្រាប់ខ្ញុំថា តើលោកធ្លាប់បានឃើញទេ ឯកសារហ្នឹងពីមុនមកនោះ?

**លោក ស្វួង ស៊ីគឿន៖**

**ឆៈ** ខ្ញុំមិនដែលបានឃើញទេបាទ។

[១០:១៦:០៦]

*(ចៅក្រមពិភាក្សាគ្នា)*

[១០:១៦:២៣]

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការដកឯកសារពីសាក្សី ហើយនិងឲ្យបុគ្គលិកជំនួយការដកឯកសារនេះចេញពីអេក្រង់កុំព្យូទ័រ!

**សួរដោយលោក ហ្សាស្តេ ប៉ោ៖**

**ស៖** លោកសាក្សី ឯកសារដែលខ្ញុំបានបង្ហាញលោកអម្បាញ់មិញនេះ គឺជាសេចក្តីថ្លែងការណ៍របស់សមាជរបស់គណៈអចិន្ត្រៃយ៍នៃតំណាង -- សភាតំណាងកម្ពុជាប្រជាធិបតេយ្យ -- រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ កងកម្លាំងប្រដាប់អាវុធ ហើយនិងតំណាងក្រសួងមន្ទីរផ្សេងៗរបស់រដ្ឋាភិបាល ហើយស្ថិតនៅក្នុងបញ្ជីឯកសារ ដែលសហព្រះរាជអាជ្ញាបានដាក់ជូនតុលាការ ហើយមាននៅក្នុងទំព័រ ១២ នៃអត្ថបទភាសាអង់គ្លេស ដែលមានអង់គ្លេស ERN 00017988, ហើយនិងខ្មែរ ERN 00595274, ហើយយើងមិនមានភាសា អត្ថបទភាសាបារាំងទេ។

នៅទំព័រទី១២ នៅក្រោមចំណងជើងលេខ៣ និយាយអំពីស្ថាប័ននីតិប្រតិបត្តិ ដែលនិយាយថា សូមដកស្រង់ "នៅពេលក្នុងនោះ គឺសមាជបានសម្រេចជាឯកច្ឆន្ទដើម្បីកែលម្អសមាសភាពរបស់កម្ពុជាប្រជាធិបតេយ្យដូចខាងក្រោមនេះ៖ នាយករដ្ឋមន្ត្រី ខៀវ សំផន, អនុរដ្ឋមន្ត្រីទទួលបន្ទុកការបរទេស លោក អៀង សារី, អនុឧបនាយករដ្ឋមន្ត្រីលោក សុន សេន ទទួលការពារជាតិ, គឺថាក្រសួងហិរញ្ញវត្ថុសេដ្ឋកិច្ច ជួន ជឿន។ បាទ ជួន ជឿន ទទួលបន្ទុកខាងសុខាភិបាល, អៀង ធីរិទ្ធ ក្រសួងកិច្ចការសង្គមកិច្ច, យុន យ៉ាត ទទួលបន្ទុកគឺថា ការអប់រំសិក្សាធិការ, លោក គាត ឈន់ ប្រធានគណៈកម្មាធិការវិទ្យាសាស្ត្រ, លោក ជួន មុំ, ទូច រិន, សគឹម ល្មុត ទទួលបន្ទុកខាងភស្តុភារ ហើយប្រៃសណីយ៍ លោក ជន់ ហៃ (ស៊ីក)។

[១០:១៩:២៨]

លោក សួង ស៊ីគឿន លោកបានធ្វើសក្ខីកម្មរួចហើយថា បន្ទាប់ពីខែមករា ឆ្នាំ១៩៧៩ លោកនៅជាមួយមេដឹកនាំកម្ពុជាប្រជាធិបតេយ្យ។ តាមអ្វីដែលលោកដឹង ផ្អែកលើការដឹងរបស់លោក ថាតើទាំងនេះជាសេចក្តីបញ្ជាក់អំពីសមាសភាពរបស់មេដឹកនាំកម្ពុជាប្រជាធិបតេយ្យនៅខែធ្នូ ឆ្នាំ១៩៧៩ ហ្នឹង

ដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយតបនឹងសំណួរទេ! សំណួរនេះមិនពាក់ព័ន្ធជាមួយនឹងអង្គហេតុ ដែលចោទប្រកាន់ទេ។

**លោក ហ្សាស្តេី ប៉ោ៖**

លោកប្រធាន សហព្រះរាជអាជ្ញាបានប្រើឯកសារនេះដើម្បីសួរសំណួរ ហើយជាសំខាន់បំផុតគឺបានបញ្ជាក់នៅក្នុងដីកាដំណោះស្រាយដោយផ្ទាល់ គឺថាទាក់ទងទៅនឹងកូនក្តីរបស់ខ្ញុំលោក នួន ជា គឺថា ១៣៨១ នៃដីកាដំណោះស្រាយនិយាយអំពីឯកសារនេះ គឺជាឯកសារដែលប្រឆាំងនឹងកូនក្តីរបស់ខ្ញុំ។ ហើយខ្ញុំសូមលោកប្រធានពិនិត្យមើលបញ្ហានេះ ហើយនិងពិនិត្យសេចក្តីសម្រេចនេះឡើងវិញ គឺមានឯកសារ ដីកាដំណោះស្រាយបញ្ជាក់ប្រាំមួយកន្លែងទៀត ដែលមានកាលបរិច្ឆេទក្រោយខែមករា ឆ្នាំ១៩៧៩ ក៏ជាឯកសារដែលពាក់ព័ន្ធច្បាស់លាស់ដែរ។

[១០:២១:០២]

**ប្រធានអង្គជំនុំ៖**

អញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

សូមអរគុណលោកប្រធាន។ ជំហររបស់យើងគឺថា ឯកសារនេះមានភាពពាក់ព័ន្ធប្រសិនបើវាសំដៅទៅលើកថាខណ្ឌនៃដីកាដំណោះស្រាយ ទាក់ទិនទៅនឹងអត្តចរិតរបស់ជនជាប់ចោទនីមួយៗ ដូចជា ខៀវ សំផន, អៀង សារី, នួន ជា ហើយក្នុងករណីដែលវាពាក់ព័ន្ធទៅនឹងអត្តចរិតរបស់បុគ្គលផ្សេងទៀត នៃរបបខ្មែរក្រហម ដែលកាន់មុខតំណែងជារដ្ឋមន្ត្រីនោះ វាមិនពាក់ព័ន្ធទេ វាហាក់ដូចវាចេញអំពីវិសាលភាពនៃការជំនុំជម្រះរឿងក្តីនេះហើយ។ ដូច្នេះប្រសិនបើសួរសំណួរទៅលើឯកសារនេះ សូមកម្រិតត្រឹមតែតួនាទីរបស់ជនជាប់ចោទនីមួយៗ ក្រោយខែមករា ឆ្នាំ១៩៧៩។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសម្រេចរួចហើយ ដូច្នេះមិនសម្រេចលើកទី២ នូវបញ្ហាដដែលទេ។

[១០:២២:២១]

**លោក ហ្សាស្តេ ប៉ោះ**

ខ្ញុំយល់សេចក្តីសម្រេចនេះ គឺថាឯកសារនេះគឺអាចប្រើសម្រាប់ដាក់បន្ទុក ប៉ុន្តែមិនឲ្យមេធាវីខាងយើងខ្ញុំសួរសាក្សីដើម្បីដោះបន្ទុកនោះទេ។ តើលោកគិតបែបនេះ ឬយ៉ាងដូចម្តេចបាទ?

**ប្រធានអង្គជំនុំ៖**

អំមិញលោកបានស្តាប់នូវការអះអាង របស់តំណាងសហព្រះរាជអាជ្ញារួចហើយ ឯកសារដែលយោងភ្ជាប់នេះគឺ ពាក់ព័ន្ធទៅនឹងអត្តចរិតរបស់ជនជាប់ចោទប៉ុណ្ណោះ ដែលអាចតាំងសំណួរសួរបាន។ សំណួរអម្បាញ់លោកមិនសួរពាក់ព័ន្ធជាមួយអត្តចរិតជនជាប់ចោទទេ គឺសួរពាក់ព័ន្ធជាមួយនឹងបុគ្គលផ្សេងទៀត ដែលមិនមានពាក់ព័ន្ធនៅក្នុងការដឹកាដំណោះស្រាយ ដែលមានខ្លឹមសារចោទប្រកាន់ ឬក៏ដោះបន្ទុកនៅក្នុងរឿងក្តីនេះទេ។

យើងមិនហាមឃាត់លោកទេ ប៉ុន្តែសំណួររបស់លោកឃើញថា ចេញឆ្ងាយពីវិសាលភាពនៃដីកាដំណោះស្រាយ។ សំណួររបស់លោកតាំងពីដើមទីរហូតដល់ពេលនេះ គឺពាក់ព័ន្ធតែមួយបុគ្គលម្នាក់ ឬពីរនាក់តែប៉ុណ្ណោះ ដែលក្រៅនៅក្នុងសំណុំរឿងនេះ។

[១០:២៣:៣៧]

**លោក ហ្សាស្តេ ប៉ោះ**

សូមអរគុណលោកប្រធាន។ ខ្ញុំគោរពសេចក្តីសម្រេចនេះ។ ដើម្បីកំណត់ត្រាតុលាការខ្ញុំសូមកត់សម្គាល់ថា ឯកសារនេះគឺសហព្រះរាជអាជ្ញាបានប្រើសួរទៅសាក្សី ទៅសាក្សី សគឹម ល្មុត គឺទាក់ទងទៅនឹងលោក សគឹម ល្មុត ខ្លួនឯងនោះឯង។ ហើយខ្ញុំនឹងតទៅមុខទៀត ទៅនឹងប្រធានបទបន្ទាប់។

**សួរដោយលោក ហ្សាស្តេ ប៉ោះ**

**ស៖** លោកសាក្សី នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ តើលោកដឹង ហោ ណាំហុង ដែរឬទេ? លោកស្គាល់លោក ហោ ណាំហុង ដែរឬទេ?

**លោក សួង ស៊ីគឿន៖**

**ឆ៖** បាទ ខ្ញុំបានស្គាល់គាត់ កាលគាត់ធ្វើជាលេខាអមទី -- អមស្ថានទូតកម្ពុជានៅទីក្រុងប៉ារីសមុនរដ្ឋប្រហារឆ្នាំ១៩៧០ បាទ។

**ស៖** នៅពេលដែលលោកនៅទីក្រុងភ្នំពេញ ចាប់ពីឆ្នាំ១៩៧៥ ដល់១៩៧៩ តើលោកបានជួបលោក ហោ ណាំហុង ដែរឬទេ ក្នុងសម័យនោះ?

**ឆ៖** ខ្ញុំមិនដែលជួបគាត់ទេបាទ។

[១០:២៥:១៧]

**ស៖** តើលោកដឹងដែរឬទេ ថាតើនៅពេលណាមួយ គាត់ជា -- ដែលថា អគ្គរដ្ឋទូតនៅប្រទេសគុយបា នោះ?

**ឆ៖** បាទ ខ្ញុំដឹងថា គាត់ធ្វើជាឯកអគ្គរដ្ឋទូត របស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ប្រចាំប្រទេសគុយបា គាត់ជំនួសលោក តូច ខាំឌឿន បាទ។ ប៉ុន្តែនេះគឺថា មុនឆ្នាំ១៩៧៥ គឺនៅក្នុងក្របខ័ណ្ឌរណសិរ្សរួបរួមជាតិកម្ពុជា ដែលមានសម្តេច នរោត្តម ព្រះសីហនុ ជាប្រធានបាទ។

**ស៖** តើលោកដឹងឬទេ នៅពេលណាដែលលោក ហោ ណាំហុង ត្រឡប់មកប្រទេសកម្ពុជាវិញនោះ? បាទ គឺក្រោយឆ្នាំ១៩៧៥។

**ឆ៖** ខ្ញុំមិនបានដឹងទេបាទ។

**ស៖** ខ្ញុំចង់បង្ហាញជូនលោកនូវឯកសារមួយ ដែលឯកសារ D366/7.1.564 អង់គ្លេស ERN 00078096, ខ្មែរ ERN 00636001, ហើយនិងបារាំង ERN 00630981។

**លោក ហ្សាស្តេ ប៉ោ៖**

ខ្ញុំមានឯកសារលើក្រដាសជូនលោកសាក្សី ហើយនិងសូមការអនុញ្ញាតដើម្បីបង្ហាញលើអេក្រង់ផងដែរបាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីសាក្សី អ៎ ពីមេធាវីយកជូនសាក្សីពិនិត្យ! ហើយនិងអាច អ៎ បង្ហាញឯកសារនៅលើអេក្រង់កុំព្យូទ័រ។

*(មន្ត្រីតុលាការយកឯកសារជូនសាក្សី)*

[១០:២៨:០៨]

**សួរដោយលោក ហ្សាស្តេ ប៉ោ៖**

**ស៖** លោកប្រធាន សំណួរទី១ របស់ខ្ញុំ គឺទាក់ទង តើលោកសាក្សីលោកបានឃើញឯកសារនេះពីមុនដែរឬទេ? ហើយនិងចាំស្តាប់ចម្លើយរបស់គាត់បាទ។

**លោក សួង ស៊ីគឿន៖**

**ឆ៖** ខ្ញុំមិនដែលបានឃើញឯកសារនេះពីមុន។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការដកឯកសារ ចេញពីសាក្សី ហើយនិងឲ្យដកចេញពីកុំព្យូទ័រ!

លោកមេធាវីអាចបង្ហាញបានទេ តើឯកសារនេះបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ ហើយឬនៅ?

**លោក ហ្សាស្តេី ប៉ោះ៖**

លោកប្រធាន នៅក្នុងបញ្ជីរបស់ការិយាល័យសហព្រះរាជអាជ្ញា គឺ D109/4.12 នៅលេខ ២៩៩ ជាលេខរៀងបាទ។

[១០:២៩:១៣]

**ប្រធានអង្គជំនុំ៖**

តំណាងសហព្រះរាជអាជ្ញាតើត្រឹមត្រូវដែរទេ?

**លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទ លោកប្រធាន។ តើលោកស្តាប់ខ្ញុំឮទេ? ខ្ញុំមិនមានបញ្ជីឯកសារនៅក្នុងដៃទេ ប៉ុន្តែខ្ញុំគិតថា ឯកសារនេះវាស្ថិតនៅក្នុងបញ្ជីឯកសារ ដែលបានដាក់កាលពីខែមេសា ឆ្នាំមុន។ ដូច្នេះវាជាឯកសារដែលមាននៅក្នុងបញ្ជីរបស់ការិយាល័យសហព្រះរាជអាជ្ញា លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ហើយសូមជម្រាបជូនលោកមេធាវីអន្តរជាតិការពារក្តីលោក នួន ជា ថា អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យលោកដកស្រង់បែប ខ្លួត ហ្នឹងយកមកសួរសាក្សីទេ។ លោកអាចយកខ្លឹមសារនៃឯកសារនោះមកសួរដេញដោលសាក្សីបាន។

**លោក ហ្សាស្តេី ប៉ោះ៖**

សូមអរគុណលោកប្រធាន។ នៅទីនេះ គឺខ្ញុំសំដៅទៅលើខ្លឹមសារនៃយុទ្ធសាស្ត្ររបស់តុលាការនេះកន្លងមកដែលបានធ្វើ។ ឯកសារនៅពេលនេះ គឺបាន -- មានការបោះត្រា ហើយឯកសារនេះក៏បានដកចេញពីបណ្ណសាររបស់វៀតណាមផងដែរ ហើយក៏បានដាក់ជូនដោយខាងសហព្រះរាជអាជ្ញា វាពាក់ព័ន្ធជាមួយនឹងការងាររបស់លោក ហោ ណាំហុង ពោលគឺជាសេចក្តីថ្លែងរបស់លោក ហោ ណាំហុង ហើយក៏វាពាក់ព័ន្ធជាមួយនឹងដំណាក់កាលពេលដែលគាត់ត្រឡប់មកវិញពីប្រទេសគុយបា។

[១០:៣១:៣៤]

ហើយខ្ញុំអាចធ្វើការសម្រួលឃ្លាហ្នឹងឡើងវិញ ដូចដែលតាមការណែនាំរបស់លោកប្រធាន គឺថា គាត់បានចូលរួមនៅក្នុងវគ្គកសាង ឬក៏រៀនសូត្រឡើងវិញពេលដែលគាត់ត្រឡប់មកវិញ ហើយការងារនេះគឺដឹកនាំដោយលោក ជួន ប្រសិទ្ធិ ហើយនិងដោយលោក គាត ឈន់។

**ប្រធានអង្គជំនុំ៖**

លោកមានសំណួរអីសួរដល់សាក្សីរូបនេះទេ? អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅលោកដើម្បីតាំងសំណួរដេញដោលចំពោះសាក្សី សួង ស៊ីគឿន។

**លោក ហ្សាស្តេ ប៉ោ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនទាន់បានសួរនូវសំណួរខ្ញុំនៅឡើយ ការពិតសំណួររបស់ខ្ញុំគឺពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធការងារនៅប-១ ហើយនិងការបែងចែកនៃទំនួលខុសត្រូវនៅទីនោះ។

[១០:៣២:៣៧]

**សួរដោយលោក ហ្សាស្តេ ប៉ោ៖**

**ស៖** ផ្អែកទៅតាមពិសោធន៍របស់លោកនៅមន្ទីរ ប-១ នោះ លោក សួង ស៊ីគឿន ថាតើវាទំនងជាអាចទេ ដែលថាលោក ជួន ប្រាសិទ្ធ ហើយនិងលោក គាត ឈន់ គាត់ជាអ្នកដឹកនាំក្នុងការធ្វើវគ្គរៀនសូត្រដែលពេលនោះ លោក ហោ ណាំហុង ក៏បានចូលរួមដែរនោះ?

**លោក សួង ស៊ីគឿន៖**

**ឆ៖** ខ្ញុំមិនបានដឹងទេបាទ ព្រោះអានេះវានៅក្រៅក្របខ័ណ្ឌភារកិច្ចរបស់ខ្ញុំ។

**ស៖** បាទ លោក ជួន ប្រាសិទ្ធ ថាតើលោកអាចប្រាប់តុលាការបានទេ អំពីតួនាទីរបស់លោក ជួន ប្រាសិទ្ធ នៅក្នុងមន្ទីរប-១ នៅពេល -- អំឡុងពេលដែលលោកក៏មានវត្តមាននៅទីនោះដែរ?

**ឆ៖** លោក ជួន ប្រសិទ្ធិ ជាសមាជិកនៃផ្នែក១នយោបាយទូទៅរបស់ក្រសួងការបរទេសដែលមានលោក អៀង សារី ជាប្រធាន។ អាហ្នឹងដូចនាយកដ្ឋាន នយោបាយទូទៅ *ដេប៉ាត់តឺម៉ង់ អប្ញ ដឺ ប៉ូលីទិច ហ្សេណឺរ៉ាល់*។

[១០:៣៤:១៨]

**ស៖** លោកបាននិយាយថា ជានាយកដ្ឋាននយោបាយទូទៅ ថាតើលោកអាចធ្វើការពន្យល់ឲ្យលម្អិតបន្ថែមទៀតទេ អំពីការងាររាល់ថ្ងៃ ប្រចាំថ្ងៃរបស់គាត់ហ្នឹង តើមានអ្វីខ្លះ?

**ឆ៖** គាត់មែនទែនទៅ គឺថាការងាររបស់គាត់ច្បាស់លាស់ គឺខ្ញុំមិនដឹងទេបាទ។ ឃើញតែគាត់

អង្គុយសរសេរ ហើយខ្ញុំក៏មិនសាកសួរអីគាត់ដែរ ព្រោះអារឿងហ្នឹងគឺថា មិនមែនជាភារកិច្ចរបស់ខ្ញុំ ហើយមិនមែនអីទាក់ទងជាមួយខ្ញុំ ខ្ញុំក៏មិនបានសួរអីគាត់ដែរ។ តាមមើលទៅគាត់សរសេររបាយការណ៍ ឬសរសេរសុន្ទរកថាអីឱ្យអ្នកដឹកនាំអាចអ៊ីចឹងបាទ ប៉ុន្តែសរសេរច្បាស់លាស់ ខ្ញុំមិនដឹងទេ។ បាទ ហើយគាត់ អ្វីដែលខ្ញុំបានដឹង គឺថាគាត់ជាអ្នកបកប្រែខាងភាសាអង់គ្លេស ជូនលោក ប៉ុល ពត។

**ស៖** អ៊ីចឹង តើលោកមានដឹងទេ ថាតើលោក ជួន ប្រសិទ្ធិ ហ្នឹង គាត់បានដឹកនាំវគ្គរៀនសូត្រដូចខ្ញុំដែលបានរៀបរាប់អម្បាញ់មិញនេះទេ? ឬក៏លោកអត់ដឹងពីបញ្ហានេះទេ?

**ឆ៖** ខ្ញុំមិនបានដឹងទេ បាទ។

[១០:៣៥:៤៩]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះ ដល់ពេលសមល្មមសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក ២០នាទី ចាប់ពីពេលនេះទៅ រហូតដល់ម៉ោងដប់មួយ ខ្វះប្រាំនាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយមន្ត្រីរដ្ឋតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនូវបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សី និងមេធាវីប្រឹក្សារបស់គាត់ ហើយនិងឱ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញ នៅវេលាម៉ោងដប់មួយ ខ្វះប្រាំនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣៦ នាទី ដល់ម៉ោង ១១:០៦ នាទី)*

[១១:០៦:៣៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

**លោក ហ្សាស្តេី ប៉ៅ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ហ្សាស្តេី ប៉ៅ៖**

**ស៖** លោក សួង ស៊ីគឿន មុនពេលសម្រាកនេះ ខ្ញុំបានយោងទៅរកឯកសារមួយ E109/4.12 អ៊ំ សូមទោស! គឺៗនៅក្នុងបញ្ជីរបស់ការិយាល័យសហព្រះរាជអាជ្ញា គឺ D366/7.1.546។ ហើយខ្ញុំមិនដកស្រង់ខ្លឹមសារទាំងស្រុងពីឯកសារនេះទេ។ ដើម្បីគោលបំណងនេះ គឺលោកប្រធាន ខ្ញុំនឹងនិយាយអំពីទំព័រអង់គ្លេស ERN 00078099, ខ្មែរ ERN 00636007, ហើយបារាំង ERN 00630984។ នៅក្នុងផ្នែកឯកសារមួយនេះ គឺការសន្ទនាតាមទូរសព្ទរវាង ស្ទីវ ហេដឌ័រ ហើយនិង ជួន ប្រាសិទ្ធ គឺត្រូវបានសង្ខេបនៅកន្លែងនេះ ហើយតាមរយៈការសន្ទនានេះ ជួន ប្រាសិទ្ធ បានអះអាងថានៅក្នុងឆ្នាំ២០០១ ជាមួយការសន្ទនាទូរស័ព្ទជាមួយ ស្ទីវ ហេដឌ័រ ថា ហោ ណាំហុង គឺបានទទួលបន្ទុកការងារនៅបឹងត្របែក។ ហើយដើម្បីចៀសវាងការដកស្រង់ខ្លឹមសារដូចដែលខ្ញុំបាននិយាយនេះ សំណួរខ្ញុំ សួរទៅលោកសាក្សី លោក សួង ស៊ីគឿន តើ ជួន ប្រាសិទ្ធ ធ្លាប់និយាយអ្វីជាមួយលោកអំពីបឹងត្របែកនៅពេលដែលលោកបានធ្វើការនៅក្រសួងការបរទេស តើគាត់បាននិយាយអំពីតួនាទីរបស់លោក ហោ ណាំហុង ដែរឬទេ?

[១១:០៩:២០]

**លោក សួង ស៊ីគឿន៖**

**ឆ៖** ជួន ប្រាសិទ្ធ មិនដែលនិយាយប្រាប់ខ្ញុំអំពីបឹងត្របែក ឬអំពីតួនាទីរបស់លោក ហោ ណាំហុង ទេបាទ។

**ស៖** សូមអរគុណ។ លោកបាននិយាយកាលពីម្សិលមិញថា លោកបានស្តាប់នៅតែបន្តស្តាប់វិទ្យុ ដែលថា ប៉ុស្តិ៍មួយចំនួនលោកតែងតែស្តាប់នោះ។ តើលោកបានឮសេចក្តីប្រកាសនៅក្នុងប៉ុន្មានសប្តាហ៍ថ្មីៗនេះទេ ដោយរដ្ឋមន្ត្រីក្រសួងការបរទេសរបស់ ហោ ណាំហុង ទាក់ទងទៅនឹងបទពិសោធន៍របស់គាត់នៅបឹងត្របែកដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក ច័ន្ទ តារាស្មី៖**

សូមអរគុណលោកប្រធាន។ ខ្ញុំយល់ថា សំណួររបស់លោកមេធាវីការពារក្តីលោក នួន ជា ដូចជាមិនត្រូវនឹងប្រធានបទដែលយើងកំពុងពិភាក្សានៅពេលនេះទេ។ ព្រោះប្រធានបទយើងដែលនិយាយសំណុំរឿង០០២/១ នេះគឺក្នុងបរិបទមួយផ្សេងពីអ្វីដែលលោកកំពុងនិយាយ។ ហើយយើងសង្កេតឃើញមួយព្រឹកនេះ គឺគាត់និយាយតែទាក់ទងនឹងតួអង្គផ្សេង ដែលមិនចំទៅនឹងប្រធានបទទាល់តែសោះ។ ខ្ញុំស្នើសុំលោកប្រធាន ក៏ដូចជាលោកមេធាវីបង្វែរសំណួរនេះឲ្យចំប្រធានបទបាទ ដើម្បីកុំឲ្យខាតពេលវេលា និងមានប្រសិទ្ធភាពនៅក្នុងការដំណើរការសវនាការរបស់យើង។ សូមអរគុណបាទ។

[១១:១០:៤៧]

**លោក ហ្វាស្តេ ប៉ោ៖**

លោកប្រធាននេះជាសំណួរត្រង់ៗ គាត់ -- សាក្សីគាត់ជាប្រភពនៃព័ត៌មាន ហើយបើមិនដូច្នោះគឺថាអាចនឹងបំបាត់នូវព័ត៌មានដែលគាត់បានឮពីប្រភពផ្សេងៗទៀតហើយ។ ដូច្នេះហើយជាសំណួរនេះគឺត្រង់ៗ ហើយការសួរទាក់ទងទៅនឹងប្រភពចំណេះដឹងរបស់សាក្សីរូបនេះដែលគាត់ដឹង ដឹងពីណា? អំពីអ្វី?

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយតបទៅនឹងសំណួរនេះទេ។ សំណួរមិនពាក់ព័ន្ធជាមួយនឹងអង្គហេតុដែលចោទប្រកាន់ចំពោះជនជាប់ចោទទាំងបីរូប ដែលយើងកំពុងតែលើកយកមកធ្វើសវនាការទេ។

[១១:១១:៣៨]

**លោក ហ្វាស្តេ ប៉ោ៖**

សូមអរគុណលោកប្រធាន។

នៅក្នុងដីកាដំណោះស្រាយ កូនក្តីរបស់ខ្ញុំលោក នួន ជា គឺត្រូវបានបញ្ជាក់ថា ទាក់ទងដោយផ្ទាល់ជាមួយការងារ សកម្មភាពនៅបឹងត្របែក។ ហើយនេះជាការកត្តាសំខាន់ ដែលយើងខ្ញុំការពារ -- មេធាវីការពារដើម្បីបង្ហាញភស្តុតាងបញ្ជាក់អំពីបឹងត្របែកនេះ។

**សួរដោយលោក ហ្វាស្តេ ប៉ោ៖**

**ស៖** លោកសាក្សី តើលោកសាក្សីធ្លាប់បានដឹងអំពីមុខតំណែងរបស់លោក ហោ ណាំហុង ទាក់ទងអំពីតួនាទីរបស់គាត់នៅបឹងត្របែកដែរឬទេ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះ?

**លោក សួង ស៊ីគឿន៖**

**ឆ៖** ខ្ញុំមិនដែលបានដឹងទេបាទ។

[១១:១២:៣៩]

**ស៖** តើលោកក្នុងឱកាសណាមួយបានស្ដាប់វិទ្យុ ហើយបានឮថ្មីៗនេះអំពីអង្គហេតុ អំពីសាក្សីមួយចំនួនដែលមកបង្ហាញខ្លួននៅតុលាការនេះ។ លោក ភី ភួន ដែលមានឈ្មោះថា រ៉ចាម តុន ហើយគាត់បាននិយាយបដិសេធសក្ខីកម្មរបស់គាត់ ដែលនៅក្នុងសវនាការនេះគាត់ថា លោក ហោ ណាំហុង បានធ្វើជាប្រធាននៅបឹងត្របែក ប៉ុន្តែក្រោយមកគាត់បានដកសម្ដីគាត់ទៅវិញ។ តើលោកបានដឹងពីរឿងហ្នឹងទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ!

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំគិតថា សាក្សីនៅទីនេះដើម្បីនិយាយអំពីដែលលោកបានឃើញ បានឮនៅក្នុងរយៈពេលមួយច្បាស់លាស់ ហើយមិនមែនមកធ្វើអត្ថាធិប្បាយលើសាក្សី អ្វីដែលសាក្សីផ្សេងនិយាយនោះទេ។ នេះមិនមែនជាកម្មវត្ថុនៃការសួរសំណួរទៅសាក្សីនេះនោះទេ គឺថាលើរយៈពេលមុនឆ្នាំ១៩៧៥ ហើយនិង ៧៥-៧៩។ ក៏ប៉ុន្តែសំណួរចោទទៅលើការផ្សាយនៃកម្មវិធីផ្សាយវិទ្យុអីនោះ វាប្រាសចាកពីប្រធានបទរបស់យើងហើយ។

[១១:១៤:០៧]

**លោក ហ្វាស្តេ ប៉ោ៖**

ខ្ញុំសូមឆ្លើយតបដោយសង្ខេប។ នៅពេលដែលបុគ្គលណាម្នាក់ឮព័ត៌មានដំណាក់កាលក្រោយ គឺទាក់ទងទៅនឹងការងារ ឬក៏ព័ត៌មានដែលនិយាយអំពីបឹងត្របែកនៅសវនាការនេះ គឺវាទាក់ទងជាបញ្ហាពាក់ព័ន្ធសម្រាប់ឲ្យយើងសួរសាក្សីរូបនេះ។ ថាតើគាត់បានទទួលព័ត៌មាននេះដែរឬទេអត់? ដូច្នេះហើយបានយើងកោះអញ្ជើញគាត់មក។ នេះជាបញ្ហាពាក់ព័ន្ធក្នុងករណីនេះ ដែលខ្ញុំបញ្ជាក់ថា ភី ភួន បានគាត់ -- គាត់បានដកសម្ដីរបស់គាត់នៅក្នុងសារព័ត៌មាន ខេមបូឌា ដេលី ក្រោយពីគាត់បានមកធ្វើសក្ខីកម្ម។ ដូច្នេះហើយបានខ្ញុំសួរសាក្សីរូបនេះ ថាតើលោកបានដឹងអ្វីជាផ្ទាល់នៅក្នុងបរិបទនេះ? នេះ សំណួរនេះ

មិនមែនក្រៅប្រធានបទនោះទេ។

**ប្រធានអង្គជំនុំ៖**

សេចក្ដីជំទាស់ និងសំអាងហេតុ នៃសេចក្ដីជំទាស់របស់តំណាងសហព្រះរាជអាជ្ញា ត្រឹមត្រូវ។ សំណួរនេះមិនពាក់ព័ន្ធទេ សាក្សីមិនបាច់ឆ្លើយតបទៅនឹងសំណួរបែបនេះទេ!

**លោក ហ្សាស្តើ ប៉ោ៖**

សូមអរគុណលោកប្រធាន។ ដើម្បីកំណត់ត្រាតុលាការនោះ ខ្ញុំនឹងដាក់សំណើតាមវិធាន៣៥ បាទ។

**ប្រធានអង្គជំនុំ៖**

ឃើញលោកដាក់រួចហើយ។

តាំងសំណួរ! យើងបានផ្ដល់វេទិកាឲ្យលោកតាំងសំណួរដេញដោល ចំពោះសាក្សីពាក់ព័ន្ធនឹងអង្គហេតុទាំងឡាយ ដែលចោទប្រកាន់លើជនជាប់ចោទនៅក្នុងសំណុំរឿង០០២។

[១១:១៦:០៥]

**លោក ហ្សាស្តើ ប៉ោ៖**

សូមអរគុណលោកប្រធាន ខ្ញុំនឹងបន្តទៅមុខទៀត។

**សួរដោយលោក ហ្សាស្តើ ប៉ោ៖**

**ស៖** លោក សួង ស៊ីគឿន ដោយពិចារណាការចូលរួមរបស់គាត់ នៅក្នុងចលនាឆ្វេងនិយមនៅដើមឆ្នាំ១៩៦០ ដោយសារថាគាត់ជាលេខារបស់រណសិរ្សរួបរួមជាតិកម្ពុជា ចាប់ពីឆ្នាំ១៩៧១មក គឺថាហើយគាត់ជាឧបនាយករដ្ឋមន្ត្រីរបស់ហ្រ្គុងផងដែរ ហើយគាត់បានចូលរួមក្នុងការរៀបចំចាត់ចែងក្រសួងការបរទេស ហើយគាត់ជាជនស្និទ្ធ ហើយគាត់ជាមនុស្សដ៏សំខាន់របស់លោក អៀង សារី តាមសម្ដីរបស់គាត់នោះ ហើយដោយពិចារណាថា លោក ហោ ណាំហុង គឺថា ត្រូវគេចោទប្រកាន់ថាទទួលបន្ទុកនៅ -- ភារកិច្ចនៅបឹងត្របែក ហើយក៏មានការអះអាងថាគាត់ជារដ្ឋមន្ត្រីនៅក្នុងក្រុមរបស់ប៉ុល ពត ក្រោយពីឆ្នាំ១៩៧៥ មក គឺថាមានដីកាបញ្ជាក់ -- ដីកាដំណោះស្រាយក៏បញ្ជាក់ពីអង្គហេតុនេះដែរ។ តាមទស្សនៈអ្នកខាងក្រៅគេអាចយល់ថា លោក គាត ឈន់ ក៏អាចនឹងមានព័ត៌មានច្រើនអំពីប្រវត្តិនៃបក្សកុម្មុយនីស្តកម្ពុជា របបកម្ពុជាប្រជាធិបតេយ្យ ហើយនិងតួនាទីរបស់មេដឹកនាំជាន់ខ្ពស់របស់ខ្លួនដែរ។

[១១:១៧:២៨]

**ប្រធានអង្គជំនុំ៖**

លោកមេធាវី លោកមកតាំងសំណួរ ឬក៏លោកមកធ្វើអត្ថាធិប្បាយ?

លោកនេះ លោកយកវេទិកានេះមកធ្វើអត្ថាធិប្បាយ ឬក៏តាំងសំណួរ? យើងដូចបញ្ជាក់អំមិញ ហើយថា យើងផ្តល់វេទិកាទៅឲ្យលោកដើម្បីតាំងសំណួរដេញដោលចំពោះសាក្សី។ យើងមិនបណ្តោយឲ្យលោកធ្វើសេចក្តីអត្ថាធិប្បាយអ្វីទេ នៅក្នុងវេទិកាដែលយើងផ្តល់ឲ្យ គឺឱកាសតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ យើងបានប្រើពាក្យពេចន៍នេះត្រឹមត្រូវណាស់ ហើយជាញឹកញាប់ទៀតផង ដើម្បីជាការរំឭកការចងចាំរបស់ភាគីពាក់ព័ន្ធនៅក្នុងការតាំងសំណួរដេញដោលចំពោះគោលដៅដែលត្រូវសួរ។

**លោក ហ្សាស្តេ ប៉ៅ៖**

សូមអរគុណលោកប្រធាន។ ហើយខ្ញុំនឹងចូលដល់សំណួររបស់ខ្ញុំ។

[១១:១៨:២៥]

**សួរដោយលោក ហ្សាស្តេ ប៉ៅ៖**

**ស៖** លោក សួង ស៊ីគឿន លោកបានធ្វើការជាបន្តបន្ទាប់ជាមួយលោក គាត ឈន់ តើលោកអាចប្រាប់ខ្ញុំបានទេ ផ្អែកលើបទពិសោធន៍របស់លោកជាមួយគាត់នោះ ដែលធ្វើការជាច្រើនឆ្នាំនៅក្រសួងការបរទេស តើលោកអាចប្រាប់ខ្ញុំបានទេថាតើលោក គាត ឈន់ មានព័ត៌មានដែលទាក់ទងទៅនឹងរបបកម្ពុជាប្រជាធិបតេយ្យ ដែលមានអត្ថប្រយោជន៍ក្នុងការបង្ហាញការពិតចំពោះតុលាការនេះ ជាពិសេសទាក់ទងទៅនឹងកូនក្តីរបស់ខ្ញុំ លោក នួន ជា? ខ្ញុំមិនសុំឲ្យលោកនិយាយស្មាន ឬសន្និដ្ឋានទេ គឺផ្អែកលើបទពិសោធន៍របស់លោកដែលធ្វើការជាមួយលោក គាត ឈន់ ហើយនិងបទពិសោធន៍ផ្ទាល់នៅក្នុងកិច្ចការទាំងអស់នោះ?

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយតបទៅនឹងសំណួរនេះទេ! សំណួរហ្នឹងឥតពាក់ព័ន្ធទេ។ ឥតមានប្រយោជន៍អ្វីក្នុងការរួមវិភាគទានក្នុងការស្វែងរកការពិតទេ។

[១១:១៩:៣៦]

**លោក ហ្សាស្តេ ប៉ៅ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ហ្សាស្តេី ប៉ោ៖**

**ស៖** លោកសាក្សី លោកបាននិយាយចំពោះមុខតុលាការនេះ នៅក្នុងសក្ខីកម្មរបស់លោកហើយ នៅចំពោះមុខសហចៅក្រមស៊ើបអង្កេតថា លោកគឺមានតែអតីតខ្មែរក្រហម កម្មាភិបាលម្នាក់ ដែលនិយាយដោយស្មោះត្រង់ ដែលថាមិនគិតពីហានិភ័យដែលអាចកើតមានឡើង។ តើនេះជាចំណុចសំខាន់ថាតើបញ្ហាជនផ្សេងទៀត ដែលបដិសេធមិនព្រមនិយាយតុលាការនេះ តើមូលហេតុអ្វី? តើបញ្ហាជនណាខ្លះ ដែលថា ពួកគាត់ដែលអាចនឹងមានសក្ខីកម្មល្អបំផុតជូនតុលាការ ហើយអ្នកណាខ្លះ ដែលលោកគិតថា អ្នកផ្សេងទៀតមិនព្រមនិយាយដូចលោក ដែលលោកបានប្រាប់ទៅចៅក្រមអង្កេតនោះ?

[១១:២០:២៨]

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយតបនឹងសំណួរនេះទេ! អង្គជំនុំជម្រះមិនត្រូវការសម្តាប់ចម្លើយតបរបស់លោកទៅនឹងសំណួរនេះទេ។

**សួរដោយលោក ហ្សាស្តេី ប៉ោ៖**

**ស៖** ដោយសារថា យើងនៅទីនេះ លោក សួង ស៊ីគឿន ដើម្បីសួរឲ្យលោកបញ្ជាក់ពីការពិត។ វាអាចនឹងជា -- ជួយដល់អង្គជំនុំជម្រះក្នុងការផ្តល់បុគ្គល -- ឈ្មោះបុគ្គលមួយចំនួន ដែលអាចយល់ច្បាស់ដឹងច្បាស់ពីកម្ពុជាប្រជាធិបតេយ្យ ដើម្បីឲ្យអង្គជំនុំជម្រះបានស្តាប់។ តើលោកសាក្សី លោកគិតថា លោក គាត ឈន់ គប្បីតែមកបង្ហាញ សក្ខីកម្ម ដើម្បីស្វែងរកការពិតជូនតុលាការដែរឬទេលោកសាក្សី?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា! សាក្សីកុំអាលទាន់ឆ្លើយ!

**លោក ច័ន្ទ តារាស្មី៖**

លោកប្រធាន ខ្ញុំសូមជំទាស់ទៅនឹងសំណួរនេះ ជាថ្មីម្តងទៀត ហើយខ្ញុំសូមសំណើលោកប្រធានជួយបញ្ជាក់ទៅលោកមេធាវី សូមមេត្តាប្រើពេលវេលាឲ្យមានប្រសិទ្ធភាព ព្រោះសំណួររបស់គាត់គឺសំណួរដែលចាកប្រធានបទអស់មួយព្រឹកហើយបាទ។ ទាក់ទិនទៅនឹងតួអង្គផ្សេង លោក គាត ឈន់ លោក ហោ ណាំហុង ហើយប្រធានបទនេះ គឺតួអង្គកំពុងនិយាយអំពីការការពារខ្លួនលោក -- ដោះបន្ទុកឲ្យកូនក្តីរបស់លោក។ ប៉ុន្តែសំណួរនេះ គឺគ្មានប្រយោជន៍នៅក្នុងដំណើរការនីតិវិធីនៅពេលនេះទេ។ ខ្ញុំសូមជំទាស់ដាច់ខាតចំពោះសំណួរនេះ។ ហើយសំណូមពរសូមឲ្យលោកសួរឲ្យចំនឹងប្រធានបទ ដើម្បីកុំ

ឲ្យខាតពេលវេលាដល់ដំណើរការនីតិវិធីរបស់តុលាការបាទ។ សូមអរគុណ។

[១១:២២:១០]

**លោក ហ្សាស្តេី ប៉ៅ៖**

ខ្ញុំនឹងឆ្លើយតបដោយសង្ខេប។ ខ្ញុំព្យាយាមជួយក្នុងការស្វែងរកការពិត ហើយខ្ញុំធ្វើបែបនេះដើម្បីកំណត់អត្តសញ្ញាណបុគ្គលមួយចំនួនដែលអាចនឹងមានព័ត៌មានពាក់ព័ន្ធច្បាស់លាស់ ទាក់ទងទៅនឹងរបបកម្ពុជាប្រជាធិបតេយ្យ និងកូនក្តីរបស់ខ្ញុំជាពិសេស។ ហើយខ្ញុំរង់ចាំការសម្រេចរបស់លោកប្រធាន អំពីការជំទាស់នេះបាទ។

**ប្រធានអង្គជំនុំ៖**

សេចក្តីជំទាស់និងសំអាងហេតុនៃសេចក្តីជំទាស់ ត្រឹមត្រូវ។ សេចក្តីជំទាស់មានប្រសិទ្ធភាព សាក្សីមិនបាច់ឆ្លើយតបទៅនឹងសំណួរបែបនេះទេ!

**លោក ហ្សាស្តេី ប៉ៅ៖**

នេះធ្វើឲ្យឈានដល់បញ្ចប់ការសួរសំណួររបស់ខ្ញុំលោកប្រធាន។ ហើយសហសេវិកមេធាវីជាតិ សុន អរុណ មិនមានសំណួរអ្វីទេ ហើយអាចនឹងផ្ទេរវេទិកានេះជូនទៅមេធាវីក្រុមការពារក្តីផ្សេងមួយទៀត បាទដើម្បីបន្តសូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការក្តី លោក អៀង សារី ដើម្បីមានឱកាសតាំងសំណួរដេញដោល ចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

[១១:២៣:៤១]

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោកស្រីចៅក្រម ហើយនិងភាគី ហើយនិងសាធារណជនផងដែរ ហើយជម្រាបសួរលោកសាក្សីផងដែរ។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** ខ្ញុំ ម៉ៃខល កាណាវាស ហើយខ្ញុំ ហើយនិងលោក អាង ឧត្តម តំណាងការពារក្តីឲ្យលោក អៀង សារី។ សំណួរខ្ញុំប្រើពេលប្រហែលជា១ថ្ងៃ ឬលើសបន្តិច ដូចខ្ញុំជម្រាបលោក ហើយខ្ញុំនឹងពិនិត្យមើលសក្ខីកម្មដែលលោកបានផ្តល់រហូតមកដល់ពេលនេះ ហើយនិងយើងពិនិត្យមើលប្រតិចារឹកផងដែរ

គឺផ្នែកខ្លះ ដើម្បីឲ្យលោកបំភ្លឺបញ្ហាមួយចំនួន។ ប៉ុន្តែមុនដំបូង សូមឲ្យលោកបំភ្លឺបញ្ហាមួយចំនួនដល់យើងខ្ញុំ ដែលនិយាយកាលពីម្សិលមិញ គឺការប្រជុំរបស់លោកជាមួយ ភី ភួន ការជួប ដែលគាត់ក៏ឈ្មោះ ជាមមុនពេលដែលលោកមកទីនេះ ដើម្បីមកផ្តល់ភស្តុតាងជាសក្ខីកម្មនេះ។ តើលោកអាចប្រាប់ខ្ញុំបានទេ ជាបឋមនោះ តើលោកបានជួបគាត់នៅកន្លែងណា? ជាកន្លែងច្បាស់លាស់នោះ?

[១១:២៤:៥៣]

**លោក សួង ស៊ីគឿន៖**

**ឆ៖** ខ្ញុំបានជួបគាត់នៅសណ្ឋាគារ [redacted] បាទ។

**ស៖** តើអ្នកណាជាអ្នកផ្តើមគំនិតដើម្បីជួបគ្នានេះ? តើលោក ឬក៏គាត់?

**ឆ៖** ខ្ញុំបាទ សូមជួបគាត់ ព្រោះគាត់មិនដែលហ៊ានសូមជួបខ្ញុំទេ ព្រោះខ្ញុំបងគាត់។

**ស៖** បាទ ដូច្នេះលោកបានសូមជួបគាត់ ខ្ញុំសូមសួរលោកថា នៅពេលណាដែលលោកបានជួបគាត់ហ្នឹង?

**ឆ៖** ខ្ញុំចាំមិនច្បាស់ទេ ព្រោះពេលដែលគាត់ចេញដំណើរមក ពីម៉ាឡៃមកគឺព្រឹកហ្នឹង ព្រឹកដែលគាត់ចេញដំណើរមក គាត់បានមកផ្ទះខ្ញុំ គាត់យកឯកសារមួយមកឲ្យខ្ញុំ ប្រហែលម៉ោងប្រាំមួយព្រឹក ហើយម៉ោងប្រាំបួន ម៉ោងដប់អីឡានរបស់តុលាការទៅដឹកគាត់ពីផ្ទះគាត់ ពីម៉ាឡៃមកភ្នំពេញ។ ហើយខ្ញុំតាមខ្ញុំប៉ាន់មើល គឺថាពេលដែលគាត់ចូលមកផ្តល់សក្ខីកម្មហ្នឹងប្រហែលជាមួយថ្ងៃ ឬកន្លះថ្ងៃខ្ញុំចាំមិនច្បាស់ទេបាទ។

[១១:២៦:៣៤]

**ស៖** បាទ ខ្ញុំចង់សួរបញ្ជាក់ ដើម្បីឲ្យខ្ញុំយល់ច្បាស់ត្រឹមត្រូវ។ លោកបានសូមជួបគាត់ នៅពេលដែលលោកបានជួបគាត់ដំបូង គាត់មានឯកសារជាមួយដៃនោះដែរឬទេ តើលោកមានឯកសារខ្លួនឯងនៅក្នុងដៃទេ នៅពេលនោះ?

**ឆ៖** អត់មានទេ។ គាត់ក៏អត់មាន គាត់កំពុង -- ពេលព្រឹកគាត់ស្រស់ស្រូបអាហារជាមួយនិងតំណាងរបស់អង្គភាពគាំពារសាក្សីម្នាក់ ខ្ញុំមិនចាំឈ្មោះគាត់ទេ ហើយយើងមិនបាននិយាយអីពាក់ព័ន្ធនឹងតុលាការទេ។ យើងនិយាយតែរឿងគាត់មកប៉ុន្មានថ្ងៃអី នាំឲ្យគាត់បាត់បង់ការងារដែលគាត់នៅស្រែចម្ការដែលគាត់ប្រមូល កំពុងដកដំឡូងលក់ហ្នឹង ដកដំឡូងលក់អីអីចឹង។ ហើយពីសុខភាពរបស់ខ្ញុំទេបាទ។ អត់មានទាក់ទងអីនេះទេ ហើយខ្ញុំអាចជម្រាបបាន។ ហេតុអ្វីបានខ្ញុំសូមជួបគាត់ គឺខ្ញុំចង់ជួបគាត់

ចង់ដឹងថា គេសួរអីច្បាស់លាស់អីអ៊ីចឹងទេ ដើម្បីខ្ញុំស្រួលឆ្លើយនឹងសំណើតុលាការ។ ហើយខ្ញុំ ហើយនិងគាត់ហ្នឹងមានទស្សនៈដូចគ្នាទេ ចំពោះរឿងទាំងអស់ហ្នឹង បានខ្ញុំមកសួរគាត់។ បាទ មិនមានអីលាក់ទេ។

ហើយតាមដែលខ្ញុំចាំក្នុងសក្ខីកម្មរបស់គាត់ហ្នឹងក៏គាត់និយាយត្រង់ច្រើនដែរបាទ។ ប្រហែលតែខ្ញុំដែរ។

[១១:២៨:១៨]

**ស៖** បាទ យើងនឹងទៅមួយជំហានម្តង លោកសាក្សី ហើយខ្ញុំចង់បង្រួមសំណួររបស់ខ្ញុំ ប៉ុន្តែខ្ញុំចង់ឲ្យប្រាកដ ដើម្បីទទួលចម្លើយរបស់លោក។ ហើយលោកបានផ្តើមគំនិតជួបគាត់ ព្រោះលោកចង់ដឹងថា តើគាត់ធ្វើសក្ខីកម្មដូចម្តេច អ៊ីចឹងហើយការជួបនេះ គឺថាបន្ទាប់ពីការ -- គាត់ធ្វើការ -- ធ្វើសក្ខកម្មនៅពាក់កណ្តាល ឬក៏ក្រោយពេលគាត់នោះចប់ផ្តល់ការធ្វើសក្ខីកម្មបាទ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ!

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

[១១:២៩:១២]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំមិនបានឮអ្វីដែលខាងការពារក្តីនិយាយនោះទេ នៅពេលដែលលោកនិយាយថា លោកចង់ជួបគាត់ដើម្បីចង់ដឹងពីខ្លឹមសារនៃសក្ខីកម្មរបស់គាត់។ ខ្ញុំគិតថា សាក្សីមិនបាននិយាយយ៉ាងដូច្នេះនោះទេ។ ខ្ញុំ -- ដូច្នេះសំណួរនេះ ក្លាយទៅជាសំណួរនាំមុខទៅហើយ ពីព្រោះថា យើងគួរតែចាប់ផ្តើមដោយបញ្ជាក់អំពីអ្វីដែលសាក្សីបាននិយាយ។ ទោះបីជាយ៉ាងណាក៏ជាភាសាបារាំងខ្ញុំមិនបានឮថា សាក្សីហ្នឹងចង់ដឹងអំពីខ្លឹមសារនៃសក្ខីកម្មរបស់លោក ភី ភួន នោះទេ ពេលដែលគាត់ទៅជួបគ្នានោះ។

**លោក ម៉ៃខល កាណាវ៉ាស៖**

**ស៖** នេះហើយ គឺខ្ញុំស្តាប់ភាសាអង់គ្លេសដែរ ខ្ញុំមិន -- អ្វីដែលគាត់ឮជាភាសាបារាំងហ្នឹងខ្ញុំស្តាប់ ឮ នោះ គឺគាត់ជាអ្នកចាប់ផ្តើមសុំការជួប ហើយគាត់ចង់ដឹងថា តើលោកសាក្សីមួយទៀតនោះគាត់បាន និយាយពីអ្វី? ហើយគោលបំណងនៃការជួបគ្នានោះ ហើយខ្ញុំចង់ដឹងថា តើក្នុងពេលការផ្តល់សក្ខីកម្ម របស់សាក្សីនោះ ឬក៏ក្រោយការផ្តល់សក្ខីកម្មរបស់សាក្សីនោះ ការដែលសុំជួបនេះបាទ?

[១១:៣០:៣០]

**លោក ស្នួង ស៊ីគឿន៖**

**ឆ៖** ខ្ញុំចាំច្បាស់ណាស់ ខ្ញុំអាចនឹង -- ប៉ុន្តែខ្ញុំបានកត់ទេ ហើយទើបតែចាប់ផ្តើមទេ បែបមិនដល់មួយថ្ងៃផងតាមមើលទៅ មួយកំណាត់ថ្ងៃ ហើយមិនបាន -- អត់បាននិយាយពីរឿងនេះទេ ព្រោះខ្ញុំ នេះខ្ញុំចង់និយាយថា ខ្ញុំជួបគាត់តែប៉ុណ្ណឹងទេ។ ព្រោះខ្ញុំមិនមានអី គោលបំណងអីវៀចវេរទេ ខ្ញុំចង់ជម្រាបព្រោះថា អ្វីដែលខ្ញុំដឹងខ្ញុំឆ្លើយ។ ហើយមានចំនួន ខ្ញុំដឹងដែរ ប៉ុន្តែខាងតុលាការមិនឱ្យឆ្លើយ ខ្ញុំក៏មិនឆ្លើយដែរ ព្រោះរឿងហ្នឹងវាតុលាការ លោកប្រធានហ្នឹង មានមតិហ្នឹងត្រូវ ប៉ុន្តែអាកន្លែងខ្លះ ខ្ញុំនិយាយវាចេះតែ -- ខ្ញុំមិនយល់ហេតុអ្វីបានគេៗ គេនិយាយពីរឿង លោក គាត ឈន់ រឿង លោក ណាំហុង ខ្លាំងពេកអ្នកដទៃ ឯទៀតដែលពាក់ព័ន្ធក្នុងរឿងហ្នឹង គេមិននិយាយ។ ហើយខ្ញុំសូមជម្រាបលោកតុលាការចុះ ខ្ញុំឆ្លៀតឱកាសហ្នឹងថាបំពានចុះ។ ពេលនុ៎ង លោកទាំងពីរហ្នឹងមានអំណាចតិចជាងខ្ញុំទេ ព្រោះគាត់អត់មានកាន់អីផ្នែកអីមួយទេ។ ពេលនុ៎ង ខ្ញុំជាប្រធានផ្នែកឃោសនានិងព័ត៌មាន។ ខ្ញុំឆ្ងល់ថា វិទ្យុសំឡេងអាមេរិកនេះ និយាយគឺថា -- សូមអត់ទោសលោកប្រធាន ខ្ញុំចប់ឥឡូវហើយ ខ្ញុំមិនកាត់ទេ ដើម្បីនេះ។

[១១:៣២:១០]

និយាយថា ខ្ញុំអនុប្រធានផ្នែកពិធិការ។ ពេលនុ៎ង គឺថាបញ្ញាជនដែលមកពីក្រៅ មានតែខ្ញុំទេ គេអាចតែងតាំងជាប្រធានផ្នែក។ ឃើញទេ! ដូច្នោះ លោកទាំងពីរហ្នឹង លោក គាត ឈន់ ឬលោក ហោ ណាំហុង មានអំណាចតិចជាងខ្ញុំទេ។ ហើយសូមៗខ្ញុំសូមអង្វរកុំទៅរករឿងអីគាត់នោះ គឺថាបើនិយាយជារួម ខ្ញុំមិនចង់និយាយទេ គឺជារួម គាត់មានឋានៈដូចជាខ្ញុំ បញ្ញាជន ដូចខ្ញុំអីចឹង។ នេះ ខ្ញុំសូមចប់សក្ខីកម្មរបស់ខ្ញុំ។ ខ្ញុំចង់និយាយតែប៉ុណ្ណឹងទេ ព្រោះវាស្រគាត្រចៀកតិចៗ គាត ឈន់ តិចៗ ហោ ណាំហុង តិចៗ គាត ឈន់ តិចៗ ហោ ណាំហុង វាត្រចៀកណាស់។ ឃើញទេ! អាហ្នឹង ដែលជាបញ្ហាខ្ញុំស្រគាត្រចៀក វា មិនមានបញ្ញាជន ពេលនុ៎ង មិនមានអំណាចអីទេ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណៗ សាក្សី។ ឥឡូវអីចេះ រំឭកសាក្សីម្តងទៀត សូមស្តាប់នូវសំណួរដែលសួរ ហើយចាប់ពីពេលនេះតទៅ លោកអាចស្តាប់ -- ព្រោះលោកអាចមានវៃបញ្ញា ព្រោះលោកជាបញ្ញាជន បើសិនជាសំណួរណាច្រំដែល គឺលោកអាចមិនឆ្លើយតបក៏បានដែរ ឬក៏សុំមកយើង ដើម្បីយើងសម្រេចថា មិនឱ្យឆ្លើយតបទៅនឹងសំណួរច្រំដែលទេ។ ព្រោះយើងស្តាប់ច្រើននៅក្នុងសវនាការប៉ុន្មានថ្ងៃនេះ យើង

ឃើញសំណួរច្រំដែលច្រើន ជាពិសេស ប្រភេទសំណួរដែលភាគីសួរផ្ទុញ់សាក្សី។ យើងកត់សម្គាល់ឃើញថា សំណួរច្រំដែលច្រើនណាស់។ ទី២ ប្រភេទសំណួរផ្សេងទៀត លោកបង្អង់សិន ប្រសិនបើសួរឱ្យលោកឆ្លើយថា បាទ ឬក៏ ទេ។ សំណួរប្រភេទនេះ គឺអង្គជំនុំជម្រះមិនអនុញ្ញាតឱ្យប្រើប្រាស់នៅក្នុងអង្គសវនាការ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានេះទេ។

[១១:៣៣:៥១]

ទី៣ សូមរំឭកលោកថា សូមលោកស្តាប់ខ្លឹមសារសំណួរឱ្យបានឆ្លើយតបទៅនឹងកម្រិតត្រឹមតែគោលបំណងនៃការសួរបានហើយ។ ចៀសវាង ការដែលលោកធ្វើអត្ថាធិប្បាយវែង នាំឱ្យបញ្ហាវាវែងហើយនិងពេលវេលាវាខាតបង់ឥតប្រយោជន៍ ពីព្រោះវាអាចក្រៅបំណងនៃការចង់បានរបស់អង្គជំនុំជម្រះ ឬក៏ភាគីដែលមានសិទ្ធិក្នុងការតាំងសំណួរចំពោះលោក។ នោះ គឺលោកនឹងអាចមានលទ្ធភាពវិលត្រឡប់ទៅលំនៅដ្ឋានរបស់លោកវិញ។ បើពុំដូច្នោះទេ គឺលោកនឹងអាចនៅទីនេះ អាចចំណាយពេលវេលាច្រើនទៀត នៅក្នុងការផ្តល់សក្ខីកម្ម។

សូមអញ្ជើញបន្តការតាំងសំណួរ!

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ បាទ ជាទូទៅរទេះប្រហែលជាអាចទៅយឺត ប៉ុន្តែគោវាខិតខំប្រឹងចេះតែខិតខំប្រឹងទាញទៅ។ ដូច្នេះ ខ្ញុំចង់ឱ្យសាក្សីហ្នឹងឆ្លើយសំណួររបស់ខ្ញុំបន្តៗទៀត។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** ឥឡូវលោក តើលោកអាចប្រាប់ខ្ញុំបានទេ ថាតើការដែលលោកជួបជាមួយលោក ភី ភួនហ្នឹង ប្រើរយៈពេលអស់ប៉ុន្មាន? ១ម៉ោង ២ម៉ោង ឬក៏៥នាទី ឬក៏រយៈពេលប៉ុន្មាន? តើលោកអាចប្រាប់តុលាការបានទេ?

[១១:៣៥:៣៤]

**លោក សួង ស៊ីគឿន៖**

**ឆ៖** តិចទេ ព្រោះស្រស់ស្រូប គាត់ស្រស់ស្រូបហើយ ខ្ញុំមិនទាន់ស្រស់ស្រូប ខ្ញុំស្រស់ស្រូបហើយ គិតថាប្រហែលកន្លះម៉ោងចុះបាទ ហើយគាត់មាន -- បាទ គាត់ដូចថាមានការ ខ្ញុំក៏មានការដែរបាទ។

**ស៖** អរគុណៗលោកសាក្សី។ ហើយលោកក៏បានលើកឡើងថាដែរថា លោកបានតាមដាន

មើលនូវសក្ខីកម្មរបស់លោក ភី ភួន នេះ ថាតើលោកតាមដានតាមវីដេអូ អ!តាមទូរទស្សន៍ តាមវិទ្យុ ឬក៏តាមអ៊ីនធឺណេត ឬក៏តាមណា? តាមមធ្យោបាយណាដែលលោកបានតាមដានមើលដំណើរការផ្តល់សក្ខីកម្មរបស់គាត់នោះ?

**ឆ៖** តាមៗវិទ្យុជារួមបាទ។

**ស៖** បាទ អ៊ីចឹងតើលោកមានបានជួបគាត់ទៀតទេ តាំងពីលោកជួបគាត់ចុងក្រោយបំផុត ហើយនិងពីពេលដែលលោកជួបគាត់ហ្នឹងរហូតមកដល់ពេលឥឡូវនេះ តើបានជួបទេ? បើសិនជាបានជួបមែន ថាតើពេលណា?

**ឆ៖** ខ្ញុំមិនបានជួបគាត់ទៀតទេបាទ។

[១១:៣៦:៤៩]

**ស៖** សូមអរគុណ។ ថាតើលោកបានអាននូវៗការអត្ថាធិប្បាយរបស់គាត់ទេ នៅក្នុងកាសែតក្តី ឬក៏នៅក្នុងវិទ្យុក្តី ថាតើលោកបានស្តាប់មើលនូវការអត្ថាធិប្បាយរបស់គាត់ទេបាទ?

**ឆ៖** ខ្ញុំមិនបានអានអត្ថាធិប្បាយរបស់គាត់នៅក្នុងកាសែត ឬវិទ្យុទេបាទ។

**ស៖** នៅមុនពេលដែលគាត់អញ្ជើញមកធ្វើសក្ខីកម្មនេះ លោក សួរ ហុង ក៏បានធ្វើសក្ខីកម្មដែរ។ តើលោកស្គាល់លោក សួរ ហុង ទេ? តើគាត់ជានរណា?

**ឆ៖** បាទ ខ្ញុំស្គាល់គាត់តើ! គាត់ជាអ្នកបានមកទទួលខ្ញុំ កាលខ្ញុំទៅភ្នំពេញនៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៧៥បាទ។ ហើយផ្ទះគាត់នៅម៉ាឡៃហ្នឹង ជាប់នឹងផ្ទះខ្ញុំដែរបាទ។

**ស៖** បាទ អ៊ីចឹងបានន័យថាលោកស្គាល់គាត់ច្បាស់ នៅពេលដែលលោកធ្វើការនៅក្រសួងការបរទេសនៅពេលនោះ ចាប់ពីឆ្នាំ១៩៧៥ ដល់៧៩ ហ្នឹង គឺលោកស្គាល់គ្នាច្បាស់។ តើខ្ញុំនិយាយអ៊ីចឹងត្រូវទេលោក?

[១១:៣៨:០៦]

**ឆ៖** បាទ គឺថាខ្ញុំស្គាល់គាត់ច្បាស់ណាបាទ។

**ស៖** អ៊ីចឹងតើលោកនៅរក្សាទំនាក់ទំនងជាមួយគាត់ទៀត ដូចដែលលោកបានធ្លាប់បន្តទំនាក់ទំនងជាមួយលោក ភី ភួន ហ្នឹង ជាមួយលោក សួរ ហុង តើលោកនៅបន្តទំនាក់ទំនងអ៊ីចឹងទៀតទេ?

**ឆ៖** ជារួមមិនមានការអីទាក់ទងជាហូរហែទេជាមួយលោក សួរ ហុង ហ្នឹង ព្រោះគាត់មានជំងឺ ហើយគាត់ឧស្សាហ៍នៅភ្នំពេញដែរ គាត់ទៅម៉ាឡៃម្តងៗ ហើយគាត់មានផ្ទះមួយនៅឆ្ងាយពីផ្ទះខ្ញុំ

បន្តិច នៅកន្លែងភូមិគេហៅថា ៩៣ នុំង វានៅឆ្ងាយពីផ្ទះភូមិខ្ញុំបន្តិច ហើយពេលខ្លះក៏ខ្ញុំមិនបានដឹងដែរ ហើយពេលខ្លះក៏ខ្ញុំដូចខែវស្សាហ្នឹង ខ្ញុំមកមន្ទីរពេទ្យ ហើយដោយបញ្ហាសុខភាព ខ្ញុំច្រើននៅភ្នំពេញជាមួយកូនខ្ញុំច្រើនដែរ ទាល់តែខែប្រាំងអីបានខ្ញុំទៅ។ ណេះ មិនដូចលោក ភី ភួន, លោក ភី ភួន គឺថាផ្ទះគាត់នៅឆ្ងាយមែន ក៏ប៉ុន្តែគាត់នៅតែម៉ាឡៃហ្នឹង ខ្ញុំទាក់ទងជាមួយគាត់ញឹកញាប់ដែរបាទ។ ចង់និយាយថា បើបញ្ជាក់ថាចំណងមិត្តភាពដែលរក្សាទុកពីជំនាន់តស៊ូហ្នឹង ពីជំនាន់កម្ពុជាប្រជាធិបតេយ្យ យើងរក្សាទុកជាមួយគ្នា រក្សាបន្តជាមួយគ្នា ក៏ប៉ុន្តែជាមួយលោក ភី ភួន គឺខ្ញុំទាក់ទងបានញឹកញាប់ជាងបាទ។

[១១:៣៩:៤៧]

**ស៖** សូមអរគុណលោកសក្សី។ ថាគាត់បានមកផ្ដល់សក្ខីកម្ម ដូចលោក ភី ភួន អ៊ីចឹងដែរ ថាតើលោកបានដឹងទេ ថាគាត់អញ្ជើញមកផ្ដល់សក្ខីនៅមុខអង្គជំនុំជម្រះនេះ?

**ឆ៖** លោក១ សួរ ហុង ខ្ញុំមិនបានដឹងទេបាទ ព្រោះខ្ញុំឃើញគាត់នៅក្នុងទូរទស្សន៍ បានខ្ញុំដឹង។

**ស៖** អ៊ីចឹងថាតើលោកមានបានព្យាយាមទាក់ទងជាមួយគាត់ តាមមធ្យោបាយណាមួយ ដើម្បីស្វែងយល់ថាតើគាត់បានផ្ដល់សក្ខីកម្មយ៉ាងដូចម្ដេចខ្លះ នៅក្នុងតុលាការនេះទេ?

**ឆ៖** ខ្ញុំមិនបានទាក់ទងជាមួយគាត់ទេបាទ។

[១១:៤០:៤៦]

**ស៖** បាទ ឥឡូវយើងជជែកគ្នាបន្តិចអំពីលោក ជាម ឬក៏លោក ភី ភួន នេះ។ លោក សួរ ហុង យើងនឹងជជែកគ្នាបន្តិចទៀត។ ប៉ុន្តែឥឡូវនេះខ្ញុំចង់១សួរសំណួរចុងក្រោយមួយទៀត គឺផ្អែកទៅតាមបទពិសោធន៍របស់លោកដែលធ្វើការនៅក្រសួងការបទេសនេះ។ ឥឡូវនេះ បើសិនជាលោកមើលតាមសមត្ថភាពរបស់លោកនាពេលបច្ចុប្បន្ន តើលោកអាចពន្យល់យើងបានទេ អំពីកាតព្វកិច្ចរបស់លោកនៅក្នុង១ក្រសួងការបរទេសនេះ គឺមុខងាររបស់គាត់នេះ?

**ឆ៖** ខ្ញុំគ្រាន់តែដឹថា គាត់ជាកងការពារស្ថានទូតបរទេសប្រចាំទីក្រុងភ្នំពេញ។ តែប៉ុណ្ណឹងទេបាទ ពេលនុំងខ្ញុំដឹងតែប៉ុណ្ណឹងទេបាទ។

**ស៖** សូមអរគុណ។ ខ្ញុំអាចសួរសំណួរនេះឲ្យរាងត្រង់បន្តិច ថាតើលោកកំពុងតែលើកឡើងនៅទីនេះដោយសារលោកបានធ្វើសម្បថរួចហើយ។ លោកដឹងហើយថា ទាំងពីរនាក់ហ្នឹងថាគាត់ជា ពិតជាអ្នកយាមនៅស្ថានទូតបរទេសនៅប្រចាំទីក្រុងភ្នំពេញមែនទេនៅពេលនោះ ពេលដែលលោកស្គាល់គាត់? តើលោកចង់និយាយអ៊ីចឹង ឬក៏យ៉ាងម៉េចបាទ?

[១១:៤២:០៧]

**ផះ** ហើយខ្ញុំដឹងថា លោក ភី ភួន គាត់ជាប្រធានការពារ។ គាត់ទទួលបន្ទុកខាងការពារស្ថានទូតបរទេសនៅភ្នំពេញ ហើយលោក សួរ ហុង គាត់ជាអគ្គលេខាធិការនៃក្រសួងការបរទេស។ ជារួមគាត់ជាដៃស្តាំរបស់លោក អៀង សារី បាទ។

**សះ** បាទ ដូចខ្ញុំ -- យើងនឹងជជែកលម្អិតបន្ថែមទៀតអំពីគាត់។ ប៉ុន្តែថាតើលោកបានដឹងព័ត៌មាននេះពីពេលណាទៅ? តើព័ត៌មានហ្នឹងលោកទើបតែដឹងឥឡូវនេះ ឬក៏លោកដឹងនៅក្នុងពេលអំឡុងពេលដែលលោកធ្វើការ៣ឆ្នាំជាង នៅក្រសួងការបរទេសនៅទីនោះ ដែលលោកដឹងអំពីតួនាទីរបស់អ្នកទាំងពីរនាក់នេះ?

**ផះ** បាទ ខ្ញុំដឹងពីតួនាទីរបស់គាត់ ពេលដែលខ្ញុំធ្វើការនៅក្រសួងការបរទេសពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ បាទ។

[១១:៤៣:១២]

**សះ** បាទ អ៊ីចឹងសក្ខីកម្មរបស់លោកហ្នឹង គឺថាគាត់ទទួលខុសត្រូវក្នុងការការពារស្ថានទូតនៅកម្ពុជា ហ្នឹងចំពោះលោក ភី ភួន។ តើហ្នឹងគឺអ្វីដែលលោកបានដឹង ឬក៏លោកមានដឹងអីផ្សេងទៀតអំពីតួនាទីរបស់គាត់នៅក្នុងក្រសួងការបរទេសនៅពេលនោះ?

**ផះ** ខ្ញុំមិនបានដឹងទេបាទ ព្រោះ--។

**សះ** បាទ អ៊ីចឹងបើសិនជាខ្ញុំចង់សួរលោកបន្ថែមទៀត ថាតើលោកបានដឹងអីទៀត ឧទាហរណ៍ថាគាត់ធ្វើការងារទាក់ទងទៅនឹងការងាររដ្ឋបាលនៃក្រសួងការបរទេស ឬក៏ការគ្រប់គ្រងរដ្ឋបាលទៅលើបុគ្គលិករបស់ក្រសួងការបរទេសហ្នឹង តាមភស្តុតាងដែលលោកបានផ្តល់ឲ្យយើងហ្នឹង ថាតើលោកអត់បានដឹងទេឬ អំពីការងាររដ្ឋបាលដែលគាត់អាចធ្វើក្រសួងការបរទេសនេះ?

**ផះ** ខ្ញុំមិនបានដឹងច្បាស់ទេបាទ។

[១១:៤៤:១៣]

**សះ** បាទ ឥឡូវយើងមើលសក្ខកម្មនេះ ហើយយើងនឹងមើលត្រឡប់មើលទៅវិញ ទៅសក្ខីកម្មរបស់លោក ភី ភួន ហើយនិងលោក សួរ ហុង នៅពេលក្រោយបន្តិចទៀតនេះ។ ឥឡូវខ្ញុំគ្រាន់តែចង់ពិនិត្យមើលទៅលើសក្ខីកម្មរបស់លោកដែលលោកបានផ្តល់ នៅពេលដែលសហព្រះរាជអាជ្ញាគាត់បានសួរសំណួរលោកពីខាងដើមមកនេះ។ ទី១ ខ្ញុំចង់ទៅការពិភាក្សាអំពីបញ្ហា ហ្វុង ហើយយើងដឹងហើយថា

យើងបានពិភាក្សាគ្នាច្រើនហើយពីបញ្ហានេះ ប៉ុន្តែខ្ញុំចង់ធ្វើការបញ្ជាក់ឡើងវិញនូវចំណុចមួយចំនួន។

ឥឡូវនៅថ្ងៃទី០២ ខែសីហា នៅពេលដែលលោកមកផ្តល់សក្ខីកម្មនៅទីនេះ គឺលោកបាន -- ខ្ញុំសូមលើកខ្មែរ ERN 00831413, ជាភាសាបារាំង 00832798, ភាសាអង់គ្លេស 00832685។ នៅទីនេះលោកបានផ្តល់នូវសក្ខីកម្មថា លោកបានចូលរួមជាមួយនឹងការរៀបចំបង្កើតហ្វុងឡើងនៅក្នុងប្រទេសចិន ហើយលោកក៏ត្រូវបានបោះឆ្នោតនៅក្នុងកិច្ចប្រជុំហ្នឹងឲ្យជាអគ្គលេខា -- ជាលេខានៃគណៈកម្មាធិការកណ្តាលរបស់ហ្វុងហ្នឹង។ អ៊ីចឹងថាតើនេះគឺជាការត្រឹមត្រូវទេ? លោកនៅតែរក្សាចម្លើយហ្នឹងទេ?

**ឆ៖** បាទ ខ្ញុំនៅតែរក្សាចម្លើយហ្នឹងបាទ។

**ស៖** ឥឡូវនៅទំព័របន្ទាប់ទៅទៀត លោកបានបន្តលើកឡើងថា រណសិរ្សរួបរួមជាតិកម្ពុជាហ្នឹងត្រូវបានបង្កើតឡើងបន្ទាប់ពីមានការអំពាវនាវពីសម្តេច នរោត្តម សីហនុ នៅថ្ងៃទី២៣ ខែមិថុនា។ តើលោកអាចធ្វើការបញ្ជាក់ឡើងវិញអំពីចំណុចនេះបន្តិចទេបាទ?

[១១:៤៦:៣៣]

**ឆ៖** សេចក្តីអំពាវនាវរបស់សម្តេច នរោត្តម សីហនុ គឺនៅថ្ងៃ២៣ ខែមីនា បាទ ឆ្នាំ១៩៧០ ដែលលោកអំពាវនាវឲ្យជនរួមជាតិយើងក្រោកឈរឡើងប្រឆាំងនឹងរដ្ឋប្រហារថ្ងៃទី១៨ មីនា ១៩៧០ របស់លោកសេនាប្រមុខ លន់ នល់ ហើយរត់ចូលម៉ាគី។ រត់ចូលម៉ាគី គឺថារត់ចូលព្រៃបាទ។

**ស៖** ហើយថាតើអ្នកដែលគាត់រត់ចូលព្រៃម៉ាគីហ្នឹង ថាតើគាត់ត្រូវធ្វើអីពេលនុ៎ង ពេលដែលគាត់ចូលទៅហ្នឹង ចូលក្នុងគោលបំណងអីបាទ?

**ឆ៖** ចូលព្រៃហ្នឹងមានន័យថា ចូលធ្វើការតស៊ូដោយអាវុធ រួមជាមួយនឹងកម្លាំងប្រដាប់អាវុធដែលមានរួចមកហើយនៅពេលនោះ នៅលើទឹកដីកម្ពុជាពេលនោះមានកម្លាំងប្រដាប់អាវុធដឹកនាំ -- ហ្វីកហ្វីន និងដឹកនាំដោយបក្សកុម្មុយនីស្តកម្ពុជា ហើយនិងកងទ័ពរំដោះរណសិរ្សវៀតណាមខាងត្បូងបាទ។

**ស៖** ហើយថាតើគាត់បានអំពាវនាវឲ្យមានអ្នកស្នេហាជាតិ ហើយនិងអ្នកជាតិនិយមដែលរស់នៅបរទេសហ្នឹង ហើយនិងអ្នកដែលនៅក្នុងប្រទេសកម្ពុជាហ្នឹងឲ្យចូលរួមប្រឆាំង តស៊ូប្រឆាំងជាមួយនឹងរបបសាធារណរដ្ឋរបស់លោក លន់ នល់?

[១១:៤៨:២៧]

**ឆ៖** បាទ តាមខ្ញុំចាំពេលនោះព្រះអង្គអំពាវនាវ គឺថាប្រជាជនជាកូនចៅរបស់ព្រះអង្គនៅក្នុងប្រទេសឲ្យចូលរួមតស៊ូប្រឆាំងនឹងរបប អ៎!ប្រឆាំងនឹងរដ្ឋប្រហារ ហើយនិងរដ្ឋាភិបាលរបស់លោកសេនាប្រមុខ លន់ នល់ បាទ។

**ស៖** ឥឡូវខ្ញុំៗសូមលើកជាសក្ខីកម្មរបស់សាក្សីមួយទៀត ដែលគាត់បានមកផ្តល់សក្ខីកម្មនៅទីនេះប៉ុន្មានថ្ងៃមុននេះ លោកអ៊ុង ចុងហឿង។ លោកអ៊ុង ចុងហឿង គាត់បានមកផ្តល់សក្ខីកម្ម ហើយនេះគឺថានៅថ្ងៃទី០៧ ខែសីហា ខ្មែរគឺ 00832575, ហើយភាសាបារាំង ខ្ញុំមានតែជាពង្រាងទេ គឺទំព័រទី៦៧, ៦៨ ហើយភាសាអង់គ្លេសក៏អ៊ីចឹងដែរ គឺទំព័រទី៧៧ ពេលនោះគាត់បានលើកឡើងអំពីចលនារបស់រណសិរ្សហ្នឹងនៅក្រោមការដឹកនាំរបស់លោក អៀង សារី ហើយថ្ងៃនេះគឺខ្ញុំចង់ឲ្យលោកមានការ -- ធ្វើការបញ្ជាក់ ថាតើលោកប្រាប់ថា ថាតើចលនារបស់រណសិរ្សហ្នឹង គឺជាពិតជាស្ថិតនៅក្រោមការដឹកនាំរបស់លោក អៀង សារី ឬក៏វាស្ថិតនៅក្រោមការដឹកនាំរបស់សម្តេច នរោត្តម សីហនុ ឬក៏ក្រោមមេដឹកនាំណាផ្សេងទៀត?

[១១:៥០:០១]

**លោក សួង ស៊ីគឿន៖**

លោកប្រធាន ខ្ញុំសុំឲ្យលោកមេធាវីបញ្ជាក់ពីសំណួរផង ពីព្រោះរណសិរ្សវាមានពីរផ្នែក ផ្នែកក្នុងប្រទេស និងក្រៅប្រទេសបាទ។

**លោក ម៉ែខល កាណាវាស៖**

**ស៖** ខ្ញុំអរគុណណាស់ អរគុណដែលលោកសួរការបញ្ជាក់នេះឡើងវិញ។ ហ្នឹងគឺសំណួរ ហើយនិងចម្លើយដែលយើងត្រូវបានទទួល។ ហើយលោកបានលើកឡើងថា ចលនារណសិរ្សហ្នឹងគឺតាមបញ្ជារបស់ លោក អៀង សារី។ គឺក្នុងគោលបំណងផ្សះផ្សាខ្មែរដែលមាននិន្នាការនយោបាយផ្សេងៗគ្នា។ ដូច្នេះ លោកអាចធ្វើការពន្យល់ត្រង់នេះបន្តិច។ ថាតើវាពិតជាមាន រណសិរ្សហ្នឹងវាមានចលនាពីរ ឬក៏យ៉ាងម៉េច?

**លោក សួង ស៊ីគឿន៖**

**ឆ៖** តាមខ្ញុំយល់ ពាក្យថា “រណសិរ្ស” ហ្នឹងគឺ វាជាសម្ព័ន្ធភាពរវាងកម្លាំងនយោបាយដែលមាននិន្នាការប្លែកៗគ្នា ដើម្បីសម្រេចគោលបំណងរួម។ ដូច្នោះក្នុងរណសិរ្សនេះ រណសិរ្សរួបរួមជាតិកម្ពុជានេះវាមានកម្លាំងស្នេហាជាតិទាំងមូល ដែលក្នុងហ្នឹងគឺថា មានកម្លាំងរបស់រាជានិយម យើងនិយាយ

អ៊ីចឹងទៅចុះបាទ។ រាជានិយម កម្លាំងរបស់ពួកបក្សកុម្មុយនីស្តកម្ពុជា ហើយកម្លាំងស្នេហាជាតិជាកម្លាំងកណ្តាល។ ខ្ញុំធ្លាប់បានជម្រាបហើយ កម្លាំងកណ្តាលគឺមានឥស្សរជនយ៉ាងណាខ្លះ? គឺឥស្សរជនទាំងនោះដូចជា លោក ចៅ សេង, ដូចជាលោក ស្វ ណៃម, ដូចជា ឧត្តមសេនីយ៍ ដួង សំអុល, ដូចជាលោក អាង គឹមឃន អតីតទូត ឯកអគ្គរដ្ឋទូតកម្ពុជាប្រចាំកូរ៉េខាងជើងហ្នឹង។ គេហៅថាកម្លាំង គឺថាកណ្តាល កម្លាំងគឺថានេះ មិនចូលស៊ប់ជាកម្លាំងសីហនុនិយមទេ ប៉ុន្តែក៏មិនចូលស៊ប់ជាកម្លាំងបក្សកុម្មុយនីស្តកម្ពុជា ប៉ុន្តែជាជនស្នេហាជាតិដែលចូលរួមក្នុងរណសិរ្ស ហើយដែលមានមុខនាទីក្នុងរណសិរ្សបាទ។

[១១:៥២:៣៧]

**ស៖** សូមអរគុណណាស់ចំពោះការពន្យល់ និងបំភ្លឺលើចំណុចនេះ។ ហើយដើម្បីឲ្យវាកាន់តែច្បាស់ទៀត យើងសួរថាតើអ្នកណាជាអ្នកដឹកនាំរណសិរ្សហ្នឹង? ពីព្រោះនៅគ្រប់រចនាសម្ព័ន្ធរបស់រណសិរ្សហ្នឹងគឺជាទូទៅគេដើម្បីសម្រេចនូវគោលដៅរួមមួយ។ ឬក៏គេអាចថា រណសិរ្សហ្នឹងវាមានរបៀបវារៈ គេផ្សេងៗគ្នា ឬក៏យ៉ាងម៉េច?

**ឆ៖** ច្បាស់ណាស់គឺថា រណសិរ្សហ្នឹងគឺថា សម្តេចព្រះនរោត្តម សីហនុ លោកជាប្រធាន។ ហើយនៅក្រៅប្រទេស គឺថាកិច្ចការទូតសំខាន់ៗគឺ លោកបានបំពេញដោយផ្ទាល់ព្រះអង្គលោក ហើយនិងគឺថាអ្នកដែលគាំទ្រលោក បានធ្វើដូចជាពួកឯកអគ្គរដ្ឋទូតមួយចំនួន ក៏ជា -- ប្រចាំនៅក្រៅប្រទេសនៅពេលនោះ ក៏ជាអ្នកដែលធ្វើការក្រោមបង្គាប់របស់ព្រះអង្គដែរបាទ។

[១១:៥៣:៥៣]

**ស៖** ឥឡូវផ្អែកទៅតាមចម្លើយរបស់លោក ថាតើនរណាគេជាអ្នកនាំពាក្យឲ្យរណសិរ្សហ្នឹងថាតើអ្នកណាគឺជាអ្នកនាំពាក្យផ្លូវការរបស់រណសិរ្ស ដែលមានអំណាច ឬក៏សិទ្ធិអំណាចក្នុងការនាំពាក្យឲ្យរណសិរ្សនោះ?

**ឆ៖** ពេលនោះតាមខ្ញុំចាំបានគឺ មិនមានតែងតាំងជាអ្នកនាំពាក្យរណសិរ្សទេ។ គឺអ្នកនាំពាក្យហ្នឹង ដូចជាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះអង្គក៏ជាអ្នកដឹកនាំ ហើយព្រះអង្គបានបំពេញសកម្មភាពច្រើន ដើម្បីផលប្រយោជន៍របស់រណសិរ្ស ហើយព្រះអង្គក៏មានការជួបកាសែត មានសម្ភាសអីច្រើន។ ហើយទន្ទឹមនឹងនេះ ក៏ការិយាល័យនយោបាយរបស់រណសិរ្ស ដែលដឹកនាំដោយសម្តេច ប៉ែន នុត ក៏មានភារកិច្ចផ្សព្វផ្សាយ និងធ្វើការដូចថា ឲ្យអន្តរជាតិបានស្គាល់ ហើយគាំទ្ររណសិរ្សរួបរួមជាតិ

កម្ពុជាដែរ នៅលើឆាកអន្តរជាតិ។ ហើយចំពោះលោក អៀង សារី ពេលនោះគាត់មិនមានតួនាទីអី តំណាងអីទេ គ្រាន់តែគាត់តំណាងផ្នែកខាងក្នុងប្រទេស ជាមួយនឹងរណសិរ្សនៅក្រៅប្រទេស។ ហើយ ការងារដែលខ្ញុំដឹងមានប៉ុណ្ណឹងបាទ។

[១១:៥៥:៤៦]

**ស៖** សូមអរគុណ។ ឥឡូវពាក់ព័ន្ធជាមួយនឹងអ្វីដែលសម្តេច សីហនុ បានលើកឡើង ឬក៏បាន សរសេរ តាមអ្វីដែលលោកបានដឹង យើងចាំបាច់ត្រូវពិនិត្យមើលឡើងវិញ ហើយនិងអាចថា កែសម្រួល ដែលនូវអ្វីដែលពេលនោះព្រះមហាក្សត្រ គាត់ត្រូវសរសេរ ឬក៏មានព្រះរាជឱង្កា?

**ឆ៖** សូមអត់ទោសលោកប្រធាន។ ខ្ញុំក្តាប់សំណួរហ្នឹងមិនបាន ខ្ញុំសូមពិភាក្សាជាមួយមេធាវីខ្ញុំ បន្តិចបាទ។

**ប្រធានអង្គជំនុំ៖**

លោកអាចឲ្យមេធាវីតាំងសំណួរនេះសាជាថ្មី។ ហើយទំនងមេធាវីមិនទាន់សួរទេ ព្រោះភាសា ខ្មែរគឺពិតហើយវាបានលើកឡើងហ្នឹង គឺមិនមាន មិនមែនជាសំណួរ ព្រោះអ៊ីចឹងប្រហែលជាគាត់មិនទាន់ សួរលោកទេ ហើយចាំស្តាប់គាត់សួរសិន ប្រសិនជាលោកមិនច្បាស់ទេ ឲ្យគាត់សួរសាជាថ្មីម្តងទៀត។

លោកចងចាំថា មានតែសំណួរណាដែលនាំឲ្យលោកឆ្លើយទៅ ដាក់កំហុសលើខ្លួនឯង ដាក់បន្ទុក លើខ្លួនឯង ដាក់ពិរុទ្ធភាពលើខ្លួនឯងនៅក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យទេ ទើបលោកពិភាក្សា ជាមួយនឹងមេធាវីជាមុន ថាតើលោកត្រូវឆ្លើយ ឬក៏មិនឆ្លើយតបទៅនឹងសំណួរ។ ក្រៅពីសំណួរមួយ ប្រភេទនេះ គឺលោកត្រូវតែមានកាតព្វកិច្ចក្នុងការតាំង អ៎! ក្នុងការឆ្លើយតបទៅនឹងសំណួរ។

[១១:៥៧:៣១]

លើកលែងតែអង្គជំនុំជម្រះសម្រេចថា ឲ្យលោកសាក្សីមិនចាំបាច់ឆ្លើយតប ដោយសារមូលហេតុ ផ្សេងៗ ដែលយើងបានសម្រេចរួចហើយ ដូចជាសំណួរច្រំដែល សំណួរក្រៅអង្គហេតុជាដើម។

លោកមេធាវីតាំងសំណួរសាជាថ្មីម្តងទៀត ពីព្រោះជាភាសាខ្មែរស្តាប់មិនយល់ថាជាសំណួរទេ។

**សួរដោយលោក ម៉ៃខល កាណាវាស៖**

**ស៖** ខ្ញុំសូមសម្រួលសំណួរនេះឡើងវិញ។ មុនពេលដែលសម្តេចគាត់ថ្លែងអីមួយ ឬក៏គាត់ សរសេរអ្វីមួយដោយក្រោមឈ្មោះរបស់គាត់ ថាតើវាចាំបាច់ត្រូវឆ្លងកាត់ការត្រួតពិនិត្យអីទេ ដើម្បីមើល ថាតើខ្លឹមសារអ្វីដែលគាត់ត្រូវលើកឡើង ឬក៏គាត់ត្រូវសរសេរហ្នឹង វាសមស្រប ហើយនិងទទួលបាន

ការអនុញ្ញាត ឬក៏វាអាចថា មានសុក្រឹតភាពជាមួយនឹងរាល់ឯកសារផ្សេងៗទៀតនៅពេលនោះ?

[១១:៥៨:៣៩]

**លោក សួង ស៊ីគឿន៖**

**ឆ៖** ខ្ញុំថា ព្រះអង្គជាប្រធាន។ ដូច្នោះជាសិទ្ធិរបស់ព្រះអង្គនឹងធ្វើសេចក្ដីថ្លែងការណ៍ តាមដែលព្រះអង្គយល់ថា មានប្រយោជន៍ ហើយជាអំណោយផលដល់ការតស៊ូនៅពេលនោះ ដូចព្រះអង្គមិនមានការដែលចាំបាច់ត្រូវឆ្លង ត្រូវសួរមតិអ្នកណាផ្សេងទៀតទេ។ ខ្ញុំអាចនឹងឆ្លើយចំពោះសំណួរនេះបានថា ប៉ុន្តែសេចក្ដីថ្លែងការណ៍របស់ព្រះអង្គ ជារួមគឺ អំណោយផលដល់ការតស៊ូនៅពេលនោះ ព្រោះអ្វីៗដែលព្រះអង្គធ្វើ ហើយព្រះអង្គតែងតែធ្វើកន្លងមក ព្រះអង្គបានគិតគូរដល់ការលះបង់ ការលំបាកវេទនារបស់បងប្អូន ដែលប្រយុទ្ធនៅក្នុងសមរភូមិក្នុងប្រទេសណាស់ ព្រះអង្គធ្វើសេចក្ដីថ្លែងការណ៍អ្វីមួយ ក៏ព្រះអង្គមិនឲ្យប៉ះពាល់ដល់ស្មារតីប្រយុទ្ធ និងស្មារតីលះបង់របស់យុទ្ធជនទាំងអស់នោះទេ។ ព្រះអង្គមានតែលើកទឹកចិត្ត មានតែគាំទ្រ មានតែផ្ដល់ភាពកក់ក្ដៅដល់បងប្អូនទាំងអស់នោះបាទ។

[១២:០០:១២]

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណ។

លោកប្រធានមើលឃើញម៉ោងយើង -- ហើយសំណួររបស់ខ្ញុំប្រហែលជាអាចហួសម៉ោងដប់ពីរទៀត។ អ៊ីចឹងវាអាស្រ័យទៅលើការសម្រេចរបស់លោកប្រធាន។ ខ្ញុំនឹងស្ដាប់តាមការណែនាំរបស់លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ពេលវេលាសមល្មមនឹងសម្រាកពិសាអាហារថ្ងៃត្រង់ហើយ។ ហើយលោក សួង ស៊ីគឿន តើលោកអាចបន្តផ្ដល់សក្ខីកម្មនៅរសៀលនេះបានដែរឬទេ? ឬក៏លោកមានបញ្ហាសុខភាព ហើយលោកសុំធ្វើនៅព្រឹកថ្ងៃស្អែក?

[១២:០០:៥៥]

**លោក សួង ស៊ីគឿន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំខំប្រឹងណាស់ដែរ ហើយខ្ញុំចង់បញ្ចប់ឆាប់ដែរ ប៉ុន្តែតាមមើលទៅសំណួរខ្ញុំមិនស្មានថា ជាពិសេសសំណួរមុនៗ ស្មានសំណួរអីវា -- មិនពិបាកអីឆ្លើយទេ ប៉ុន្តែដូចថា វាធ្វើ

ឲ្យខ្ញុំហត់ដែរ។ ដូច្នេះ បើលោកប្រធានអនុញ្ញាត ខ្ញុំសូមសម្រាកនៅថ្ងៃរសៀលនេះ ហើយខ្ញុំនឹងបន្តមកធ្វើសក្ខីកម្មនៅពេលស្អែកព្រឹកបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អ៊ីចឹងគឺ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកដើម្បីពិសាអាហារថ្ងៃត្រង់ ហើយសវនាការលើកទៅបន្តធ្វើនៅរសៀលនេះ។ ប៉ុន្តែនៅរសៀលនេះអង្គជំនុំជម្រះ ជម្រាបជូនភាគី និងសាធារណជនថា អង្គជំនុំជម្រះមិនដំណើរការសួរដេញដោលសាក្សី សួង ស៊ីគឿន ទេ ដោយអង្គជំនុំជម្រះធ្វើ -- នឹងចាប់ផ្តើមធ្វើការតាំងសួរដេញដោលស្តាប់សក្ខីកម្មចំពោះសាក្សីដែលមានរហស្សនាម TCW-609 ដែលបានបម្រុងទុករួចហើយនៅ -- ហើយមានវត្តមាននៅក្នុងបរិវេណនៃ អ.វ.ត.ក យើងនេះ។

ហើយដោយឡែកការសួរដេញដោលស្តាប់សក្ខីកម្មសាក្សី សួង ស៊ីគឿន អង្គជំនុំជម្រះលើកបន្តធ្វើនៅថ្ងៃស្អែក ដោយបន្តការតាំងសំណួរដេញដោលដោយក្រុមមេធាវីការពារក្តីលោក អៀង សារី អ៊ីចឹងសូម -- អង្គជំនុំជម្រះអញ្ជើញលោក សួង ស៊ីគឿន និងមេធាវីផង អញ្ជើញមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃស្អែកចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួល ជាមួយនឹងអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនសាក្សីវិលត្រឡប់ទៅកាន់កន្លែងដែលគាត់ស្នាក់នៅវិញ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្ម នៅក្នុងបន្ទប់សវនាការនេះវិញ នៅព្រឹកថ្ងៃស្អែកនៅវេលាម៉ោងប្រាំបួន។

អញ្ជើញលោកមេធាវី!

[១២:០៣:០៨]

**លោក ហ្សាស្តេ ប៉ោ៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបថា លោក នួន ជា សូមអនុញ្ញាតទៅតាមដានល្ងាចនេះពីបន្ទប់ខាងក្រោម គាត់មានឈឺក្បាល ឈឺខ្នង ហើយនិងពិបាកក្នុងការផ្តង់អារម្មណ៍ ហើយខ្ញុំនឹងរៀបចំលិខិតបោះបង់សិទ្ធិជូនតុលាការតាមនីតិវិធី សូមឲ្យគាត់បានទៅតាមដានពីខាងក្រោម។ ហើយសូមអរគុណលោកសាក្សី សួង ស៊ីគឿន ដែលគាត់បានផ្តល់សក្ខីកម្ម និងការប្រឹងប្រែងរបស់គាត់នៅថ្ងៃនេះ។ ហើយក្នុងនាមក្រុមមេធាវីការពារក្តីលោក នួន ជា សូមអរគុណលោក ហើយជាច្រើន ហើយសូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

អង្គជំនុំជម្រះបានស្តាប់សំណើសុំជនជាប់ចោទ នួន ជា ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់ សូមទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយសម្រាប់រយៈពេលធ្វើសវនាការពេញមួយរសៀលនេះ ដោយក្រុមមេធាវីការពារក្តីសន្យាលះបង់សិទ្ធិចូលរួមផ្ទាល់ក្នុងកិច្ចដំណើរការសវនាការនេះរបស់ អៀង សារី មកឲ្យអង្គជំនុំជម្រះ ដោយមូលហេតុដែលមានបញ្ហាសុខភាព។

អង្គជំនុំយល់ឃើញថា សំណើជនជាប់ចោទ នួន ជា ធ្វើឡើងមានមូលហេតុសមស្របអង្គជំនុំជម្រះសម្រេចយល់ព្រមនិងអនុញ្ញាតឲ្យលោក នួន ជា ទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលធ្វើសវនាការពេញមួយថ្ងៃរសៀលនេះ ដោយលោក នួន ជា លះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទាប់សវនាការនេះ។

[១២:០៤:៣៥]

អង្គជំនុំជម្រះតម្រូវឲ្យក្រុមមេធាវីការពារក្តីផ្តល់មកឲ្យអង្គជំនុំជម្រះនូវភ្ជាម នូវពាក្យសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការរបស់លោក នួន ជា ហើយបង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះ អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយនៅក្នុងអំឡុងពេលធ្វើសវនាការពេញមួយរសៀលថ្ងៃនេះ។

បង្គាប់អនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និងលោក ខៀវ សំផន ទៅកាន់បន្ទប់ឃុំខ្លួនខាងក្រោម ដែលនៅរសៀលនេះ ទុកឲ្យលោក នួន ជា នៅក្នុងបន្ទប់ដែលរៀបចំទុកជាស្រេចនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចតាមដាន និងចូលរួមកិច្ចដំណើរការសវនាការពីចម្ងាយ។ ដោយឡែក លោក ខៀវ សំផន ឲ្យនាំខ្លួនគាត់មកកាន់បន្ទប់សវនាការនេះវិញ ឲ្យបានមុនម៉ោងមួយ និងសាមសិបនាទីរសៀល។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០៥ នាទី ដល់ម៉ោង ១៣:៣១នាទី)*

[១៣:៣១:៣៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការសវនាការ។ ហើយនៅរសៀលនេះ ដូចអង្គជំនុំជម្រះបានជម្រាបជូនភាគី និងសាធារណជនរួចហើយ កាលពីពេល មុនពេលសម្រាកថ្ងៃត្រង់ គឺអង្គជំនុំជម្រះនឹងបន្តចាប់ផ្តើមស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម TCW-609។

មន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សី TCW-609 ចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ!

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

[១៣:៣៤:០៧]

សួស្តីសាក្សី! អំមិញសាក្សីបានស្តាប់នូវការណែនាំរបស់មន្ត្រីរដ្ឋបាលតុលាការហើយលើការប្រើឧបករណ៍ក្បាលមីក្រូក្នុងការឆ្លើយតបទៅនឹងសំណួរ។ គឺលោកស្រីនៅពេលដែលមានការតាំងសំណួរចំពោះលោកស្រី សូមលោកស្រីបង្អង់បន្តិច រង់ចាំមើលភ្លើងក្រហមនៅៗក្បាលមីក្រូ ចេញជាសញ្ញាប្រាប់ថាក្បាលមីក្រូប្រតិបត្តិការ សូមលោកស្រីចាប់ផ្តើមនិយាយ ចាប់ផ្តើមឆ្លើយតបនឹងសំណួរ។ ហើយការសម្របសម្រួលនោះ គឺខាង អាយ.វី ទេ គេអ្នកទទួលសម្របសម្រួលក្នុងការចុច ឬបិទ ឬក៏បើក ផ្តាច់ ឬក៏ភ្ជាប់ក្បាលមីក្រូលោកស្រីនោះ។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** តើលោកស្រីប្រាប់ដល់អង្គជំនុំជម្រះបានទេ ថាតើលោកស្រីឈ្មោះអ្វី?

**លោកស្រី ស សៀក៖**

**ឆ៖** ចាស ជាបឋម សូមគោរពលោកប្រធាន ខ្ញុំឈ្មោះ ស សៀក។

**ស៖** បាទ អរគុណ។ ក្រៅពីឈ្មោះ ស សៀក ហ្នឹងតើលោកស្រីមានធ្លាប់ប្រើឈ្មោះអ្វីដែរទេ ជាពិសេស ក្នុងសម័យឆ្នាំ១៩៧០ ឬ៧៩?

**ឆ៖** ចាស ឈ្មោះថ្មីខ្ញុំឈ្មោះៗ ស៊ីម លោកប្រធាន។

[១៣:៣៥:៥០]

**ស៖** អ៊ីចឹងបានសេចក្ដីថា លោកស្រីហ្នឹងគឺឈ្មោះ សៀក ឈ្មោះ ស សៀក ហៅ ស៊ីម អ៊ីចឹងពិតមែនទេ?

**ផ៖** ចាស លោកប្រធាន។

**ស៖** លោកស្រីអាចប្រាប់យើងបានទេថា តើលោកស្រីកើតនៅថ្ងៃខែឆ្នាំណាដែរ?

**ផ៖** ចាស ខ្ញុំកើតនៅឆ្នាំ១៩៥៦ នៅខែ ដូចមិនចាំទេ តែក្នុងនេះមានក្នុងអត្តសញ្ញាណបណ្ណ លោក ហើយកើតនៅភូមិត្រពាំងមានជ័យ ឃុំទឹកថ្លា ស្រុកព្រៃវែង ខេត្តព្រៃវែង។

**ស៖** បាទ អរគុណ។ ហើយតើលោកស្រីសព្វថ្ងៃនេះ តើមានទីលំនៅនៅកន្លែងណា?

**ផ៖** ចាស ខ្ញុំនៅភូមិអូរស្នួត ឃុំតាសាញ ស្រុកសំឡូត ខេត្តបាត់ដំបង។

**ស៖** បាទ អរគុណ។ ហើយតើសព្វថ្ងៃនេះលោកស្រីប្រកបមុខរបររកស៊ីធ្វើអ្វី?

[១៣:៣៧:១២]

**ផ៖** ចាស ធ្វើស្រែចម្ការធម្មតាលោក។

**ស៖** បាទ អរគុណ។ ហើយតើឪពុកបង្កើតរបស់លោកស្រី គាត់ឈ្មោះអ្វីដែរ?

**ផ៖** ចាស ឪពុកនាងខ្ញុំឈ្មោះ ហែម ឈៀ ម្ដាយឈ្មោះ ស សៀ។

**ស៖** បាទ អរគុណ។ ចុះស្វាមីរបស់លោក -- របស់លោកស្រីគាត់ឈ្មោះអ្វី?

**ផ៖** ចាស គ្រួសារខ្ញុំឈ្មោះ សុទ្ធ ថា។

**ស៖** បាទ អរគុណ។ ហើយលោកស្រីមានកូនប៉ុន្មាននាក់?

**ផ៖** ចាស នាងខ្ញុំមានកូនបួននាក់ ប្រុសមួយ ស្រីបី។

**ស៖** បាទ អរគុណ។ លោកស្រី ស សៀក តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការកាលពីព្រឹកមិញនេះថា តាមសមត្ថភាពដែលលោកស្រីអាចដឹង លោកស្រីមិនមានចំណងញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងបីរូប គឺលោក នួន ជា, អៀង សារី, ខៀវ សំផន ហើយក៏ដូចគ្នាដែរគឺមិនមានញាតិលោហិត ឬក៏ញាតិពន្ធជាមួយនឹងបុគ្គលទាំងឡាយដែលត្រូវបានទទួលយកជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងរឿងក្ដីនេះទេ។ តើជាការពិតមែនដែរឬទេ?

[១៣:៣៨:៥២]

**ផ៖** ចាស ពិតមែន។

**ស៖** បាទ អរគុណ។ ហើយក្រឡាបញ្ជីបានរាយការណ៍ផងដែរថា លោកស្រីបានធ្វើសម្បថ

រួចហើយ គឺកាលពីម្សិលមិញថ្ងៃ១៤ ខែសីហា នៅចំពោះមុខអ្នកតាដំបងដែក។ តើពិតមែនដែរទេ?

**ឆ៖** ចាស ពិតមែន។

**ប្រធានអង្គជំនុំ៖**

លោកស្រី ស សៀក យើងប្រាប់អំពីសិទ្ធិ និងករណីយកិច្ចក្នុងនាមលោកស្រីធ្វើជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះនាពេលនេះ។ អំពីសិទ្ធិលោកស្រីក្នុងនាមជាសាក្សីក្នុងកិច្ចដំណើរការនីតិវិធីសវនាការនៅចំពោះមុខអង្គជំនុំជម្រះនេះ លោកស្រីអាចបដិសេធក្នុងការឆ្លើយទៅនឹងសំណួរ ឬការសុំឲ្យលោកស្រីធ្វើអំណះអំណាងណាមួយ ឬច្រើនដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង។ គឺសិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងខ្លួនឯង មានន័យថា មានតែចម្លើយ -- ដោយសារតែចម្លើយ ឬអំណះអំណាងរបស់លោកស្រីនោះ នាំឲ្យលោកស្រីនឹងត្រូវទទួលរងនូវការចោទប្រកាន់។

[១៣:៣៩:៥៧]

ហើយអំពីករណីយកិច្ចលោកស្រី ក្នុងនាមជាសាក្សីត្រូវតែផ្តល់សក្ខីកម្មនៅក្នុងកិច្ចដំណើរការសវនាការនេះ។ នៅចំពោះមុខអង្គជំនុំជម្រះ លោកស្រីត្រូវឆ្លើយតបសំណួរទាំងឡាយដែលភាគី ឬអង្គជំនុំជម្រះបានសួរចំពោះលោកស្រី លើកលែងតែក្នុងករណីការឆ្លើយទៅនឹងសំណួរ ឬការធ្វើអត្ថាធិប្បាយណាមួយ ឬច្រើន ដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង គឺសិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ ហើយលោកស្រីត្រូវតែឆ្លើយការណ៍ដែលពិត ដែលខ្លួនបានឃើញ បានដឹង បានឮ បានចាំ ឬក៏ធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬក៏បានធ្វើការកត់សម្គាល់ដោយផ្ទាល់នូវព្រឹត្តិការណ៍ ព្រឹត្តិហេតុទាំងឡាយដែលពាក់ព័ន្ធទៅនឹងសំណួរទាំងឡាយដែលភាគី ឬចៅក្រមអង្គជំនុំជម្រះសួរលោកស្រី។ តើលោកស្រីយល់ទេ?

**លោកស្រី ស សៀក៖**

ចាស លោកប្រធាន។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** តើលោកស្រីធ្លាប់បានផ្តល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេត នៃការិយាល័យស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទេកន្លងមក? ហើយប្រសិនបើមាន ធ្វើនៅប៉ុន្មានដង? ហើយនៅទីកន្លែងណា? នៅពេលណា?

[១៣:៤១:១៩]

**លោកស្រី ស សៀក៖**

**ឆ៖** ចាស លោកប្រធាន ខ្ញុំបានជួប និងធ្វើបទសម្ភាសន៍ជាមួយខាងក្រុមការងារនៅភូមិរបស់នាងខ្ញុំ ហើយនិងនៅផ្ទះរបស់នាងខ្ញុំ។ តែខែថ្ងៃឆ្នាំ នាងខ្ញុំអាចមិនបានចាំជាក់លាក់ទេ តែមាននៅក្នុងកំណត់ហេតុ។

**ស៖** បាទ អរគុណ។ ហើយប៉ុន្មានលើកដែរលោកស្រី ចាំទេ?

**ឆ៖** ចាស តែមួយលើកលោក។

**ស៖** បាទ អរគុណ។ ហើយនៅមុនពេលចូលមកចំពោះអង្គជំនុំជម្រះនាពេលនេះ តើលោកស្រីបានពិនិត្យមើល ឬអាន ឬក៏ស្តាប់ការអានរបស់អ្នកណាម្នាក់នូវកំណត់ហេតុស្តាប់ចម្លើយរបស់លោកស្រីដែលលោកស្រីបានធ្វើជាមួយអ្នកស៊ើបអង្កេតនៃការិយាល័យស៊ើបអង្កេតកន្លងមក ដើម្បីរំឭកការចងចាំដែរឬទេ?

**ឆ៖** ចាស ក្នុងក្រុមការងារបានជួយសម្របសម្រួល ដើម្បីឲ្យនាងខ្ញុំអាននូវសេចក្តីសម្ភាសជាចម្លើយដើមរបស់នាងខ្ញុំខ្លះៗមកហើយ។

[១៣:៤២:៣៦]

**ស៖** ក្រោយពេលអានហើយ -- តើលោកស្រីអាចបញ្ជាក់បានដែរទេថា កំណត់ហេតុស្តាប់ចម្លើយលោកស្រី ដែលលោកស្រីបានអាន ដើម្បីរំឭកការចងចាំនោះ តើពិតជាត្រឹមត្រូវ និងស៊ីសង្វាក់គ្នាស្របទៅនឹងចម្លើយ ដែលលោកស្រីបានធ្វើសម្ភាសកាលពីមុនជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យស៊ើបអង្កេតដែរឬទេ?

**ឆ៖** ចាស លោកប្រធាន នាងខ្ញុំចង់និយាយថា ឆាប់ចាំ ហើយក៏ឆាប់ភ្លេច។ អាចនឹងភ្លេចខ្លះៗមិនចាំទាំងអស់នៅលើកិច្ចសម្ភាសន៍របស់ខ្លួនឯងពីមុនមក។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយអង្គជំនុំជម្រះសូមជម្រាបជូននូវតំណាងសហព្រះរាជអាជ្ញាថា ក្នុងកិច្ចដំណើរការសវនាការពិភាក្សាដេញដោលក្នុងការស្តាប់សក្ខីកម្មសាក្សីរូបនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាមុនភាគីឯទៀតនៃរឿងក្តី។ អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា។ សូមអញ្ជើញ!

[១៣:៤៤:០៦]

**លោក វ៉េង ហ៊ត់៖**

សូមគោរពលោកប្រធាន។ សូមគោរពក្រុមប្រឹក្សានៃអង្គចៅក្រមទាំងមូល។ សូមគោរពលោក លោកស្រីទាំងអស់ដែលចូលរួមនៅក្នុងអង្គសវនាការនេះ។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក វ៉េង ហ៊ត់៖**

សួស្តីលោកស្រី ស សៀក ខ្ញុំមកពីការិយាល័យសហព្រះរាជាអាជ្ញា។ ខ្ញុំមានសំណួរមួយចំនួន សួរទៅលោកស្រី ប្រសិនបើសំណួររបស់ខ្ញុំសួរទៅលោកស្រីស្តាប់មិនបាន ឬក៏លឿនពេក លោកស្រីកុំពិបាកចិត្តអី គ្រាន់ប្រាប់ខ្ញុំថាសំណួរលោកលឿនណាស់ សុំឱ្យសួរមួយសាទៀត។ ខ្ញុំឯកភាព។

**ស៖** ឥឡូវនេះ ខ្ញុំសួរសំណួរលោកស្រីតែម្តង។ សំណួរទី១ របស់ខ្ញុំគឺសួរថា នៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ តើលោកស្រីដឹងហេតុការណ៍អ្វីខ្លះ ដែលកើតឡើងនៅទីក្រុងភ្នំពេញទេ?

**លោកស្រី ស សៀក៖**

**ឆ៖** ចាស លោក អង្កាល់ពីឆ្នាំ១៩៧៥ នៅទីក្រុងភ្នំពេញ ពេលនោះ ស្រុកយើងហៅថា ស្រុករំដោះ កងទ័ពយើងដែលបានវ៉ៃរំដោះទីក្រុងភ្នំពេញទាំងស្រុង។ ហើយហេតុការណ៍ ដែលនាងខ្ញុំបានដឹងនៅពេលនោះ នាងខ្ញុំបានចូលមកនៅកន្លែងម្តុំស្តាត ក៏ឃើញមានកងទ័ពស្រីប្រុស មានឃើញឧបករណ៍ជាអាវុធ ជារថក្រោះ កាំភ្លើងតូចធំ យន្តហោះ ហើយនិងឃើញប្រជាជនដែលត្រូវជម្លៀសចេញពីទីក្រុងនៅសល់មួយខ្សែលោក។

**ស៖** អរគុណលោកស្រី។ ខ្ញុំចង់សួរថយក្រោយបន្តិចថា មុនពេលដែលលោកស្រីដឹងថាទីក្រុងភ្នំពេញត្រូវបានគេវាយបែក ឬក៏រំដោះនោះ តើលោកស្រីចូលមកទីក្រុងភ្នំពេញ នៅថ្ងៃរំដោះតែម្តង ឬមួយក៏មានការសម្រាកនៅទីណាដែរ?

**ឆ៖** ចាស ថ្ងៃ១៧ មេសា នៅអង្គភាពក្រុមសិល្បៈនាងខ្ញុំ បានធ្វើដំណើរ និងត្រៀម -- ការពិតគឺធ្វើដំណើរចេញមកតាមស្រែវាល ស្ពឺ ហ្គឹង ហើយឆ្លងមកតាមផ្លូវវិហារសួគ៌ ហើយមកសម្រាកនៅភ្នំអដ្ឋវស្សបីយប់លោក។

**ស៖** ខ្ញុំពិនិត្យឃើញថា ជាទូទៅ កាលណាគេបែកទីក្រុងភ្នំពេញ ប្រជាជនត្រូវបានគេជម្លៀសចេញ ដូចលោកស្រីនិយាយអម្បាញ់មិញ។ ចុះលោកស្រីមានតួនាទីអី បែរជា១ វាយបែកទីក្រុងភ្នំពេញ បែរជាលោកស្រីចូលមកទីក្រុងភ្នំពេញវិញ? កាលនុ៎ងលោកស្រីមានតួនាទីអី បានអាចចូលបានបញ្ជោស

គ្នាអ៊ីចឹង?

[១៣:៤៧:៥៦]

**ធ៖** ចាស ខ្ញុំគ្មានតួនាទីអីទេ ជាក្រុមសិល្បៈមក ក៏មកក្នុងអង្គភាព។ ក្រុមសិល្បៈហ្នឹងឲ្យមកថា ពេលដែលយើងរំដោះទីក្រុងហើយ សិល្បៈចូលមកនៅកន្លែងឃោសនាការ ដើម្បីបម្រើការងារហ្នឹង។ អ៊ីចឹងលោក។

**ស៖** ចូលមកកន្លែងមកឃោសនាការដំបូង ឬមួយចូលនៅក្នុងអង្គភាពផ្សាយ ឈ្មោះអង្គភាពផ្សព្វផ្សាយហ្នឹងឈ្មោះអីដែរ?

**ធ៖** ចាស អង្គភាពហ្នឹង អង្គភាពសិល្បៈស-៦ ពីមុនមក។

**ស៖** លោកស្រីបាននិយាយអម្បាញ់មិញថា នៅពេលដែលលោកស្រីចូលមកដល់ទីក្រុងភ្នំពេញនេះ លោកស្រីសម្រាក ឬក៏នៅភ្នំអង្គរស្ស តើនៅទីនោះប៉ុន្មានយប់ដែរលោកស្រី?

**ធ៖** ចាស ក្រុមនាងខ្ញុំសម្រាកបីយប់។

**ស៖** ក្នុងពេលដែលលោកស្រីសម្រាកនោះ តើលោកស្រីបានឃើញផ្ទាល់ភ្នែកនូវមេដឹកនាំណាខ្លះដែលនៅភ្នំអង្គរស្សហ្នឹង?

[១៣:៤៩:៣០]

**ធ៖** ចាស លោក ខ្ញុំនិយាយថយក្រោយវិញ ពីព្រោះអី កាលដែលធ្វើដំណើរទៅដល់នៅជិតស្ពឺ ខ្ញុំធ្វើដំណើរមួយក្រុមខ្ញុំហ្នឹងទៅ ខ្ញុំឃើញលោក ខៀវ សំផន នៅម្តុំជិតស្ពឺ ស្រែវាល ឃើញលោកជិះឡានតូចមួយ *អាស៊ីមីស័រ* ចិន។ តែដំណើរគាត់ អាចទៅមុនក្រុមនាងខ្ញុំ ពីព្រោះអី ក្រុមនាងខ្ញុំជិះឡាន *អាស៊ីន* ហើយដឹកសម្ភារៈសិល្បៈក្នុងមួយអង្គភាពហ្នឹង ឡានមួយហ្នឹង។

**ស៖** លោកស្រីថា បានឃើញលោក ខៀវ សំផន ជិះឡាន តើគាត់ជិះឡានតែម្នាក់ឯង ឬក៏មានក្រុមណាដែលគាត់ទៅជាមួយទេ ពេលនុ៎ង?

**ធ៖** ចាស គាត់ជិះឡានជាមួយនឹងស្រីៗ ពីរនាក់។ ស្រីៗពីរនាក់ហ្នឹង អ្នកអានវិទ្យុចល័ត ហើយតែកុងឡានហ្នឹង ខ្ញុំភ្លេចឈ្មោះហើយ មិនបានស្គាល់ឈ្មោះ។

[១៣:៥១:០៦]

**ស៖** លោកស្រីនិយាយអម្បាញ់មិញថា នៅសំណួរទី១ របស់ខ្ញុំនោះ លោកស្រីបាននិយាយថា ឃើញប្រជាជនហ្នឹង ជម្លៀសចេញ ហើយជម្លៀសហ្នឹងខុសទិសដៅ។ មួយខ្សែហ្នឹង គេជម្លៀសហ្នឹង

តើប្រជាជនហ្នឹងច្រើនទេ ពេលដែលលោកស្រីឃើញហ្នឹង ជម្លៀសចុងក្រោយហ្នឹង?

**ឆ៖** ចាស ច្រើនលោក ប្រហែលជាគ្នាកាន់ម៉ឺននាក់ដែរ លោក។

**ស៖** ហើយគេជម្លៀសហ្នឹងត្រូវតាមទិសដៅដែលប្រជាជនត្រូវទៅ ឬក៏ខុសទិសដៅ លោកស្រី?

**ឆ៖** ចាស ការជម្លៀសហ្នឹង ខ្ញុំទៅជួបនឹងមុខស្អាតហ្នឹង ប្រជាជនមកពីមាត់ទន្លេវិញហើយ តាមឮមនុស្សម្នាដែលនៅជុំវិញហ្នឹង ហើយនិងប្រធានសិល្បៈខ្ញុំហ្នឹង ឈ្មោះ មិត្តសៅ ហ្នឹង ប្រាប់ថា ប្រជាជនហ្នឹងជម្លៀសខុសទិស។ មិនមែនចេញទៅថា ខាងព្រៃកក្តាមទេ ពីព្រោះអីប្រជាជនហ្នឹង ស្រុកកំណើតនៅខាងពាយ័ព្យភ្នំពេញវិញ។

[១៣:៥២:៣៨]

**ស៖** ខ្ញុំសួរលោកស្រីបន្តទៀត នៅពេលដែលប្រជាជនដែលជម្លៀសនោះ តើលោកស្រីឃើញថា កាលនោះ ស្ថាប័នណាដែលគ្រប់គ្រងប្រជាជន ដូចជា យោធា ឬមួយខាងស៊ីវិល គេជាអ្នកបញ្ជាឲ្យជម្លៀសហ្នឹង?

**ឆ៖** ចាស លោក ខ្ញុំអត់ដឹងថា កងទ័ព ឬមួយក៏ខាងស៊ីវិលផង ព្រោះអី ខ្ញុំមកពីបឃើញប្រទះនៅនឹងតែម្តង។

**លោក វ៉េង ហ៊ាត់៖**

អរគុណលោកប្រធាន ខ្ញុំសូមបង្ហាញឯកសារទាក់ទងនឹង E3/379 ហើយ ERN ខ្មែរ 00294801, ERN អង់គ្លេស 00323324 ទៅដល់ 25, ERN ជាភាសាបារាំង 00385196។

សូមលោកប្រធានអនុញ្ញាត បាទ។

[១៣:៥៤:០១]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារ ជាក្រដាសពីតំណាងសហព្រះរាជអាជ្ញា យកជូនសាក្សីពិនិត្យ!

**សួរដោយលោក វ៉េង ហ៊ាត់៖**

**ស៖** ខ្ញុំសូមសួរ -- ខ្ញុំសូមបញ្ជាក់ជូនលោកស្រី។ កាលនោះ ចៅក្រមស៊ើបអង្កេត លោកស្រីបានផ្តល់យោបល់យ៉ាងប្រាកដថា "ខ្ញុំឃើញការជម្លៀសនោះ គឺឃើញសុទ្ធតែទ័ព ប៉ុន្តែខ្ញុំមិនស្គាល់ថា កងពលណាទេ។ ពេលនោះមានភ្លៀងទៀត មានរលឹម មានអាប់អួរ មេឃងងឹត មានអាវុធរាយប៉ាយ

ចោល បាឡូ ខោអាវស្បែកជើង"។ ចំណុចហ្នឹងលោកស្រីមានការបន្ថែមអីទៀតទេ ឬក៏លោកស្រីយល់យ៉ាងម៉េចដែរ កិច្ចដែលលោកស្រីបានឆ្លើយហ្នឹង?

**ឆ៖** ចាស លោកប្រធាន ចំណុចនេះហ្នឹងប្រហែលជាការសួរនិងការនិយាយហ្នឹងប្រហែលជាវាមិនបានដកឃ្លា ឬមួយយ៉ាងម៉េចទេ ព្រោះខ្ញុំមិនមែនទ័ពទេ ជម្លៀសហ្នឹងគឺប្រជាជនអ្នកជម្លៀស។ បើខ្ញុំចង់និយាយថាពេលនុ៎ង កងទ័ពនៅហ្នឹងមាន តែកងទ័ពខ្មែរក្រហម។ ចាស ខ្ញុំចង់បញ្ជាក់ប៉ុណ្ណឹងលោក។

**ស៖** ប្រហែលជាកំហុសខ្ញុំ លោកស្រី។ អ៊ីចឹង ខ្ញុំសួរលោកស្រីម្តងទៀត ថាប្រជាជនហ្នឹងត្រូវបានគេជម្លៀសហើយ ពពាក់ពពូនណ៎ានៅក្នុងហ្នឹង ក៏ប៉ុន្តែអ្នកណាអ្នកគ្រប់គ្រងប្រជាជននៅទីនេះ? គឺគ្រប់គ្រងប្រជាជនក្នុងការជម្លៀសឲ្យចេញពីទីក្រុងភ្នំពេញហ្នឹង? ហើយក្នុងនេះលោកស្រីថា ឃើញសុទ្ធតែទ័ព ដែលគ្រប់គ្រងប្រជាជន។ តើពាក្យហ្នឹងលោកស្រីនៅរក្សាដូច្នេះ ឬមួយក៏លោកស្រីកែប្រែ?

[១៣:៥៦:៣៧]

**ឆ៖** ចាស លោកកន្លែងនេះ ខ្ញុំចង់វែកញែក ហើយបញ្ជាក់បន្តិច មិនមែនកងទ័ពទេជម្លៀសហ្នឹងនោះ ហើយខ្ញុំក៏មិនដឹងថាពីណាអ្នកគ្រប់គ្រងប្រជាជនអ្នកជម្លៀសហ្នឹងដែរ។ តែគ្រាន់តែថាឃើញគេជម្លៀសខុសទិស តែប៉ុណ្ណឹង។

**ស៖** អរគុណលោកស្រី។ ចុះចំណុចមួយទៀត លោកស្រីថាកងទ័ពជម្លៀសហ្នឹងលោកស្រីមិនឯកភាពទេ។ តើលោកស្រីឯកភាពទេដែលថាការជម្លៀសហ្នឹង មាន -- ពេលនោះមានភ្លៀងរលឹមមេឃងងឹត? តើលោកស្រីឯកភាពទេចំណុចហ្នឹង?

**ឆ៖** ចាស ខ្ញុំឯកភាព។

**ស៖** អរគុណ។ ខ្ញុំនឹងសួរសំណួរទាក់ទងនឹងនេះហ្នឹងតទៅទៀត។ នៅពេលដែលលោកស្រីដឹងថា ពេលដែលជម្លៀសនេះ ប្រជាជនជម្លៀសទាំងភ្លៀង ទាំងងងឹត តើស្ថានភាពនៃការជម្លៀសទាំងមេឃងងឹតនោះ ខ្ញុំចង់សួរថា តើលោកស្រីបានដឹងទេ នៅពេលដែលស្ត្រីភេទ ដែលគាត់ទើបតែសម្រាលកូន និងស្ត្រីដែលពោះធំ ដែលត្រៀមសម្រាលកូននោះ តើអង្គការនោះ ដែលឲ្យជម្លៀសហ្នឹង គេមានរៀបចំកន្លែងសម្រាប់គាត់ដែរឬទេ?

[១៣:៥៨:១០]

**ឆ៖** ចាស ត្រង់ចំណុចនេះ នាងខ្ញុំមិនបានដឹងទេ ពីព្រោះអី គេធ្វើយ៉ាងម៉េចឲ្យតែប្រជាជនចេញ

ឲ្យស្អាតនៅទីក្រុង។ គឺថាឲ្យប្រជាជនចេញឲ្យទៅស្រុកកំណើតវិញ ត្រង់ថាពោះធំ ឬមួយក៏គ្រប់ខែអី នាងខ្ញុំមិនបានពិនិត្យទេ គ្រាន់តែឈរមើល។

**ស៖** លោកស្រីបានឈរមើល ចង់និយាយថាឈរមើលស្ត្រីដែលឆ្លងទន្លេ ហើយនិងទុក្ខវេទនាដែលស្ត្រីគ្រប់ខែហ្នឹង ឬក៏យ៉ាងម៉េច?

**ឆ៖** នាងខ្ញុំមិនបានឃើញមានអ្នកពោះធំផង។ គ្រាន់ឃើញបងប្អូនរុញឡាន មានរទេះ មានអីពពាក់ពពូន ដូចយើងរត់អ៊ីចឹង។

**ស៖** អរគុណលោកស្រី។ ខ្ញុំទៅសំណួរមួយទៀត។ លោកស្រីបានមានប្រសាសន៍ថានៅមន្ទីរ ស-៦ ផ្សាយផ្នែកវិទ្យុ។ អ៊ីចឹងខ្ញុំសួរថា នៅពេលដែលទុក្ខវេទនាប្រជាជនត្រូវបានគេជម្លៀសទាំងភ្លៀងរលឹម ទាំងមេឃងងឹត តើវិទ្យុហ្នឹង គេមានផ្សាយពីការលំបាករបស់ប្រជាជនហ្នឹងដែរទេ?

[១៣:៥៩:៤៥]

**ឆ៖** ចាស លោក ភ្លាមៗនោះ វិទ្យុចល័តផ្សាយតែពីរំដោះទីក្រុង។

**ស៖** ខ្ញុំបន្តទៅសំណួរមួយទៀត។ ខ្ញុំសួរ នៅថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ វិទ្យុនោះផ្សាយៗ ក្រៅពីរំដោះហ្នឹង មានផ្សាយឲ្យប្រជាជនធ្វើសកម្មភាពយ៉ាងម៉េចខ្លះដែរទេ?

**ឆ៖** អត់ទេលោក។ ផ្សាយតែពីរឿងរំដោះទីក្រុងតែប៉ុណ្ណោះ រឿងការជម្លៀសអីក៏អត់មានផ្សព្វផ្សាយដែរ។ និយាយតែពីរឿងការឈ្នះ រំដោះប្រទេសតែម្តង។

**ស៖** អរគុណ។

[១៤:០១:00]

**លោក វ៉េង ហ៊ៀត៖**

លោកប្រធាន ខ្ញុំសូមអាននូវឯកសារដដែលទេ រំឭកសាក្សីបន្តិច។

**សួរដោយលោក វ៉េង ហ៊ៀត៖**

**ស៖** លោកស្រីបានឆ្លើយនៅក្នុងចម្លើយដដែលនេះ ខ្លឹមសារគឺថា “បានឲ្យប្រជាជនលើកទង់ស និងដាក់អាវុធ។ ប្រជាជនដាក់ទង់សតាមផ្ទះ”។ តើលោកស្រីមានការផ្លាស់ប្តូរទេគំនិតហ្នឹង?

**លោក គង់ សំអុន៖**

សូមអធ្យាស្រ័យលោកប្រធាន សូមតំណាងសហព្រះរាជអាជ្ញាបញ្ជាក់អំពីអត្តសញ្ញាណ។

ខ្ញុំនិយាយម្តងទៀត ខ្ញុំសូមតំណាងសហព្រះរាជអាជ្ញា សូមលោកប្រធានអនុញ្ញាតឲ្យបង្ហាញ

អត្តសញ្ញាណឯកសារ។ អំមិញបានប្រាប់ហើយ ប៉ុន្តែទីតាំងថាលេខ ERN នៅត្រង់ណាអត់ទាន់បានបញ្ជាក់បាទ។ សូមអរគុណ។

[១៤:០២:០០]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ដើម្បីឲ្យជាប្រយោជន៍ក្នុងការតាមដានភាគីដទៃទៀត និងអង្គជំនុំជម្រះផង សូមលោកតំណាងសហព្រះរាជអាជ្ញាបង្ហាញនូវលេខទំព័រ គឺលេខ ERN ដែល -- នៃឯកសារដែលលោកមានបំណងក្នុងការតាំងសំណួរដេញដោលចំពោះសាក្សី ដើម្បីឲ្យភាគី និងអង្គជំនុំជម្រះបានផ្ទៀងផ្ទាត់ និងពិនិត្យមើលនូវឯកសារនោះដោយផ្ទាល់។

**លោក វើង ហ៊ត់៖**

អរគុណលោកប្រធាន។ ឯកសារដែលខ្ញុំបានបង្ហាញអម្បាញ់មិញនេះ ខ្មែរ ERN 00294802, ERN ជាភាសាអង់គ្លេស 00323326, ERN ជាភាសាបារាំង 00385197។

**សួរដោយលោក វើង ហ៊ត់៖**

**ស៖** ខ្ញុំសូមបញ្ជាក់លោកស្រីម្តងទៀត។ លោកស្រីបានមានប្រសាសន៍ប្រាប់ទៅអ្នកស៊ើបអង្កេតថា "ពេលនោះគឺឲ្យលើកទង់ស និងដាក់អាវុធ" ហើយលោកស្រីបាននិយាយថា "ប្រជាជនដាក់ទង់សតាមផ្ទះ"។ តើអ៊ីចឹងមែនទេ លោកស្រី?

[១៤:០៣:៤៦]

**លោកស្រី ស សៀក៖**

**ឆ៖** ចាស ត្រង់ចំណុចនេះ នាងខ្ញុំមកឃើញនៅតាមផ្ទះបងប្អូនប្រជាជន អ្នកខ្លះហូតដល់ដំបូលផ្ទះហើយ អ្នកខ្លះនៅពាក់កណ្តាល អ្នកខ្លះទើបនឹងចង។ ហើយនៅតាមស្ពាតក៏បានហូតគ្រប់ថែង។

**ស៖** លោកស្រីបានៗឃើញប្រជាជនហូត ឬមួយក៏ពេលហ្នឹងគេផ្សាយឲ្យប្រជាជនហូតទង់ជ័យស ហើយបន្ទាប់មកបានឃើញប្រជាជនហ្នឹងហូតទង់ជ័យសដូចលោកស្រីបានបញ្ជាក់អំមិញ តើអ៊ីចឹងមែនទេ?

**ឆ៖** ចាស ចំណុចត្រង់នេះ ៣ថ្ងៃទើបនាងខ្ញុំចូលដល់ភ្នំពេញ។ ដូច្នេះក្រោយ៣ថ្ងៃ បាននាងខ្ញុំឃើញ។ ឃើញទង់សនៅទីក្រុង ពីព្រោះអីថ្ងៃរំដោះ ថ្ងៃ១៧ មេសា នាងខ្ញុំមិនទាន់ធ្វើដំណើរមកដល់ទេ។ ចាស មកដល់អដ្ឋរស្ស ខ្ញុំសម្រាក៣យប់នៅហ្នឹងទៀត ក្រុមនាងខ្ញុំទាំងអស់គ្នា។

[១៤:០៥:០២]

**ស៖** ខ្ញុំសូមសួរបញ្ជាក់លោកស្រី សំណួរមួយសាទៀត ថាតើវិទ្យុហ្នឹងគេមានផ្សាយឲ្យប្រជាជនលើកទង់សអ៊ីចឹងដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកស្រីមេធាវី!

**កញ្ញា អង់តា ហ្គីសសេ៖**

ជម្រាបសួរលោកប្រធាន។ សូមអរគុណលោក លោកស្រីចៅក្រមទាំងអស់ជាទីគោរព ហើយនិងភាគីទាំងអស់ជាទីគោរព។ ខ្ញុំសូមកាត់ផ្តាច់ហ្នឹងដោយមូលហេតុដដែលៗទេ ព្រោះថាឥឡូវនេះ អ្នកនិយាយសុទ្ធជាខ្មែរទាំងអស់ ហើយអ៊ីចឹងត្រូវពេលដែលសួរចប់ហើយសម្រាកបន្តិច ហើយឆ្លើយហើយសម្រាកបន្តិច។ ហើយនៅពេលដែលសាក្សីហ្នឹងឆ្លើយចប់ហើយនុ៎ង ត្រូវតែឈប់បន្តិចដើម្បីមុននឹងចាប់ផ្តើមសួរទៀត ព្រោះលើកនេះដូចរាល់ដងដែរ គឺថាយើងពិបាកតាមការបកប្រែជាភាសាបារាំង។ ខ្ញុំសូមរំឭកទៀត រំឭកអំពីសារៈសំខាន់នៃការសម្រាកបន្តិចសិន នៅពេលដែលសាក្សី -- ខ្ញុំគិតថាដូចមានបញ្ហាអ្វីមួយមានសំឡេងខុសពីប្រក្រតី។

[១៤:០៦:១៦]

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលខាងអង្គភាពបកប្រែភាសា ដើម្បីដោះស្រាយបញ្ហា អត់មានការបកប្រែភាសាអង់គ្លេសទេ។

បាទ អរគុណច្រើននូវការកត់សម្គាល់នេះ ដោយខ្ញុំខ្មែរ ហើយអ្នកសួរខ្មែរ អ្នកឆ្លើយខ្មែរអ៊ីចឹងដូចអត់មានបញ្ហាអីទេ អ៊ីចឹងដោយសារមិនឆ្លងកាត់ការបកប្រែទើបមិនបានដឹង អំពីព័ត៌មានស្តីពីបញ្ហាប្រឈម នៃការបកប្រែមិនទាន់។ ឥឡូវច្បាស់លាស់ហើយ សូមឲ្យតំណាងសហព្រះរាជអាជ្ញាជាតិសួររួចបង្អង់បន្តិច ហើយដូចគ្នានៅពេលដែលគាត់ឆ្លើយចប់ឲ្យបង្អង់បន្តិច ដើម្បីឲ្យផ្តល់ឱកាសពេលវេលាសមស្របសម្រាប់អ្នកបកប្រែហ្នឹង បកប្រែបានអស់សេចក្តីនូវសំណួរនិងចម្លើយ។

សូមអញ្ជើញ!

[១៤:០៨:០២]

**សួរដោយលោក វ៉េង ហ៊ត់៖**

**ស៖** ខ្ញុំសូមបញ្ជាក់លោកស្រីម្តងទៀតនូវសំណួរ។ ថាតើនៅពេលដែលទីក្រុងភ្នំពេញជិតបែកនោះ តើមានការផ្សាយឲ្យប្រជាជន ឬក៏កងទ័ពរបស់ លន់ នល់ ហ្នឹងដាក់អាវុធចុះលើកទង់សអីដែរទេពេលហ្នឹង?

**លោកស្រី ស សៀក៖**

**ឆ៖** ចាស ចំណុចត្រង់នេះនាងខ្ញុំស្តាប់មិនបានទេលោក។ ថាអត់ដឹងចុះ។

**ស៖** ខ្ញុំសួរលោកស្រីមួយសាទៀត តើក្រុមចល័តនេះនៅអំឡុងពេលនោះ អ្នកណាគេគ្រប់គ្រងវិទ្យុចល័តហ្នឹង?

**ឆ៖** ចាស វិទ្យុចល័តនេះ ខ្ញុំអត់ដឹងថាពីណាមួយជាអ្នកទទួលខុសត្រូវទេ ពីព្រោះអីផ្នែកខ្ញុំជាផ្នែកសិល្បៈទេ តែគ្រាន់ថាន័យដែលថាវិទ្យុចល័តនេះ គឺបម្រើតែសមរភូមិមួយគត់សម្រាប់តែកងទ័ព។ ចាស ទី១ គឺថាលើកទឹកចិត្តដល់ការប្រយុទ្ធ ចាស ហើយជាដំណឹងដែលយើងឈ្នះនៅម្តុំនេះម្តុំនោះតែប៉ុណ្ណឹងលោក។

**ស៖** អរគុណលោកស្រី។ ខ្ញុំសួរសំណួរទាក់ទងនឹងក្រសួងឃោសនាការវិញ។ នៅក្នុងក្រសួងឃោនាការ តើលោកស្រីដឹងថា អ្នកណាគ្រប់គ្រងទាំងរដ្ឋបាល ទាំងបច្ចេកទេសនៅក្នុងក្រសួង?

**ឆ៖** ចាស នៅក្នុងក្រសួងនាងខ្ញុំ គឺមានលោក ហ៊ូ នឹម ជាប្រធាន ហើយពេលរំដោះទីក្រុងភ្នំពេញថ្មីៗនោះ មានលោក ទីវ អុល គាត់ជំនួយការ។ តែអនុប្រធាន នាងខ្ញុំភ្លេចបាត់ហើយ តែក្រោយមកលោក ទីវ អុល ក៏គាត់ចេញពីក្រសួងហ្នឹង មិនដឹងទៅនៅឯណាដែរ។ ខ្ញុំនៅតែជាមួយលោក ហ៊ូ នឹម។

**ស៖** បាទ ឥឡូវសំណួរបន្ទាប់ទៀត។ នៅពេលលោកស្រីចូលទៅធ្វើការនៅក្រសួងឃោសនា-ការ ពេលនោះលោកស្រីបានឃើញថាទេថា មន្ត្រីរដ្ឋការនៃរបប លន់ នល់ ទាំងនោះត្រូវបានគេជម្លៀសចេញ ឬទេ? អានេះសំណួរទី១។ សំណួរទី២ តើមនុស្សនៅសេសសល់ខ្លះទេ តាមដែលលោកស្រីបានដឹងជាក់ស្តែងនោះបាទ?

**ឆ៖** ចាស ខ្ញុំសូមឆ្លើយទៅនឹងសំណួរនេះ ព្រោះនាងខ្ញុំឃើញពិតៗនៅក្នុងក្រសួងឃោសនាការមកដល់ពួកបច្ចេកទេសចាស់ ខាងវិទ្យុចាស់ គាត់អត់មានទៅណាទេ គាត់នៅហ្នឹង សម្រាប់មកប្រាប់ទីកន្លែង ឬមួយក៏បន្ទប់ថតតូច ធំ ដល់ពួកក្រុមសិល្បៈនាងខ្ញុំលោក។ ប៉ុន្តែមន្ត្រីរាជការអីធំៗទៀត នាង

ខ្ញុំអត់បានដឹងទេ ពីព្រោះខ្ញុំចូលទៅនៅតែកន្លែងហ្នឹង អត់មានបានដើរទៅណាទេ។

**លោក វ៉េង ហ៊ាត់៖**

លោកប្រធាន ខ្ញុំសូមអានចម្លើយកាលពីលោកស្រីគាត់ឆ្លើយនៅ -- គាត់ប្រាប់ទៅចៅក្រមស៊ើបសួរនៅក្នុង ERN 00294801 ជាភាសាខ្មែរ, ដល់ពេលភាសាអង់គ្លេស 00323325, ភាសាបារាំង 00385196។

**សួរដោយលោក វ៉េង ហ៊ាត់៖**

**ស៖** លោកស្រីពេលនោះបានប្រាប់ទៅអ្នកស៊ើបអង្កេតថា នៅពេលទៅដល់ក្រសួងឃោសនា-ការ ពួកសិល្បៈចាស់ៗត្រូវបានគេជម្លៀសចេញអស់ហើយ។ តើលោកស្រីមានការប្រែប្រួល ឬក៏យល់ព្រមយ៉ាងម៉េចដែរលើអ្វីដែលលោកស្រី បានបង្ហាញទៅក្រុមអ្នកស៊ើបអង្កេតនោះ?

**លោកស្រី ស សៀក៖**

**ឆ៖** ចាស ខ្ញុំសូមបញ្ជាក់ ត្រង់ថា ការភ្លេចភ្លាំង ដូចថាសំណួរលោកប្រធានសួរមកចំណុចណាខ្ញុំឆ្លើយចំណុចហ្នឹង ប៉ុន្តែមិនបានអស់។ ការពិតសិល្បៈចាស់ៗអត់មាននៅទេ មានតែបច្ចេកទេស។ ចាស ខ្ញុំអត់បានបញ្ជាក់ត្រង់ហ្នឹង។ អត់មានឃើញនៅហ្នឹងទេ។ តែគ្រាន់ថា ធម្មតាកន្លែងធ្វើការអ៊ីចឹងដល់ម៉ោងបានបងប្អូនមកធ្វើ មកថតមកផ្សាយអីអ៊ីចឹងណាលោក ជារបៀបរបបមិនខុសយើងទេ ហើយឲ្យខ្ញុំទៅដឹងថា គាត់នៅត្រង់ណាៗ អត់ដឹង។ វាអត់ឃើញនៅក្នុងកន្លែងធ្វើការហ្នឹង អត់ឃើញ។ ឃើញតែខាងបច្ចេកទេស ប្រាំមួយនាក់នៅហ្នឹងមែន។

[១៤:១៥:០៥]

**ស៖** អរគុណលោកស្រី។ អ៊ីចឹង ខ្ញុំទៅសំណួរមួយទៀត តើលោកស្រីមានការផ្សាយផ្សព្វវិទ្យុអំពីសហករណ៍ ការបង្កបង្កើនផល និងការជីកភ្លឺស្រែ ទំនប់ទឹកដែរទេ នៅពេលហ្នឹង?

**ឆ៖** ចាស លោក ខ្ញុំមិនមែនជាតួនាទីអ្នកផ្សាយវិទ្យុទេ សំខាន់គឺសិល្បៈ តែគ្រាន់ថា នៅក្នុងចង្កោមជាមួយគ្នា នាងខ្ញុំ អាចដឹងខ្លះ។ មាន ចាស។ មានការជំរុញប្រជាជនបង្កបង្កើនផល ធ្វើស្រែដើម្បីដោះស្រាយជីវភាព ហៅម៉េចថា “ម្ចាស់ការខ្លួនឯង ខ្លួនឧបត្ថម្ភខ្លួន” ហ្នឹងពីសម័យនោះ។

**ស៖** ខ្ញុំសួរទៅសំណួរមួយទៀត ក្នុងស្ថានភាពដែលលោកស្រីបានដឹងពីកិច្ចការផ្សាយនេះ នៅក្នុងក្រុមតែមួយ ដូចលោកស្រីបានមានប្រសាសន៍អម្បាញ់មិញ។ អ៊ីចឹង ខ្ញុំសូមសួរលោកស្រីថាតើកម្មវិធីផ្សាយ គេមានផ្សាយអំពីជម្លោះដែនកោះ? ជម្លោះព្រំដែនគោក និងបញ្ហាជម្លោះតាមព្រំដែន

វៀតណាម ដែរទេ ដែលលោកស្រីបានដឹងជាក់ស្តែង?

[១៤:១៧:០៥]

**ឆ៖** ចាស សំណួរនេះពិតមែន។ ព្រោះអី ខ្ញុំមិនចាំឆ្នាំៗណោះឮថាទាហានវៀតណាមវ៉ៃយកកោះត្រល់ កោះអីហ្នឹង គឺមែនលោក។

**ស៖** ទន្ទឹមនឹងការផ្សាយ ស្តីពីការវ៉ៃយកកោះត្រល់ តើវិទ្យុហ្នឹងមានៗផ្សាយធ្វើឱ្យប្រជាជនឈឺចាប់ ដោយសារបញ្ហាទឹកដីហ្នឹងដែរទេ?

**ឆ៖** ចាស សំណួរនេះ ត្រឹមត្រូវហើយលោក ពីព្រោះអី យួនឈ្លានពាន ពេលនោះ ប្រជាជនខ្លាចបាត់បង់ទឹកដី។ ដូច្នេះ វិទ្យុតែងតែមានការអប់រំ។ មានការ ដើម្បីដាស់អារម្មណ៍ឱ្យមានការឈឺចាប់ការពារទឹកដីខ្លួនឯង។

**ស៖** ចំណុចនេះ ខ្ញុំចង់សួរលោកស្រីត្រង់ហ្នឹងដែរ ថាតើបំផុសការឈឺចាប់នេះ គឺគេនិយាយថាម៉េចខ្លះ ដែលលោកស្រីបានចាំនៅក្នុងកាលៈទេសៈនុ៎ង?

**ឆ៖** ចាស ការផ្សាយផ្សព្វ ដើម្បីអប់រំប្រជាជនឱ្យយល់អំពីប្រទេសជិតខាង ដែលរំលោភឈ្លានពាននៅព្រំដែន។ ដូច្នេះ ឱ្យមានការឈឺចាប់ លះបង់កូនចៅ ដើម្បីថាជួយការពារទឹកដី។

**ស៖** អរគុណលោកស្រី ខ្ញុំសួរលោកស្រីមួយសំណួរទៀតទេ ហើយបន្ទាប់មក លោកស្រីជួយឆ្លើយនូវសហការីដែលធ្វើការជាមួយខ្ញុំសួរលោកស្រីបន្ត បាទ។ សំណួរចុងក្រោយនេះ ខ្ញុំសួរលោកស្រីថាក្រៅពីមេដឹកនាំ ខៀវ សំផន ដែលលោកស្រីបានឃើញគាត់ផ្ទាល់ តើមានមេដឹកនាំណាផ្សេងទៀតដែលលោកស្រីបានឃើញទេ នៅក្នុងស្ថានភាពនោះ?

[១៤:២០:០៩]

**ឆ៖** ចាស លោក នៅក្នុងសំណួរនេះ ខ្ញុំបាន -- ក្រៅពីលោកប្រធាន ខៀវ សំផន ខ្ញុំបានជួបលោក សុន សេន នៅស្តាត។ ក្រុមខ្ញុំទាំងអស់គ្នា មិនមែនខ្ញុំម្នាក់ឯងទេ។ ប្រហែលជាថ្ងៃល្ងាចម៉ោងប្រាំចូលទៅដល់ស្តាតហ្នឹង ជួបគាត់នៅហ្នឹង គាត់ក៏មកអបអរ ហើយចាប់ដៃចាប់ជើង សួរសុខទុក្ខធម្មតានៅស្តាត។ ឃើញគាត់នៅហ្នឹង ជួបនៅហ្នឹង តែក្នុងនៅក្នុងកិច្ចសម្ភាសន៍នេះ ហាក់បីដូចថានាងខ្ញុំឆ្លើយមក អ្នកកំណត់ហេតុថា ដូចថាសរសេរថាខ្ញុំបានធ្វើដំណើរមកជាមួយគាត់ពីមុន ការពិតមិនមែនទេត្រង់ហ្នឹង។ ជួបគាត់នៅស្តាតហ្នឹងតែម្តង លោក សុន សេន។

**ស៖** នៅក្នុងការបង្ហាញនៅក្នុងកំណត់ហេតុរបស់ចៅក្រមស៊ើបសួរ ខ្ញុំឃើញលោកស្រីបង្ហាញ

ក្រៅពីលោក ខៀវ សំផន លោកស្រីក៏បានដឹងផងដែរនៅលោក អៀង សារី។ ហើយលោកស្រីបានបញ្ជាក់ថា កាលណោះ អៀង សារី គាត់ធ្វើការនៅក្រសួងការបរទេស។ ក៏ប៉ុន្តែខ្ញុំ -- លោកស្រីមានយោបល់អីទេ? បើសិនជាគ្មានទេ ខ្ញុំសូមបញ្ចប់សំណួរបាទ។ អរគុណ។

[១៤:២១:៥៤]

**ឆ៖** អត់ទេលោក ខ្ញុំអត់បានឃើញផង។ នេះគ្រាន់ថាសួរបៀបថាស្គាល់ឬអត់ប៉ុណ្ណឹង។ នាងខ្ញុំឆ្លើយថាស្គាល់។

**លោក វ៉េង ហ៊ត់៖**

អរគុណលោកស្រី។ អរគុណលោកប្រធាន និងក្រុមប្រឹក្សាជំនុំជម្រះ។ ខ្ញុំអស់សំណួរប៉ុណ្ណេះហើយ។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញ!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរអស់លោក លោកស្រីចៅក្រម។

ជម្រាបសួរលោកស្រី ស សៀក។ ដំបូងខ្ញុំសូមអរគុណលោកស្រីដែលបានអញ្ជើញធ្វើដំណើរវែងឆ្ងាយ ដើម្បីមកជួយដល់តុលាការរំឭកឡើងវិញនូវអ្វីដែលបានកើតឡើងចន្លោះពីឆ្នាំ៧៥ ដល់៧៩។

[១៤:២៣:១៧]

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** ខ្ញុំចង់ចាប់ផ្តើមនោះគឺ ខ្ញុំសូមចូលទៅដល់មន្ទីរដែលលោកស្រីធ្វើការនោះ រហូត -- មន្ទីរដែលលោកស្រីធ្វើការរហូតមកដល់ថ្ងៃ១៧ មេសា ៧៥។ តើមន្ទីរដែលលោកស្រីធ្វើការនេះ ជាស្ថានីយផ្សាយវិទ្យុហ្នឹងដែលថាជាមន្ទីរស-២០ ហ្នឹងមែនទេ? ថាតើស-២០ នោះមានទីតាំងនៅត្រង់ -- សូមទោស! តើស-៦ នោះមានទីតាំងនៅត្រង់ណាដែលលោកស្រី?

**លោកស្រី ស សៀក៖**

**ឆ៖** ចាស ខ្ញុំសូមឆ្លើយនូវសំណួរនេះ។ ស-៦ ហ្នឹងនៅស្រុកស្ទឹងត្រង់ខាងជើងលោក។ តែកន្លែងស-៦ ខ្ញុំសូមបញ្ជាក់ដែរ មិនមែនជាស្ថានីយវិទ្យុទេ គឺជាកន្លែងក្រុមសិល្បៈតែម្តង។

**ស៖** សូមអរគុណលោកស្រីដែលបានបញ្ជាក់ចំណុចនេះ។ តើស្ថានីយផ្សាយវិទ្យុនោះមានទីតាំង

នៅស្ទឹងត្រង់ជាមួយគ្នាហ្នឹងដែរឬក៏យ៉ាងណា?

[១៤:២៤:៥៤]

**ឆ៖** ចាស លោក ពីជំនាន់ហ្នឹងនាងខ្ញុំទើបនឹងមក ខ្ញុំជាបុគ្គលិកថ្មីដែរទេ។ មកដល់គេរៀបចំឱ្យថតចម្រៀង ថតអីហ្នឹង ផ្ញើទៅវិទ្យុយើងនៅស្រុកយួននោះ តែវិទ្យុ ចល័តក្រោយនេះ សម្រាប់កងទ័ពហ្នឹងទើបនឹងកើតក្រោយទេ។ តែថតចម្រៀង ថតអីតិចតួចហ្នឹង គឺផ្សាយនៅហាណូយ។

**ស៖** តើមានសម្ភារៈឧបករណ៍សម្រាប់ផ្សាយសំឡេងនៅស្ទឹងត្រង់ដែរឬទេ?

**ឆ៖** ចាស វិទ្យុចល័តមានកើតក្រោយ ហ្នឹងសម្រាប់តែកងទ័ព ដូចខ្ញុំបានឆ្លើយនូវសំណួរលោកប្រធានរួចមកហើយ។

**ស៖** សូមអរគុណលោកស្រី។ លោកស្រីចាំទេ ថាតើវិទ្យុផ្សាយសំឡេងហ្នឹងគេបង្កើតឡើងនៅឆ្នាំណាដែរ?

**ឆ៖** ចាស ខ្ញុំអត់ដឹងទេ។ ខ្ញុំទើបមកឆ្នាំ៧៣ ខ្ញុំអត់ដឹងផង។

**ស៖** អរគុណលោកស្រី។ ក្រៅពីមន្ទីរ -- ស្ថានីយផ្សាយសំឡេងនៅមន្ទីរស-៦ ហ្នឹង ថាតើមានអង្គភាពណាដែលមានទីតាំងនៅកន្លែងហ្នឹងដែរឬទេ? អង្គភាពផ្សេងៗដែលមានទីតាំងនៅកន្លែងស្ថានីយវិទ្យុហ្នឹងដែរឬទេ?

**ឆ៖** ចាស លោកនៅត្រពាំងថ្មហ្នឹងមានមន្ទីរស-៦ មន្ទីរក-១៨ និងមន្ទីរប-២០ និងមន្ទីរ១៩។ ហ្នឹងនៅជិតៗគ្នា។

**ស៖** លោកស្រីអាចជម្រាបជូនតុលាការបានទេ ថាតើប-២០ ហ្នឹងជាស្អីដែរ?

**ឆ៖** ចាស លោកមន្ទីរហ្នឹងហាក់ដូចជាថា មន្ទីរ របៀបដូចថាចែកចាយជាសម្ភារៈហូប។ សំខាន់គឺស្បៀងទៅតាមអង្គភាពតូចៗនៅត្រពាំងថ្មហ្នឹង។

[១៤:២៨:០៣]

**ស៖** លោកស្រីអាចនៅចាំបានទេ ថាតើមានតាៗ គឺមេដឹកនាំធ្វើការនៅកន្លែងទីតាំងនោះដែរឬទេ?

**ឆ៖** ចាស លោក អ៊ំៗពីសម័យហ្នឹង ខ្ញុំមិនដឹងថាចំណុចគាត់នៅត្រង់ណាទេ ប៉ុន្តែគ្រាន់ថាប្រហែលជានៅត្រពាំងថ្មហ្នឹង។ ព្រោះអីនៅនោះជាមូលដ្ឋានរបស់ផងគាត់។

**ស៖** តើមន្ទីរក-១៨ ហ្នឹងទទួលខុសត្រូវខាងផ្នែកអីដែរលោកស្រី?

**ផ៖** ចាស មន្ទីរក-១៨ ភាគច្រើន សុទ្ធស្រីៗនៅកាត់ដេរ ហើយដាំបន្លែបង្ការអីខ្លះ តែប៉ុណ្ណឹងលោក។

**ស៖** លោកស្រីបានជម្រាបមកយើងខ្ញុំថា នៅពេលដែលលោកស្រីចេញដំណើរពីតំបន់នោះមកកាន់ក្រុងភ្នំពេញ នៅពេលមួយនោះគឺលោកស្រីបានឃើញ ខៀវ សំផន ធ្វើដំណើរតាមរថយន្ត។ ធ្វើម៉េចបានលោកស្រីដឹងថា គាត់ជា ខៀវ សំផន? តើលោកស្រីធ្លាប់ស្គាល់គាត់ពីមុនដែរឬទេ?

[១៤:២៩:៥៨]

**ផ៖** ចាស ខ្ញុំស្គាល់។

**ស៖** តើលោកស្រីអាចជម្រាបជូនតុលាការបានទេថា លោកស្រីធ្លាប់ឃើញលោក ខៀវ សំផន ពីមុនៗមកហ្នឹង នៅកន្លែងណាដែរ?

**ផ៖** ចាស ខ្ញុំស្គាល់តាមរយៈបុណ្យទាន ពេលដែលចូលឆ្នាំអី លោកទៅចូលរួមម្តងម្កាល។

**ស៖** លោកស្រី នៅពេលនោះលោកស្រីដឹងទេថា លោក ខៀវ សំផន ហ្នឹងមានតួនាទីអ្វីដែរ?

**ផ៖** ចាស ខ្ញុំមិនបានចាំទេលោក។ ចាស អត់បានចាំ មិនដឹងគាត់មានតួនាទីអីផង ប៉ុន្តែគ្រាន់តែឃើញថា គាត់អាចគ្រប់គ្រងផ្នែកអីមួយប៉ុណ្ណឹង។

**ស៖** នៅពេលដែលលោកស្រីថា ដែលៗ -- គាត់ប្រហែលជាកាន់កាប់ផ្នែកៗណាមួយនោះ ធ្វើម៉េចបានឲ្យលោកស្រីគិតអ៊ីចឹង? ហេតុអីបានជាលោកស្រីគិតយ៉ាងដូច្នេះ?

[១៤:៣១:៤១]

**ផ៖** ចាស ព្រោះអីតាមខ្ញុំយល់ ព្រោះអីគាត់រួមចំណែកក្នុងការដឹកនាំមួយចំណែកដែរ បានខ្ញុំយល់ដូច្នេះ។

**ស៖** សូមអរគុណ។ នៅពេលនោះដែរ លោកស្រីបាននិយាយពីមុនមកថា លោកស្រីបានជួប ហ៊ូ នឹម និង សុន សេន ក្រោយថ្ងៃ១៧ មេសា។ តើលោកស្រីស្គាល់មនុស្សទាំងពីរនាក់នេះពីមុនមកទេ? តើលោកបានជួបមនុស្សទាំងពីរនាក់នេះញឹកញាប់ប៉ុនណាដែរ?

**ផ៖** ចាស លោក ខ្ញុំស្គាល់តាមរយៈដូចថា លោក ទីវ អុល វិញ កាលពីឆ្នាំ៧៣ គាត់បានចុះទៅតាមភូមិភាគ។ ខ្ញុំធ្លាប់នៅភូមិភាគបូព៌ា ដូច្នេះគាត់អាចចុះទៅ គាត់មាននិស្ស័យខាងសិល្បៈអ៊ីចឹង គាត់ទៅជួយកែលម្អអីនៅសិល្បៈស្រុក នៅខាងស្រុកព្រៃវែងនាងខ្ញុំ បានជាខ្ញុំស្គាល់។ ចំណែកលោក ហ៊ូ នឹម ខ្ញុំស្គាល់តាមរយៈដែលគាត់គ្រប់គ្រងនៅនឹងក្រសួងខ្ញុំហ្នឹងតែម្តង។

[១៤:៣៣:២៥]

**ស៖** ដូច្នេះខ្ញុំចង់បញ្ជាក់ឲ្យច្បាស់ថា លោកជួបលោក ហ៊ូ នឹម គឺក្រោយ១៧ មេសា ទេ អ៊ីចឹង ឬយ៉ាងណា?

**ឆ៖** ចាស លោក ហ៊ូ នឹម មែនទែន ខ្ញុំស្គាល់តាំងពីនៅក្នុងព្រៃនោះ ក៏ប៉ុន្តែគ្រាន់ថា ស្គាល់ជាក់លាក់មែនទែននៅនឹងក្រសួងឃោសនា ដែលក្រោយរំដោះនេះហើយលោក។

**ស៖** សូមអរគុណ។ សំណួរចុងក្រោយទាក់ទងទៅនឹងមនុស្សប៉ុន្មាននាក់នេះ។ តើលោកស្រីធ្លាប់ស្គាល់ សុន សេន ដែរឬទេ មុន១៧ មេសា?

**ឆ៖** ចាស ធ្លាប់ឮឈ្មោះ។

**ស៖** សូមអរគុណលោកស្រី។ ឥឡូវខ្ញុំសូមចូលទៅវិទ្យុ ស្ថានីយវិទ្យុចល័តឡើងវិញ។ លោកដឹងថា អ្នកណាជាអ្នករៀបចំស្ថានីយវិទ្យុចល័តនោះ?

**ឆ៖** អត់ដឹងទេលោក។

**ស៖** លោកស្រីអាចស្តាប់ការផ្សាយចេញពីស្ថានីយវិទ្យុហ្នឹងមុនថ្ងៃ១៧ មេសា អាចស្តាប់បានដែរឬទេ? អាចស្តាប់ឮដែរឬទេ?

**ឆ៖** ចាស វិទ្យុហ្នឹងឮតិចបានចម្ងាយមិនឆ្ងាយ ចង់និយាយថាសមរភូមិដាក់ជិតៗសមរភូមិទេ មិនមែនឮច្រើនគឺឡូទេលោក។ ហើយការផ្សាយក៏តិចម៉ោងបំផុតដែរ តែនាងខ្ញុំមិនបានចាំថាមួយថ្ងៃប៉ុន្មានពេល ប៉ុន្មានម៉ោង នាងខ្ញុំមិនបានចាំទេ។

**ស៖** អរគុណ។ លោកស្រីបានជម្រាបជូនសហការីរបស់ខ្ញុំដែលថា វិទ្យុផ្សាយសំឡេងចល័តនេះគឺសម្រាប់បម្រើកងទ័ព និងដើម្បីជំរុញស្មារតីកងទ័ពឲ្យក្លាហាន។ ខ្ញុំចង់សួរថា តើលោកស្រី ឬក៏នៅពេលនោះសហការី ឬក៏មិត្តរបស់លោកស្រីនោះស្តាប់វិទ្យុផ្សាយសំឡេងហ្នឹងបានដែរទេ? ស្តាប់ឮដែរទេ?

**ឆ៖** ចាស បើនៅជិតៗស្តាប់បានលោក នៅឆ្ងាយចាប់មិនបានទេ។

[១៤:៣៦:៥៣]

**ស៖** សូមអរគុណ។ លោកស្រីបានជម្រាបមកយើងខ្ញុំថា នៅថ្ងៃ១៧ មេសា ហ្នឹង គឺ មានការផ្សាយអំពីថា ទីក្រុងភ្នំពេញត្រូវបានរំដោះក្រោយពេលលោកស្រីចេញពីស្ទឹងត្រង់មក? តើលោកស្រីចំណាយពេលប៉ុន្មានថ្ងៃ ចេញដំណើរពីស្ទឹងត្រង់ប-២១ ហ្នឹងមកភ្នំមួយ ដែលលោកស្រីស្នាក់នៅហ្នឹង?

**ឆ៖** ចាស ចេញមកថ្ងៃ១៧ មេសា មកដេកនៅភ្នំចិដ្ឋរស្សបីយប់ មកដេកនៅវាលស្រែមួយមានកូនខ្ទមស្បូវហួសៗឧដុង្គ មកសម្រាកនៅវាលស្រែហ្នឹងមួយយប់ទៀត ល្ងាចប្រហែលជាម៉ោងប្រាំបានក្រុមនាងខ្ញុំចូលមកដល់ស្តាតអូឡាំពិក។ អ៊ីចឹងឡើងបួនយប់។

**ស៖** ទីតាំងដែលលោកស្រីស្នាក់នៅអស់រយៈពេលបីយប់ ខ្ញុំគ្រាន់តែចង់បញ្ជាក់ថា តើខ្ញុំនិយាយទីតាំងនោះត្រឹមត្រូវដែរឬក៏អត់? ហើយខ្ញុំអានជាភាសាអង់គ្លេស ប្រសិនណាជាខ្ញុំអានឈ្មោះមិនត្រូវទេសូមជួយប្រាប់ខ្ញុំផង។ គឺ លោកមកស្នាក់នៅភ្នំមួយហៅថា ភ្នំអដ្ឋរស្ស នៅជិតឧដុង្គ តើបើសិនណាខ្ញុំអានឈ្មោះទៅខុសជួយប្រាប់ខ្ញុំផង តើភ្នំឈ្មោះអ៊ីចឹងមែនទេ?

[១៤:៣៨:៤៩]

**ឆ៖** ចាស ជាសាមញ្ញ ខ្ញុំហៅថាភ្នំចិដ្ឋរស្ស ដល់ឥឡូវនេះបងប្អូនថា អដ្ឋរស្សម៉េច? ខ្ញុំស្គាល់តែចិដ្ឋរស្ស ព្រោះអីវត្តហ្នឹងទៅហួសពីវត្តមួយនៅលើភ្នំ ហើយមានបឹងឈូកមួយយ៉ាងធំនៅវត្តហ្នឹង។ ខ្ញុំមិនដែលស្គាល់ដែរនៅភូមិសាស្ត្រហ្នឹង ប៉ុន្តែបងប្អូនភាគច្រើនគេស្គាល់ គេថាភ្នំចិដ្ឋរស្ស។ អ៊ីចឹង អស់លោកចង់ដឹងច្បាស់ ទាល់តែសួរប្រជាជនខ្ញុំនៅហ្នឹងទៅ ខ្ញុំអត់ស្គាល់ដែរ ដឹងតែចិដ្ឋរស្ស។

**ស៖** សូមអរគុណច្រើន។ ខ្ញុំគ្រាន់តែចង់ដឹងឈ្មោះទីកន្លែងនោះឲ្យបានពិតប្រាកដ។ តើភ្នំហ្នឹងនៅជិតឧដុង្គ ឬក៏អត់ទេ?

**ឆ៖** ខ្ញុំចេញមកដើរមក ធ្វើដំណើរមក វាគ្រាន់ថាផ្លូវមិនសូវស្អាត ពេលនុ៎ងយូរដែរទម្រាំដល់ឧដុង្គ តែឥឡូវនេះខ្ញុំវង្វេងហើយលោក មិនដឹងឯណាផង សូម្បីតែទីក្រុងភ្នំពេញមិនដឹងថាកន្លែងខ្លួនឯងធ្លាប់នៅត្រង់ណាផង។

**ស៖** តើត្រឹមត្រូវដែរទេ ដែលថាលោកស្រីចេញដំណើរពីស្ទឹងត្រង់នៅថ្ងៃ១៧ មេសា ហើយលោកស្រីមកភ្នំនេះ ដែលថាស្នាក់នៅ នៅថ្ងៃតែមួយហ្នឹង តើអ៊ីចឹងមែនទេ?

**ឆ៖** ចាស លោក ខ្ញុំមកដល់ព្រែកក្តាម ប៉ុន្តែពេលនោះ ខ្ញុំវានៅក្មេងដែរ តែខ្ញុំមានសភាពងងឹតភ្នែកគេហៅថា ពាក្យសាមញ្ញថា ងងឹតមាន់។ ដូច្នេះពេលដែលឆ្លងកាណូត ក៏គេដឹកដៃខ្ញុំចុះក្នុងកាណូតដែរ ឆ្លងព្រលប់ៗហើយ។ ចាស គឺថ្ងៃហ្នឹង ក្នុងល្ងាចថ្ងៃ១៧ មេសា ហ្នឹង ដែលខ្ញុំមកដល់ភ្នំចិដ្ឋរស្ស តែខ្ញុំឆ្លងកាណូតនៅ ខ្ញុំហៅគេប្រាប់ថា ហ្នឹងហើយព្រែកក្តាម។ ប៉ុន្តែគេដឹកដៃខ្ញុំចុះនៅក្នុងកាណូតហ្នឹងខ្ញុំងងឹតមាន់លោក។ មិនដឹងថា ខាងជើង ខាងត្បូង ខាងណាទេ តែដល់ឡើងទៅដល់គោក គេប្រាប់ថាត្រង់នេះហើយហៅថាអី វិហារសួគ៌។ ហ្នឹងតាមខ្ញុំចាំ លោក។

**ស៖** សូមអរគុណច្រើន។ នៅពេលលោកស្រីមកដល់ឧដុង្គ តើលោកស្រីអាចជម្រាបជូនតុលាការបានទេ លោកស្រីបានឃើញអ្វីខ្លះ? ហើយបានឃើញមនុស្សប៉ុន្មាននាក់ដែរនៅទីនោះ?

**ឆ៖** ចាស លោកមកដល់ផ្សារហ្នឹង ក្រុមនាងខ្ញុំដើរ និងធ្វើដំណើរកាត់ផ្ទះបងប្អូនមានផ្ទះថ្ម ផ្ទះចិនអីហ្នឹង ឃើញបងប្អូននៅកុះករ តាមផ្ទះតាមសម្បែងធម្មតា។

[១៤:៤២:១២]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទីចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាក នៅបន្ទប់រង់ចាំសម្រាប់សាក្សីរូបនេះក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញមកកាន់កន្លែងផ្តល់សក្ខីកម្ម នៅក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤២ នាទី ដល់ម៉ោង ១៥:០៣ នាទី)*

[១៥:០៣:០៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។ សូមអញ្ជើញ!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោកស្រី ស សៀក ខ្ញុំចង់បន្តពីអ្វីដែលយើងបានឈប់អម្បាញ់មិញ នៅពេលដែលលោក

ស្រីបានមកដល់ឧដុង្គ។ ប្រសិនបើជាខ្ញុំសួរ ចង់សួរលោកស្រីដំបូងបំផុតហ្នឹង ថាតើមានមនុស្សប៉ុន្មាននាក់ដែលមករួមដំណើរជាមួយលោកស្រី ហើយបានចាកចេញពីតំបន់ស្ទឹងត្រង់មក នៅក្នុង -- មុនថ្ងៃទី១៧ មេសា ឆ្នាំ៧៥ ហ្នឹងបាទ?

**លោកស្រី ស សៀក៖**

**ឆ៖** ចាស លោកប្រធាន។ ចាស លោក នៅក្នុងក្រុមសិល្បៈនាងខ្ញុំទាំងមូលមក ខ្ញុំមិនចាំចំនួនទេ ទាំងប្រុស ទាំងស្រី ទាំងកុមារ ក៏មានដែលមក រួមទាំងឧបករណ៍មកមួយចប់។ មានភ្លេង មានស្គរ មានទ្រ អ៊ីចឹងទៅលោក។

[១៥:០៤:២៥]

**ស៖** ហើយថាតើមានអ្នកផ្សេងទៀត ដែលគាត់ធ្វើការនៅតំបន់ស្ទឹងត្រង់ហ្នឹង ថាមានអ្នកណាផ្សេងទៀត ដែលមកពីក្រុមផ្សេង ដែលគាត់មកចូលរួមជាមួយក្រុមលោកស្រី ដែលគាត់ត្រូវធ្វើដំណើរបន្តមកឧដុង្គនោះជាមួយលោកស្រី នៅចាំទេបាទ?

**ឆ៖** ចាស ដែលនាងខ្ញុំដែលបានដំណើរមកហ្នឹង គឺជាមួយលោក ហ៊ូ នឹម, ទីវ អុល មកជាមួយប៉ុន្តែគ្រាន់តែមកដល់ អង្គរស្សនេះ គាត់អាចចេញមកមុននាងខ្ញុំ ពីព្រោះអីនៅតែក្រុមពួកនាងខ្ញុំទេដែលធ្វើដំណើរមកក្រោយ។

**ស៖** អ៊ីចឹង បើសិនយើងក្រឡេកមើលទៅលើស្ថានភាព១ នៅឧដុង្គនៅពេលនោះ តើមានអ្នកផ្សេងទៀត ក្រៅពីក្រុមសិល្បៈរបស់លោកស្រី ហើយនិងអ្នកដែលលោកស្រីមកជាមួយហ្នឹង ថាតើមានអ្នកផ្សេងទៀតទេ ដែលធ្វើការក្នុងក្រុមអ្នកដឹកនាំដែលមកពីប្រទេសកម្ពុជា ហើយគេមកជាមួយ -- ហើយមក១ឧដុង្គជាមួយគ្នាដែរ កាលពីមុន គាត់ជាអ្នកដឹកនាំដែលមានមូលដ្ឋាននៅស្ទឹងត្រង់នោះ?

**ឆ៖** ចាស សំណួរលោកសួរនេះ ខ្ញុំចង់ឆ្លើយថា មកហ្នឹង ពីមុន ខ្ញុំរួមដំណើរដែលមកជួបនឹងលោក ខៀវ សំផន ប៉ុន្តែលោក ខៀវ សំផន ក៏ចូលក្នុងអង្គរស្សហ្នឹង ខ្ញុំឃើញតែរយៈពេលខ្លី ហើយក្រោយមក ដែលខ្ញុំធ្វើដំណើរមកនេះ មកតែពួកខ្ញុំទេ អត់បានឃើញគាត់ទេ ព្រោះគាត់ជិះឡានតូចផ្សេង។

[១៥:០៦:៥៥]

**ស៖** គ្រាន់តែចង់បញ្ជាក់ឡើងវិញទៅចំណុចនេះ លោកស្រីបានលើកឡើងអំពី ប-២០ ហើយនិង ក-១៨ អី នៅស្ទឹងត្រង់ហ្នឹង ថាតើអ្នកដែលនៅនុំង គាត់មកឧដុង្គដូចគ្នាអត់ទេ ជាមួយលោកស្រី

នោះ កាលពីថ្ងៃ មុនថ្ងៃទី១៧ ខែមេសានោះ?

**ឆ៖** ចាស អង្គភាពគេផ្សេងៗ ខ្ញុំមិនបានដឹងទេ ព្រោះថាក្រុមនាងខ្ញុំ ដែលខ្ញុំបានចង់ចាំថាធ្វើដំណើរមកឯករាជ្យ។

**ស៖** អរគុណ។ លោកស្រីបានលើកឡើងថា ក្រុមរបស់លោកស្រីទាំងមូលបានមកជាមួយនឹង ទីវ អុល ហើយនិង ហ៊ូ នឹម ហើយលោកស្រីក៏បានប្រាប់តុលាការផងដែរ ថាលោកស្រីបានជួបជាមួយនឹង លោក ខៀវ សំផន។ តើគេធ្វើអី នៅពេលនោះ នៅពេលដែលលោកស្រីមកដល់ខដុង្គនោះ លោកស្រីឃើញគេធ្វើអីនៅពេលនោះ?

[១៥:០៨:២២]

**ឆ៖** ចាស ខ្ញុំជួបគាត់តាមផ្លូវ គាត់ជិះឡានធម្មតា។ តែមកដល់ អង្គរស្ស្សហ្នឹង គ្រាន់តែឃើញគាត់សម្រាកមួយភ្លែត តែមិនដឹងគាត់ទៅណា។ តែសកម្មភាពរបស់គាត់ធម្មតា ចុះសម្រាកអីធម្មតា។ ហើយខាងខ្ញុំរវល់តែការងារពេលនុ៎ង ចង់និយាយថា មមាញឹក ហាត់ៗ ច្រៀងនៅតាមផ្លូវ ពេលដែលសម្រាកហ្នឹង មិនបានសម្រាកទេ។ ហាត់នៅតាមវិហារលោក សម ហាត់ហ្នឹង គឺសមគ្នា ដើម្បីឲ្យវាស្អាត់ ឲ្យចាំ នូវបទចម្រៀងខ្លះ។

**ស៖** តើស្ថានីយវិទ្យុចល័តដែលលោកស្រីបានលើកឡើងហ្នឹង ពេលគេមក គេរើមកជាមួយលោកស្រីដែរ នៅពេលដែលលោកស្រីមកខដុង្គហ្នឹង ឬក៏យ៉ាងម៉េចដែរ?

**ឆ៖** ចាស វិទ្យុតូចហ្នឹងមកដែរ ប៉ុន្តែគេ -- ខ្ញុំធ្វើដំណើរមកជួបនៅម្តុំស្ពឺស្រែវាល លោក។ គេមកៗ ចូលភ្នំពេញដែរ។ ក្រោយមក បុគ្គលិកគាត់ប៉ុន្មាននាក់ហ្នឹង មកចូលរួមធ្វើការងារនៅឃោសនាការហ្នឹងទាំងអស់គ្នា។ តែវិទ្យុហ្នឹងក៏គេឈប់ប្រើហើយក្រោយមក ប្រើតែប៉ុស្តិ៍វិទ្យុនៅឃោសនាការនៅក្បែរវត្តភ្នំហ្នឹងមួយ។

[១៥:១០:០០]

**ស៖** សូមអរគុណ។ នៅពេលដែលលោកស្រី ធ្វើដំណើរចាកចេញពីស្ទឹងត្រង់រហូតមកដល់អង្គរស្ស្សនេះ តើស្ថានីយវិទ្យុចល័តហ្នឹងនៅតែបន្តផ្សាយនូវកម្មវិធីវិទ្យុរបស់ខ្លួនទៀត ឬក៏យ៉ាងម៉េចបាទ?

**ឆ៖** ចាស មិនទាន់ចូលភ្នំពេញ នៅបន្តផ្សាយ ដល់ចូលមកដល់ស្អាតហើយ ឈប់។ មកដល់ឃោសនាការ បងប្អូនហ្នឹងរៀបចំ។ មិនមែនមកដល់ភ្លាមបានផ្សាយវិទ្យុធំហ្នឹងភ្លាមទេលោក ទម្រាំរៀបចំអាក់ខាន២-៣ថ្ងៃដែរ។ ទម្រាំរៀបចំស្គាល់បន្ទប់ ស្គាល់កន្លែងថត ស្គាល់អី។ ខាន ១ថ្ងៃ ២ថ្ងៃដែរ។

**ស៖** បើអ៊ីចឹង តើលោកស្រីនៅចាំបានទេ ថាតើមានហេតុផលអីដែលលោកស្រីមកស្នាក់នៅបណ្ដោះអាសន្ននៅតំបន់អង្គរស្សឺហ្នឹងរយៈពេល៣យប់ មុនពេលដែលលោកស្រីត្រូវបន្តដំណើរមកទីក្រុងភ្នំពេញទៀតហ្នឹង។ ហេតុអីបានជាត្រូវស្នាក់នៅនុ៎ង?

[១៥:១១:១៤]

**ឆ៖** ចាស ដំបូងឡើយនាងខ្ញុំមិនដឹងថាមានហេតុផលអីទេ ក៏ប៉ុន្តែដល់ចូលមកដល់ស្ពាតហ្នឹងឃើញប្រជាជនជម្លៀសមិនទាន់អស់ហ្នឹង។ តាមនាងខ្ញុំវិភាគ ហើយឮប្រធានខ្ញុំឈ្មោះ សៅ គាត់និយាយថា យើងមិនទាន់បានចូលដោយសារប្រជាជនមិនទាន់ជម្លៀសអស់។

**ស៖** ដើម្បីឲ្យយើងកាន់តែយល់អំពីបញ្ហានេះបានច្បាស់បន្ថែមទៀតនឹងអ្វីដែលលោកស្រីបានដឹងនៅពេលនោះ ខ្ញុំចង់បង្ហាញនូវសម្រង់នៃមួយដែលគេផ្ដល់ឲ្យនៅការិយាល័យសហចៅក្រមស៊ើបអង្កេត។

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាននេះ គឺឯកសារ E3/379 ជាឯកសារដែលសហសេរីករបស់យើងបានប្រើកាលពីមុនដែរ ហើយខ្ញុំចង់ជូនឯកសារនេះទៅសាក្សី បើសិនជាមានការអនុញ្ញាតពីលោកប្រធាន។ ហើយខ្ញុំនឹងជម្រាបជូននូវលេខ ERN នៅពេលក្រោយ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! ប៉ុន្តែទំនងជាមានហើយឬនៅ? ម៉េចបានទទួលម្ដងហើយ? អនុញ្ញាត! សូមមន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញាយកជូនសាក្សីពិនិត្យ។

[១៥:១២:៥៥]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន ហើយសូមឲ្យមន្ត្រីតុលាការជួយសាក្សីរបស់យើងរកមើលផ្នែកជាភាសាខ្មែរដែលចាប់ផ្ដើមពី ERN 00294800, ភាសាអង់គ្លេស ERN គឺ 00323324, ហើយជាភាសាបារាំង 00385195។

បើសិនជាយើងបង្ហាញ អាចបង្ហាញឯកសារនេះនៅលើកុំព្យូទ័រសម្រាប់ឲ្យមើលឃើញ ភាសា -- ERN ជាភាសាខ្មែរគឺលេខ 00294800។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** ខ្ញុំចង់អាននូវសំណួរមួយជូនលោកស្រី ហើយដើម្បីឲ្យអ្នកស្រីជួយធ្វើការបំភ្លឺបន្ថែម ថាតើ

អ្វីដែលលោកស្រីបានយល់នៅពេលនោះ។ "សំណួរ៖ នៅពេលដែលលោកស្រីនៅជាមួយនឹងអ្នកទាំងបីហ្នឹង លោក ខៀវ សំផន, សុន សេន, ហើយនិង ហ៊ូ នឹម តើលោកស្រីបានឃើញសកម្មភាពពួកគាត់ហ្នឹងធ្វើអ្វីខ្លះនៅទីនោះ? ចម្លើយ៖ លោកស្រីឆ្លើយថា ខ្ញុំអត់បានឃើញអ្វីទេ គឺសកម្មភាពរបស់ពួកគាត់ធម្មតា ដើម្បីត្រៀមចូលទៅកាន់កាប់ទីក្រុងភ្នំពេញ"។ ត្រង់កន្លែងនេះ ថាតើនេះគឺជាការសង្ខេបត្រឹមត្រូវទេ ទៅលើចម្លើយរបស់លោកស្រី ដែលទៅមុខចំពោះមុខការិយាល័យចៅក្រមស៊ើបអង្កេតនោះបាទ?

**លោកស្រី ស សៀក៖**

**ឆ៖** ចាស លោក សំណួរនេះលោក សុន សេន អត់បានរួមដំណើរមកទេ។ តែសំណួរនេះ -- ចម្លើយនាងខ្ញុំឆ្លើយត្រឹមត្រូវហើយ។

**ស៖** សូមអរគុណណាស់ចំពោះការបំភ្លឺចំណុចនេះ។ ហើយតើការយល់របស់ខ្ញុំត្រឹមត្រូវទេ ដែលថានេះគឺជាការពិពណ៌នាទៅអ្វីដែលលោកស្រីបានឃើញផ្ទាល់ភ្នែក នៅពេលដែលលោកស្រីដល់អង្គរស្ស ឬក៏ឧដុង្គនោះ?

[១៥:១៥:៤៧]

**ឆ៖** ចាស ត្រឹមត្រូវ។

**ស៖** សូមអរគុណ។ ឥឡូវបើសិនជាយើងមើលលើឯកសារដដែលហ្នឹង ហើយនៅទំព័រដូចគ្នាដែរ សំណួរ -- បីសំណួរក្រោមមកទៀត ហើយ ERN ក៏ដូចគ្នាដែរ គឺនៅទំព័រដូចគ្នាទាំងបីភាសា ដូចដែលខ្ញុំបានជម្រាបជូនតុលាការពីខាងដើមអម្បាញ់មិញនេះ។ ហើយខ្ញុំសូមអានជូនលោកស្រីនៅសំណួរចំនួនពីរ ហើយនិងចម្លើយទៅនឹងសំណួរទាំងពីរនោះរបស់លោកស្រី។ សំណួរគឺ៖ "នៅពេលនោះតើលោកស្រីបានដឹងទេថា អ្នកណាគេជាអ្នកបញ្ជាឲ្យជម្លៀសប្រជាជនចេញ?" ហើយចម្លើយលោកស្រីឆ្លើយថា៖ "ខ្ញុំអត់ដឹងទេ ខ្ញុំគ្រាន់តែដឹងថា អ៊ំៗនិយាយថា មិនទាន់ឲ្យចូលបានទេ ព្រោះប្រជាជនជម្លៀសហ្នឹងខុសទិស"។ ហើយសំណួរបន្តទៀតហ្នឹង ក៏សួរថា៖ "តើអ្នកណាគេជាអ៊ំៗ?" ហើយចម្លើយគឺ៖ "ពួកមេដឹកនាំធំៗបីនាក់ដែលទៅជាមួយនោះ"។ អ៊ីចឹងសំណួររបស់ខ្ញុំ ថាតើនេះគឺជាការសង្ខេបត្រឹមត្រូវនូវចម្លើយរបស់លោកស្រី ឬក៏ការពន្យល់របស់លោកស្រីអំពីការយឺតនៅក្នុងការចូលទីក្រុងភ្នំពេញនៅពេលដែលមកពីខេត្តនោះ?

**ឆ៖** ចាស លោកសំណួរនេះ ខ្ញុំសូមបញ្ជាក់ដែរ។ ខ្ញុំចង់និយាយថា អ៊ំៗហ្នឹង ជាក់ស្តែងនៅជាប់ខាងនាងខ្ញុំហ្នឹង ដូចថាមានលោក ហ៊ូ នឹម។ ចាស ព្រោះគាត់រួមដំណើរនៅក្នុងហ្នឹងចាស។ ហើយមានអ៊ី

ប្រែប្រួលទៅលោក សំណួរខ្ញុំចង់ចាំខ្លួនឯងដែរ។

[១៥:១៧:៥១]

**ស៖** បើសិនបើខ្ញុំអានទំព័រនេះឲ្យបានត្រឹមត្រូវ បើសិនជាខ្ញុំខុស សូមជួយកែខ្ញុំ។ គឺថា "មេដឹកនាំ អ៎! អ៊ំៗទាំងបីនាក់"។ អ៊ីចឹង "អ៊ំៗទាំងបីនាក់" ហ្នឹង គឺថាយើងចង់សំដៅលើ ខៀវ សំផន, សុន សេន ហើយនិងលោក ហ៊ូ នឹម ពីព្រោះលោកស្រីបានលើកឡើងអំពីពួកគាត់ទាំងបីនាក់នេះពីខាងដើម។ អ៊ីចឹងថាតើត្រឹមត្រូវឬទេ ដែលអ្នកទាំងបីនាក់ហ្នឹងជាអ្នកប្រាប់យើងថា កុំទាន់ចូលទីក្រុងភ្នំពេញ?

**ឆ៖** ចាស នៅលើសំណួរនេះពាក្យពេចន៍លោក ខៀវ សំផន គាត់មិនបាននិយាយទេ។ ប៉ុន្តែគ្រាន់ថាអ៊ំៗនៅហ្នឹង គឺមានលោក ហ៊ូ នឹម ហើយនិងលោក ទីវ អុល។ ដោយឡែកលោក សុន សេន គាត់មិនបានរួមដំណើរទេ ដូចខ្ញុំបញ្ជាក់ពីខាងលើអ៊ីចឹង គ្រាន់តែខ្ញុំមកជួបនៅឯស្អាតហើយ។

[១៥:១៨:៤៧]

**ស៖** អ៊ីចឹងពេលដែលលោក -- លោកស្រីនិយាយថា អ្នកទាំងពីរនាក់ --អ៎! អ៊ំៗទាំងពីរនាក់និយាយហ្នឹង ថាតើហ្នឹងគឺជាអ្នកទាំងពីរនាក់ហ្នឹង កាលគាត់និយាយលោកស្រីឮដោយផ្ទាល់ខ្លួនឯងតែម្តង ឬក៏អ្នកស្រីឮពីអ្នកផ្សេងទេក្នុងការប្រាប់ឲ្យៗកុំទាន់ចូលភ្នំពេញហ្នឹង?

**ឆ៖** ចាស ពាក្យនេះខ្ញុំឮតាមរយៈប្រធានខ្ញុំ គាត់បានមកដូចថាស្រែកប្រាប់នៅតាមទ្វារឡាន អ៊ីចឹង ឲ្យសមាជិកទាំងអស់ជ្រាប និងដឹងនូវដំណឹងនេះគ្រប់គ្នា។

**ស៖** សូមអរគុណ។ អ៊ីចឹងលោកស្រីបានលើកឡើងថា លោកស្រីបានឃើញលោក ខៀវ សំផន ប្រសិនជាខ្ញុំស្តាប់បានត្រឹមត្រូវ។ ហើយអ៊ីចឹងថាតើពេលណាជាពេលបន្ទាប់ទៀត ដែលលោកស្រីបានឃើញលោក ខៀវ សំផន ម្តងទៀតបន្ទាប់ពីពេលចុងក្រោយដែលលោកស្រីបានឃើញនោះ?

**ឆ៖** ចាស ចាប់ចូលភ្នំពេញមក ខ្ញុំលែងបានឃើញគាត់ ព្រោះអីមិនដឹងគាត់ទៅនៅកន្លែងណាវិញ។

**ស៖** តើខ្ញុំ -- ការយល់របស់ខ្ញុំត្រឹមត្រូវទេដែលថាលោកស្រីមិនដែលបានឃើញលោក ខៀវ សំផន ទៀតទេ បន្ទាប់ពីលោកស្រីចាកចេញពីឧដុង្គមក ពោលគឺក្រោយថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥នោះបាទ?

**ឆ៖** ចាស ត្រឹមត្រូវ ព្រោះខ្ញុំអត់បានឃើញគាត់ទៀត។ ពេលនុំងខ្ញុំនៅតែក្នុងមន្ទីរខ្លួនឯង។

**ស៖** អរគុណច្រើន។ ឥឡូវប្រសិនបើយើងត្រឡប់ថយក្រោយបន្តិចវិញ ហើយយើងក្រឡេក

មើលទៅលើបញ្ហាមួយចំនួនទាក់ទងទៅនឹងការផ្សព្វផ្សាយវិទ្យុ ផ្សាយសំឡេងវិទ្យុនេះ នៅក្នុងអំឡុងពេលហ្នឹង។ លោកស្រីបានប្រាប់យើងខ្ញុំពីខាងដើមថា មានការផ្សាយវិទ្យុមួយចំនួន គឺធ្វើឡើងដើម្បីគាំទ្រទៅដល់សមរភូមិ ក៏ដូចជាការលើកទឹក ជំរុញទឹកចិត្ត ទៅដល់កងទ័ពនៅក្នុងសមរភូមិមុខ។ អ៊ីចឹងអ្វីដែលខ្ញុំចង់ធ្វើនៅពេលនេះ គឺខ្ញុំចង់អានចេញពីប្រតិចារឹកនៃការផ្សាយសំឡេងតាមវិទ្យុនេះ ហើយដើម្បីឱ្យលោកស្រីអាចមើលថា តើលោកស្រីអាចនៅចាំឬទេ អំពីខ្លឹមសារនៃការផ្សាយដែលត្រូវបានធ្វើឡើងនៅក្នុងអំឡុងពេលនោះ?

[១៥:២២:១៨]

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ហើយអស់លោក លោកស្រីចៅក្រម ឯកសារនេះគឺ E3/118។ នេះគឺជាឯកសាររបស់ផ្សាយព័ត៌មានរបស់ហ្វីប៊ីស ដែលគេបានស្រង់នូវប្រតិចារឹករបស់ខ្លួនចេញនៅថ្ងៃទី០១ ខែមេសា ឆ្នាំ១៩៧៥។ យើងមានឯកសារជាក្រដាស ដើម្បីបង្ហាញជូនសាក្សី។ ខ្ញុំគិតថា សាក្សីនេះប្រហែលជាមិនបានឃើញឯកសារដើមនេះពីមុនមកទេ ពីព្រោះឯកសារនេះត្រូវបានគេផលិតឡើងនៅក្រៅប្រទេសកម្ពុជា។ ប៉ុន្តែបើសិនជាលោកប្រធានអនុញ្ញាត ខ្ញុំនឹងអាចបង្ហាញឯកសារនេះទៅដល់សាក្សីនេះ មុនពេលខ្ញុំនឹងដាក់សំណួរមួយចំនួនជូនគាត់។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីមេធាវី!

[១៥:២៣:០៩]

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគ្រាន់តែចង់រំឭកអំពីវិធីសាស្ត្រដែលបានប្រើប្រាស់ដោយអង្គជំនុំជម្រះ គឺថាជាដំបូងយើងត្រូវបង្ហាញឯកសារជាមុនសិនទៅដល់សាក្សី ដើម្បីសួរគាត់ថាតើគាត់ស្គាល់ឯកសារដែរឬទេ? ប្រសិនបើគាត់មិនស្គាល់ទេ យើងត្រូវដកឯកសារវិញ យើងមិនត្រូវមកដកស្រង់ទាំងស្រុងឱ្យគាត់ស្តាប់នៃខ្លឹមសារឯកសារបែបនេះទេ។ ដូច -- នេះគឺជាសេចក្តីសម្រេចរបស់អង្គជំនុំជម្រះកាលពីព្រឹកមិញនៅពេលដែលមេធាវីការពារក្តី នួន ជា បានសួរនោះ អង្គជំនុំជម្រះសម្រេចបែបនេះ។ ដូច្នេះសូមឱ្យអនុវត្តការសម្រេចបែបនេះចំពោះសហព្រះរាជអាជ្ញាផងដែរ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញលោកមេធាវីអន្តរជាតិការពារក្ដីលោក នួន ជា!

[១៥:២៤:០៦]

**លោក ហ្សាស្តេ ប៉ោ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគ្រាន់តែចង់បន្ថែមដែលសហសេវិករបស់ខ្ញុំ សហភាតារបស់ខ្ញុំ បានលើកឡើង។ គឺថាការបំផុត យើងត្រូវសួរសាក្សីនេះ ថាតើគាត់ធ្លាប់បានឃើញឯកសារហ្នឹងអត់? ហើយបើសិនជាចម្លើយថាអត់ទេ អ៊ីចឹងគឺយើងនឹងអនុវត្តនូវសេចក្ដីសម្រេចដែលអង្គជំនុំជម្រះកាលពីមុនមកចំពោះបញ្ហាដូចគ្នានេះ គឺបានន័យថាព្រះរាជអាជ្ញាគាត់មិនអាចដកស្រង់ ដំណកស្រង់ចេញពីឯកសារនេះទេ ប៉ុន្តែគាត់អាចសួរសំណួរនេះ។ ដូច្នេះហើយ ខ្ញុំសង្ឃឹមថាយើងនឹងអាចអនុវត្តបានទៅតាមសេចក្ដីសម្រេចនេះ បើសិនជាសេចក្ដីសម្រេចនេះយកមកអនុវត្តចំពោះយើងខ្ញុំជាមេធាវី ក៏ត្រូវតែអនុវត្តចំពោះភាគីផ្សេងទៀតដែរ។ សូមអរគុណ។

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ខ្ញុំគិតថាលោកសហភាតារបស់យើងនៅខាងណោះ គឺគាត់បកស្រាយខុសទៅលើគោលបំណងរបស់ខ្ញុំ។ នេះគឺជាឯកសារដែលកើតឡើងនៅក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ។ ហើយខ្លឹមសារនៃឯកសារនេះ គឺមានជាប្រតិចារឹកនៃការផ្សាយវិទ្យុនេះ។ ខ្ញុំមិនអាចបង្ហាញនូវសំឡេងវិទ្យុសំឡេងនោះទេទៅដល់លោកស្រី ដែលជាសាក្សីនេះ។ យើងគ្រាន់តែចង់អាននូវខ្លឹមសារហ្នឹងខ្លះ ជូនទៅលោកស្រីហ្នឹង ដើម្បីឲ្យគាត់មើល ថាតើគាត់អាចនៅចាំបានឬអត់ ហើយបើសិនគាត់មិនអាចចាំបានទេ យើងអាចសួរសំណួរមួយចំនួន ព្រោះយើងគិតថា នេះជាចំណុចសំខាន់ដែលយើងអាចសួរឲ្យគាត់ដើម្បីស្វះស្វែងរកការពិត។ ជាពិសេស គឺយើងគ្រាន់តែចង់ដឹងថាតើគាត់ អាចស្គាល់ ធ្លាប់នៅចាំការផ្សាយសំឡេង ហើយនិងព័ត៌មានអស់នេះបានឬអត់។ ដូច្នេះ យើងគ្រាន់តែចង់ធ្វើយ៉ាងម៉េចឲ្យគាត់ធ្វើការបំភ្លឺ ឬក៏បញ្ជាក់ចំណុចតែប៉ុណ្ណោះ។ ហើយនេះគឺជាមូលដ្ឋាន សម្រាប់ការលើកនៃឯកសាររបស់យើង ហើយខ្ញុំក៏គាំទ្រដែរ ថាឲ្យភាគីទាំងអស់ត្រូវតែគោរពទៅតាម រាល់សេចក្ដីសម្រេចទាំងអស់ របស់អង្គជំនុំជម្រះបានដាក់ចេញកន្លងមកនេះ។

[១៥:២៥:៥៤]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:២៩:៣៨]

**ប្រធានអង្គជំនុំ៖**

បាទករណីនេះ ដែលឯកសារតំណាងសហព្រះរាជអាជ្ញា មានបំណងដាក់ដេញដោលចំពោះសាក្សីនាពេលនេះ គឺមានលក្ខណៈប្លែកពីឯកសារដទៃទៀត ដោយសារឯកសារនេះគឺជាការចម្លងចេញពីសំឡេងផ្សាយវិទ្យុនៅក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ ដែលមានការពាក់ព័ន្ធ ហើយម្យ៉ាងទៀតតំណាងសហព្រះរាជអាជ្ញាបានបញ្ជាក់ច្បាស់លាស់ថា ទំនងជាសាក្សីមិនដែលបានស្គាល់ឯកសារនេះទេ។ ដូច្នេះ អង្គជំនុំជម្រះសម្រេចថា ទី១ គឺមិនចាំបាច់ប្រគល់ឯកសារនេះឲ្យដល់សាក្សីពិនិត្យនោះទេ ហើយក៏មិនបាច់ដាក់បង្ហាញនៅលើអេក្រង់កុំព្យូទ័រដែរ។ តែអង្គជំនុំជម្រះអនុញ្ញាតឲ្យតំណាងសហព្រះរាជអាជ្ញា ប្រើប្រាស់ឯកសារនេះក្នុងការដេញដោលសាក្សី។

សូមអញ្ជើញលោកមេធាវី! យើងបានសម្រេចរួចហើយ លោកមានបញ្ហាអីផ្សេងទេ? ព្រោះបញ្ហាដដែល លោកអាចសម្រេច លោកអាចជំទាស់តែម្តងបាន អត់អាចជំទាស់ពីរដងបានទេ។ លើកលែងតែលោកមានបញ្ហាផ្សេង នោះអង្គជំនុំជម្រះនឹងអនុញ្ញាតឲ្យលោកធ្វើការដូច្នេះ។

[១៥:៣១:១៣]

**លោក គង់ សំអុន៖**

សូមឲ្យលោកប្រធានបញ្ជាក់បន្ថែម ខ្ញុំអត់មានជំទាស់លោកប្រធានទេ ប៉ុន្តែបញ្ជាក់បន្ថែមថា តើការប្រើប្រាស់ ដែលលោកប្រធានមានប្រសាសន៍នេះ ក្នុងកម្រិតណា? ការប្រើប្រាស់បែបម៉េច ដែលសហព្រះរាជអាជ្ញាអាចប្រើបាន សូមលោកប្រធានជួយបញ្ជាក់បាទ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ ដោយសារនេះ ជាប្រតិចារឹក ដែលចេញពីអាត់សំឡេង។ ដូច្នេះការដកស្រង់ ការអាននូវខ្លឹមសារទាំងស្រុង ឬក៏ផ្នែកណាមួយ ដើម្បីរំឭកការចងចាំរបស់សាក្សី គឺអាចធ្វើទៅបាន។

សូមអញ្ជើញតំណាង -- អ៎! លោក ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំចង់បញ្ជាក់ឲ្យច្បាស់ ចំពោះភាគីទាំងអស់ ហើយនិងសាធារណជន។ ប្រសិនបើខ្ញុំមិនច្រឡំទេ ឯកសារដែលសហព្រះរាជអាជ្ញាចង់យោងយកមកប្រើនេះ គឺជាឯកសារដែលបានដាក់ទៅក្នុងសំណុំរឿងហើយ ដែលបានជជែកដេញដោលហើយ។ ឯកសារនេះ គឺថាមានលេខ

E3 រួចទៅហើយ។ បើសិនជាខុសអាចសហព្រះរាជអាជ្ញាកែបាន គឺថាមានលេខ E3/118។ ឯកសារនេះបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ។ ដូច្នេះ ឯកសារនេះ អាចប្រើប្រាស់បានជាមូលដ្ឋានសម្រាប់តាំងសំណួរ។ ទោះជាយ៉ាងណាក៏ដោយ គឺថាយើងមានលក្ខណៈទូទៅមួយថា ធ្វើម៉េចឲ្យមាន -- យកឯកសារនោះមកប្រើសម្រាប់ភាពពាក់ព័ន្ធសំណុំរឿងរបស់យើង។

[១៥:៣២:៥៩]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** ខ្ញុំលើកឡើងសង្ខេបទេ។ គោលបំណងរបស់ខ្ញុំនោះគឺគ្រាន់តែចង់ដឹងថា តើសាក្សីហ្នឹងគាត់អាចចាំខ្លឹមសារនៅក្នុងប្រតិចារឹកនេះដែរ ឬក៏អត់ប៉ុណ្ណោះ? ដើម្បីវាជាប្រតិចារឹក គឺឯកសារ E3/118 ERN ជាភាសាខ្មែរ 00700267, ហើយជាភាសាបារាំង 00700256, ហើយនិង ERN ជាភាសាអង់គ្លេស 00166897។ ខ្ញុំគ្រាន់តែចង់បង្ហាញប្រតិចារឹកហ្នឹង គឺដែលនិយាយអំពីថ្ងៃដប់ប្រាំ -- និយាយពី ០១ ខែមេសា ឆ្នាំ៧៥ សេចក្តីថ្លែងការណ៍របស់លោក ខៀវ សំផន ចេញផ្សាយសេចក្តីថ្លែងការណ៍ស្តីអំពីស្ថានភាពបច្ចុប្បន្ន។ នេះគឺជាវិទ្យុសំឡេងរណសិរ្សរួបរួមជាតិកម្ពុជានៅទីក្រុងភ្នំពេញ។ ហើយផ្សាយជាភាសាខ្មែរ ប្រតិចារឹកនេះគឺបានបង្ហាញ គឺជាសេចក្តីថ្លែងការណ៍របស់រាជរដ្ឋាភិបាលៗបង្រួបបង្រួមជាតិកម្ពុជា ដែលថ្លែងដោយលោក ខៀវ សំផន។

[១៥:៣៤:៤៧]

ខ្ញុំនឹងអានតែពីរកថាខណ្ឌទេ ដើម្បីជួយរំឭកថា តើសាក្សី គាត់អាចនឹងចាំ ថាតើនេះ គឺជាប្រភេទនៃសេចក្តីថ្លែងការណ៍ដែលបានផ្សាយនោះដែរ ឬក៏អត់? ខ្ញុំសូមចាប់ពីកថាខណ្ឌទី១ តែម្តង។ "រណសិរ្សរួបរួមជាតិកម្ពុជា ដែលមានសម្តេចព្រះ នរោត្តម សីហនុ ជាប្រធាន និងរាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា ដែលមានសម្តេច ប៉ែន នុត ជានាយករដ្ឋមន្ត្រី និងលោក ខៀវ សំផន ជាឧបនាយករដ្ឋមន្ត្រី។ នៅក្នុងសមត្ថភាពជាអង្គការចាត់តាំងមួយស្របច្បាប់ គឺថាមានការផ្សព្វផ្សាយអំពីការបង្រួបបង្រួមជាតិកម្ពុជា ថានឹងធ្វើការត្រួតត្រាទៅលើប្រទេសកម្ពុជាទាំងមូល រួមទាំងទីក្រុងភ្នំពេញផងដែរ។ ហើយសារទី២នោះ រណសិរ្សរួបរួមជាតិកម្ពុជា រាជរដ្ឋាភិបាលបង្រួបបង្រួមជាតិកម្ពុជា និងកងទ័ពរំដោះជាតិកម្ពុជា សូមអំពាវនាវទៅដល់ក្រុមប្រដាប់អាវុធទាំងអស់ ប្រជាជនទាំងអស់ និងក្រុមបនក្បត់ទាំងអស់

រួមទាំងអ្នករស់នៅភ្នំពេញ និងនៅតាមបណ្តាខេត្តផ្សេងៗផងដែរ សូមឲ្យដាក់អាវុធចុះជាបន្ទាន់ និងចូលរួមជាមួយរណសិរ្សរួបរួមជាតិកម្ពុជាភ្លាមៗតែម្តង។ ហើយអ្នកដែលមានឋានន្តរសក្តិទាំងអស់ គឺរួមទាំងជនមហាក្បត់ទាំងប្រាំពីរនាក់មកចូលរួមជាមួយរណសិរ្សរួបរួមជាតិកម្ពុជា"។

[១៥:៣៦:៥៤]

អ៊ីចឹងការកត់ត្រានៃការផ្សាយសំឡេងនេះ តើលោកស្រីសាក្សីមានដែលឮសូរការផ្សាយសារបែបនេះ ឬក៏សារដែលមានន័យស្រដៀងៗនេះដែរទេ?

**ឆ៖** ចាស លោក នៅក្នុងសំណួរនេះ នាងខ្ញុំសូមឆ្លើយថា បដិសេធទៅចុះ។ ដូចថានាងខ្ញុំនៅក្មេងដែរ ហើយគិតតែពីការងារខ្លួនឯង មិនបានចងចាំ ហើយក៏មិនបានស្តាប់អីដែរ ចាស។

**ស៖** តើលោកស្រីនៅចាំបានទេ ថាតើមានសេចក្តីថ្លែងការណ៍ផ្សេងណាទៀតដែលនិយាយអំពីស្ថានភាពនៅសមរភូមិមុខ និងការអំពាវនាវឲ្យទាហានរបស់ លន់ នល់ គឺថាចុះចាញ់ សុំឲ្យលើកដៃចុះចាញ់។ លោកស្រីមានបានឮសូរសារបែបនេះទេ?

**ឆ៖** អត់ទាល់តែសោះលោក។ អត់បានឮ។

[១៥:៣៨:៣០]

**ស៖** លោកស្រីនៅចាំទេ ថាតើកម្មវិធីផ្សាយ វិទ្យុផ្សាយសំឡេងនេះមានសារដែលត្រូវអានដោយមេដឹកនាំជាន់ខ្ពស់នោះដែរឬទេ?

**ឆ៖** ចាស ទាំងបីសំណួរនេះ នាងខ្ញុំអត់បានដឹង។ អត់ មិនបានតាមដាន មិនបានយកចិត្តទុកដាក់។

**ស៖** *(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ដំណើរការ!

សូមអញ្ជើញលោកមេធាវី!

**លោក ហ្សាស្តេី ប៉ោ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមអធ្យាស្រ័យចំពោះសហព្រះរាជអាជ្ញា ដែលខ្ញុំរំខាននៅពេលចោទតាំងសំណួរនេះ។ ប៉ុន្តែខ្ញុំគិតថាត្រូវដោះស្រាយបញ្ហានេះ មុននឹងចាប់ផ្តើមជាមួយនឹងឯកសារដទៃៗទៀតទាក់ទង ថាតើឯកសារមួយណាអាចដកស្រង់សម្តីយកមកប្រើបាន? នេះគឺជាសេចក្តីបញ្ជាក់

របស់លោកចៅក្រម ឡាវ៉ែន៍។ ខ្ញុំពេញចិត្តណាស់ចំពោះសេចក្តីបញ្ជាក់របស់លោកចៅក្រម។ ប៉ុន្តែនៅតែមានចំណុចមួយចំនួនមិនច្បាស់ ខ្ញុំ -- តាមខ្ញុំយល់នោះគឺថា គឺលោកចៅក្រម ឡាវ៉ែន៍ គាត់ថាសំណួរណាដែលត្រូវយកមកពិចារណាថាតើឯកសារណាអាចត្រូវស្រង់សម្តីមកបាន? ឯកសារណាមិនបាន?

ដូច្នេះខ្ញុំសួរថាតើ -- សូមសួរចំពោះមុខអង្គជំនុំជម្រះ តើឯកសារណាត្រូវមុខជំនុំជម្រះសិន ឬក៏យ៉ាងម៉េច? ដូច្នេះឯងបានជាខ្ញុំសូមការបញ្ជាក់ ថាតើសេចក្តីសម្រេចនេះត្រូវអនុវត្តជាមួយនឹងឯកសារមុនៗ ដែលយើងខ្ញុំបានប្រើប្រាស់ដោយរបៀបណា? ជាពិសេសទាក់ទងទៅនឹងឯកសារ E3/1435 ខ្ញុំដឹងថាខ្ញុំមិនអាចដកស្រង់សម្តីចេញពីឯកសារនេះបានទេ មុននឹងខ្ញុំរៀបចំជាសំណួរផ្សេងៗ។

[១៥:៤០:៤៧]

ដូច្នេះ ចំណុចនេះ គឺថាសម្រាប់ឲ្យភាគី -- ដើម្បីប្រយោជន៍ភាគីទាំងអស់នោះ គឺមានសារប្រយោជន៍ គឺត្រូវមានសេចក្តីសម្រេចពិតប្រាកដតែម្តង ច្បាស់ៗតែម្តង ថាតើឯកសារណាអាចស្រង់សម្តីបាន។

ដូច្នេះយើងខ្ញុំយល់ស្របជាមួយនឹងសហព្រះរាជអាជ្ញាទាំងស្រុងថា យើងត្រូវតែរកវិធីណាមួយដើម្បីដោះស្រាយនូវបញ្ហានោះ ថាហេតុអ្វីបានជាឯកសារណាមិនអាចដកស្រង់សម្តីបាននោះ បើសិនណាជាឯកសារនោះគឺថាភាគីទាំងអស់មិនមាននោះ។ ដូច្នេះ យើងខ្ញុំសូមឲ្យបញ្ជាក់ចំណុចនេះមុននឹងចាប់ផ្តើមបន្តទៅទៀត។

**លោក អាប់ឌុលឡាក់ ថារីក៖**

ខ្ញុំសូមឆ្លើយតបទៅសង្ខេបទេ។ ខ្ញុំបានយោងទៅនឹងឯកសារដែលយើងខ្ញុំបានដាក់នៅក្នុងខែឧសភា ឆ្នាំ២០១២។ ឯកសារ E201 ដែលយើងខ្ញុំ -- ដែលឯកសារនេះសង្ខេបអំពីបញ្ហាផ្លូវច្បាប់ បញ្ហាជាក់ស្តែងតែម្តងដែលសម្រាប់ការប្រើប្រាស់ឯកសារ ដែលយើងខ្ញុំបានដាក់ដែលថាវាសមស្របណាស់។

[១៥:៤២:១១]

យើងខ្ញុំបានសង្ខេបនូវបីកថាខណ្ឌនៅក្នុងឯកសារនោះ គឺឯកសារ E201 ហើយនៅកថាខណ្ឌទី៣នេះ គឺថាឯកសារអាចបង្ហាញទៅសាក្សីដើម្បីឲ្យវា -- យល់ថាវាស៊ីសង្វាក់គ្នាទៅនឹងខ្លឹមសារនៅក្នុងឯកសារដោយយោងទៅលើការដឹងឮ យល់ដឹងផ្ទាល់របស់សាក្សី។ ឯកសារ E201/2 គឺជាអនុស្សរណៈរបស់អង្គជំនុំជម្រះនៅថ្ងៃ៣០ ឧសភា ឆ្នាំ២០១២ ដែលយើង -- ដែលអង្គជំនុំជម្រះបានសម្រេចថា គឺឯកសារនេះគ្រាន់តែបង្ហាញអំពីបញ្ហាគតិយុត្តតែប៉ុណ្ណោះ។ នេះគឺជា -- ខ្ញុំសូមសង្ខេបអំពីជំហរផ្នែកខាង

គតិយុត្តដែលយើងខ្ញុំបានដាក់ជូនអង្គជំនុំជម្រះ។

ដើម្បីបន្តជាមួយនឹងការតាំងសំណួរទៅលើសាក្សីនេះ គឺថា មានការឃើតបន្តិចហើយ ខ្ញុំសួរថាតើបើសិនណាត្រូវពិភាក្សា ចំណុចគួរណាស់តែពិភាក្សានៅក្នុងកិច្ចប្រជុំរៀបចំចាត់ចែងសវនាការទៅវិញទើបជាការប្រសើរ។

[១៥:៤៣:៣៣]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:៤៦:២៩]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយសូមជម្រាបលោកមេធាវី ហ្សាស្តី ប៉ៅ ថាចំពោះការកត់សម្គាល់របស់លោក និងសំណើររបស់លោកអម្បាញ់មិញនេះ ពាក់ព័ន្ធនឹងការសួរដេញដោលឯកសារ ហើយប្រភេទឯកសារបែបណា ហើយដើម្បីក្នុងការអាចដេញដោលដោយដកស្រង់បាន ឬក៏មិនបាននោះ អង្គជំនុំជម្រះនឹងសម្រេចលើបញ្ហា ដែលលោកលើកឡើងនេះនៅថ្ងៃ -- ព្រលឹមឡើង ថ្ងៃស្អែក។ ហើយដើម្បីកុំឲ្យខាតពេល អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីធ្វើការតាំងសំណួរពីព្រោះពេលវេលា ដូចជាបាត់បង់ច្រើននៅក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ ហើយចំពោះបញ្ហាផ្សេងទៀត យើងនឹងបញ្ជាក់បន្ថែមឲ្យកាន់តែច្បាស់ទៀត ដែលជា អាចបំពេញបន្ថែមនូវរបៀបវារៈមួយទៀត នៅក្នុងកិច្ចពិភាក្សាដែលយើងរៀបចំដំណើរការកិច្ចរៀបចំសវនាការដែលយើងនឹងធ្វើអសាធារណៈ នៅថ្ងៃទី១៧ ខែនេះ បានន័យថាខានស្អែក។

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

[១៥:៤៧:៤៧]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោកស្រី ស សៀក ឥឡូវនេះខ្ញុំចង់ចូលទៅការរៀបរាប់របស់លោកស្រី នូវអ្វីដែលលោកស្រីបានឃើញនៅពេលដែលលោកស្រីមកដល់ទីក្រុងភ្នំពេញ មកស្ពាតអូឡាំពិក។ បើខ្ញុំយល់មិនច្រឡំទេ គឺលោកស្រីមកដល់ស្ពាតអូឡាំពិក បួនថ្ងៃក្រោយ១៧ មេសា ៧៥ អ៊ីចឹងមែនទេ?

**លោកស្រី ស សៀក៖**

**ឆ៖** ចាស បួនថ្ងៃក្រោយ។

[១៥:៤៨:៤០]

**ស៖** នៅពេលលោកស្រីទៅដល់ស្ពាតអូឡាំពិក តើលោកស្រីបានឃើញមេដឹកនាំជាន់ខ្ពស់នៅ -- ណាខ្លះ នៅទីនោះដែរឬទេក្រៅពី សុន សេន?

**ឆ៖** ចាស អត់មានទេ មានតែ សុន សេន គាត់មកទទួលក្មេងៗដែលចុះពីឡានមក។

**ស៖** នៅពេលដែលលោកស្រីបានឃើញគាត់ តើគាត់និយាយអ្វីមកកាន់លោកស្រី?

**ឆ៖** ចាស គ្រាន់តែសួរសុខទុក្ខធម្មតា ធ្វើដំណើរមកតាមផ្លូវយ៉ាងម៉េចយ៉ាងម៉ា ហើយសម្រាក នៅទីណាអី។ សួរសុខទុក្ខធម្មតា។

**ស៖** តើលោកស្រីស្នាក់នៅស្ពាតអូឡាំពិកហ្នឹងប៉ុន្មានថ្ងៃដែរ?

**ឆ៖** ព្រលប់ៗប្រហែលម៉ោងប្រាំហ្នឹង យប់ហ្នឹង អត់ទាន់មកដល់ឃោសនាការទេ សម្រាក នៅបន្ទប់ស្ពាតអូឡាំពិកហ្នឹងមួយយប់ ងងឹតឡើងបានមកទៀត។ សម្រាកមួយយប់លោក សម្រាកមួយ យប់នៅស្ពាត។

**ស៖** នៅពេលហ្នឹងលោកនិយាយ -- លោកស្រីនិយាយថា លោកស្រីឃើញមនុស្សរាប់ពាន់ដើរ នៅតាមផ្លូវ ដែលលោកស្រីធ្វើដំណើរមក។ តើលោកស្រីអាចរៀបរាប់ ហ្វូងមនុស្សបានទេមានបុរសស្ត្រី មានលោកសង្ឃអីដែរ លោកស្រីអាចរៀបរាប់បានទេ?

**ឆ៖** ចាសលោក ខ្ញុំរៀបរាប់បាន គ្រាន់ថា ចំពោះព្រះសង្ឃអីមិនបានឃើញទេ គ្រាន់តែយើង -- នាងខ្ញុំឈរមើល មិនមែនតែឯងទេ ចុះពីឡានមក មើលគ្នាច្រើននាក់ដែរ។ ហើយពីស្ពាតចម្ងាយពីស្ពាត ទៅផ្លូវវាឆ្ងាយដែរ គ្រាន់តែឃើញបងប្អូនខ្លះរុញរ៉ឺម៉ក ខ្លះជិះក្នុងឡាន មានដូនចាស់ៗ អីចឹង។

[១៥:៥១:២៥]

**ស៖** តើអ្នកទាំងនោះគឺថា មានអ្នកណាដើរអមទេ មានកងទ័ពខ្មែរក្រហមណាដើរអមហ្វូង មនុស្ស ដែលធ្វើដំណើរចាកចេញនោះដែរទេ?

**ឆ៖** ដូចមិនឃើញមានកងទ័ពអីដើរអមផង ឃើញមានតែបងប្អូន។ របៀបថា ស្គាល់ទិសដែល ត្រូវទៅហើយអីចឹង នាំគ្នាចេញទៅនេះតាមដំណើរ មើលទៅដូចធម្មតា។

**ស៖** អីចឹងនេះគឺថា ជារឿងធម្មតា ដែលឃើញតែហ្វូងមនុស្សរាប់រយពាន់ ដែលធ្វើដំណើរចាក

ចេញពីទីក្រុង អ៊ីចឹង ឬក៏យ៉ាងណា?

**ឆ៖** ចាស ពិតមែនលោក។

**ស៖** ហេតុអ្វីបានជាលោកស្រីគិតថា នេះវាជារឿងធម្មតា? តាមដែលលោកស្រីយល់ មូលហេតុអីបានជាប្រជាជនទាំងនោះ ចាកចេញពីទីក្រុង?

**ឆ៖** ខ្ញុំមិនយល់ដែរលោក។ ចង់ថា បងប្អូននៅហ្នឹង ហើយឲ្យស្នាក់នៅជាបណ្ដោះអាសន្ននៅតាមភូមិឃុំកំណើតរបស់គាត់វិញសិន ឬមួយក៏យ៉ាងម៉េចទេ តាមការយល់របស់ខ្ញុំ។

**ស៖** លោកស្រីដឹងទេ ថាអ្នកណាជាអ្នកបញ្ជាឲ្យប្រជាជនទាំងនោះ ចាកចេញពីទីក្រុង?

**ឆ៖** ចាស ខ្ញុំអត់ដឹងផង។

**ស៖** ការដែលលោកស្រី ស្នាក់នៅស្ដាតអូឡាំពិករយៈពេលមួយយប់ លោកស្រីបាននិយាយថា លោកស្រីបានទៅកាន់ក្រសួងឃោសនាការ។ នេះគឺ ជាទីតាំងដែលលោកស្រីបានបញ្ជាក់មុននោះថា វានៅជិតវត្តភ្នំអ៊ីចឹងដែរ ឬក៏យ៉ាងណា?

[១៥:៥៤:០៧]

**ឆ៖** ចាស នៅជិតវត្តភ្នំ នៅខាងកើតវ៉ារទេះភ្លើង នៅកន្លែងហ្នឹងមានសាលាមួយធំវែង ពីដើមគេហៅថា សាលា ខ្ញុំមិនចេះហៅដែរ តែគេហៅថា សាលាលីសេដេកាត។ អ៊ីចឹងចេះតែហៅតាមគ្នាអ៊ីចឹងទៅ។

**ស៖** តើនេះគឺជាអគារដែលលោកស្រីស្នាក់ទីនោះរហូតដល់ឆ្នាំ១៩៧៩ ឬក៏យ៉ាងណា?

**ឆ៖** ចាស នៅមន្ទីរហ្នឹង ខ្ញុំនៅដល់ឆ្នាំ៧៧ ចុង៧៧ ហ្នឹងខាងក្រសួងដកនាងខ្ញុំមកនៅមន្ទីររោងពុម្ពវិញ ឈប់នៅកន្លែងសិល្បៈហើយ។

**ស៖** លោកស្រីបានជម្រាបមកសហព្រះរាជអាជ្ញាជាតិដែលនិយាយអំពីអ្នកបច្ចេកទេស អតីតបច្ចេកទេស ដែលធ្វើការនៅស្ថានីយវិទ្យុផ្សាយសំឡេង។ តើជាស្ថានីយវិទ្យុនោះ មានទីតាំងនៅជាមួយនឹងក្រសួងដែរ ឬក៏យ៉ាងណា? ក្រសួងឃោសនាការហ្នឹងដែរ ឬក៏យ៉ាងណា?

**ឆ៖** កន្លែងវិទ្យុហ្នឹង ជារួមទាំងកន្លែងក្រុមសិល្បៈនៅ ហើយក្រុមវិទ្យុហ្នឹងទាំងអស់ គេហៅថាក្រសួងឃោសនាការហ្នឹងតែម្ដង លោក។

[១៥:៥៦:១៥]

**ស៖** តើលោក ហ៊ូ នឹម ស្នាក់នៅទីណាដែរ ក្រោយ១៧ មេសា ឆ្នាំ៧៥ ហ្នឹង ក្រៅពីក្រសួង

ឃោសនាការហ្នឹង តើគាត់ស្នាក់នៅទីណា?

**ឆ៖** ចាស ដំបូងឡើយ គាត់មកកន្លែងឃោសនាការហ្នឹង រយៈ១ថ្ងៃ ២ថ្ងៃ ប៉ុន្តែមិនទាន់មានផ្ទះអីស្អាតបាត ដោយសារពេលនោះ វាបន្ទប់មួយៗ យើងមិនស្គាល់ផ្ទះសម្បែងវិញ នៅមិនទាន់មានអនាម័យលោក។ ដូច្នេះ មិនដឹងគាត់ជាទៅសម្រាកកន្លែងណាទេ។ តែក្រោយមក បានគាត់មកនៅហ្នឹងទាំងកូនប្រពន្ធ។

**ស៖** បើសិនណាជាខ្ញុំអាចនិយាយឲ្យឆាប់ឲ្យងាយយល់អំពីមុខងាររបស់ក្រសួងឃោសនាការហ្នឹង ក្រៅពីស្ថានីយប្រតិបត្តិការដំណើរការរបស់វិទ្យុសំឡេង តើក្រសួងការឃោសនាការនឹងធ្វើអ្វី? តើមានសកម្មភាពអីខ្លះ មុខងារអីខ្លះ ដែលក្រសួងឃោសនាការហ្នឹងត្រូវធ្វើអ្វី?

**ឆ៖** ចាស នៅក្រសួងឃោសនាការមានផ្នែកអានវិទ្យុ អ្នកបច្ចេកទេស កន្លែងទទួលរោងពុម្ពហើយនិងក្រុមសិល្បៈ។

[១៥:៥៨:២៣]

**ស៖** នៅពេលមួយនោះ គឺលោកស្រីនិយាយថា នៅក្នុងឆ្នាំ១៩៧៧ លោកស្រីទៅធ្វើដំណើរទៅស្នាក់នៅរោងពុម្ព។ តើរោងពុម្ពនេះ ជារោងពុម្ព ជាផ្នែកមួយរបស់ក្រសួងឃោសនាការដែរ ឬក៏អត់ទេ?

**ឆ៖** ចាស លោកក្រោយមក ខាងខ្ញុំគេឲ្យទៅធ្វើសៀវភៅនៅមន្ទីររោងពុម្ពហ្នឹង។ ពីព្រោះអីចេះរ៉ាយរាប់បន្តិចចុះ ព្រោះអី ក្រោយពីគេដកនាងខ្ញុំទៅធ្វើសៀវភៅនៅមន្ទីររោងពុម្ព ក្រសួងឃោសនាការហើយនិងមន្ទីររោងពុម្ពនេះ គេរំលាយចូលគ្នា ក្រសួង មន្ទីររោងពុម្ព ហើយនិងក្រសួងឃោសនាការប្រើពាក្យថា "ក្រសួងឃោសនាអប់រំ" វិញ ពីរផ្នែកហ្នឹង បូកគ្នាតែមួយ។

[១៥:៥៩:៣១]

**ស៖** សូមអរគុណ។ នៅពេលដែលក្រសួងទាំងពីរច្របាច់បញ្ចូលគ្នា តើអ្នកណាជារដ្ឋមន្ត្រីនៃក្រសួងដែលបានច្របាច់បញ្ចូលគ្នាទាំងពីរហ្នឹង?

**ឆ៖** ពេលហ្នឹង អ្នកទទួលខុសត្រូវមានអ្នកស្រី យុន យ៉ាត ហើយអ្នកចូលទៅទទួលខុសត្រូវជំនួសលោក ហ៊ូ នឹម មានឈ្មោះ ឆយ ទៅកន្លែងឃោសនាការ។

**ស៖** លោកស្រីស្គាល់ឈ្មោះពេញរបស់ ឆយ ហ្នឹងទេ? នាមត្រកូលនាមខ្លួនគាត់ឲ្យពេញតែម្តងទេ?

**ឆ៖** ចាស លោក!

**សៈ** សំណួរខ្ញុំសួរថា តើលោកស្រីស្គាល់នាមត្រកូន នាមខ្លួនរបស់ ឆយ ហ្នឹងទេ ឲ្យពេញតែម្តង ឈ្មោះពេញតែម្តង?

**ឆៈ** អត់ស្គាល់ទេ ស្គាល់តែឈ្មោះ ឆយ ឈ្មោះពូ ឆយៗ។

[១៦:០១:០០]

**សៈ** លោកស្រីនិយាយថា គេបញ្ជូនលោកស្រីទៅឲ្យធ្វើការ ទៅរៀបចំសៀវភៅមួយ លោកស្រីអាចប្រាប់បានទេ សៀវភៅនោះជាសៀវភៅអ្វី?

**ឆៈ** ចាសទៅធ្វើសៀវភៅនេះ ទៅបត់ជាក្រដាស ហើយផ្ទៀងទំព័រ ឬមួយក៏រៀនចាប់ជាអក្សរ១ពុម្ព សៀវភៅទស្សនាវដ្តីរូបភាព។

**សៈ** លោកស្រីស្គាល់ឈ្មោះសៀវភៅហ្នឹងទេ? សៀវភៅហ្នឹងមានចំណងជើងថាម៉េចដែរ?

**ឆៈ** ភ្លេចអស់ហើយ យូរឆ្នាំពេក។

**សៈ** ចុះខ្លឹមសាររបស់សៀវភៅហ្នឹង គេនិយាយពីអី? គេនិយាយពីសៀវភៅសម្រាប់ប្រើប្រាស់នៅសាលារៀន ឬក៏សម្រាប់វិទ្យាសាស្ត្រ? តើខ្លឹមសារនៃសៀវភៅហ្នឹងមាននិយាយអំពីអ្វី?

**ឆៈ** ចាស នៅក្នុងរូបភាពហ្នឹង មានដូចថានារីស្រែអំបិលអីអ៊ីចឹង យើងដាក់ចំណងជើង នារីស្រែអំបិល ហើយរូបភាពមានអំបិល មានអីអ៊ីចឹងទៅ។ ហើយដូចថាកន្លែងដែលប្រជាជនកសាងទំនប់អ៊ីចឹងទៅ ដាក់ចំណងជើងថា ទំនប់ អ៊ីចឹង បងប្អូនធ្វើអ៊ីចឹង ខំកសាងអីអ៊ីចឹងទៅលោក។

[១៦:០២:៥៥]

**ប្រធានអង្គជំនុំ៖**

បាទ កិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ដល់ពេលត្រូវសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសសម្រាក -- ប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃព្រហស្បតិ៍ ទី១៦ ខែសីហា ឆ្នាំ២០១២ ដោយចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ ហើយអង្គជំនុំជម្រះសូមជម្រាបថាសវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងបន្តស្តាប់សក្ខីកម្មសាក្សី សួង ស៊ីគឿន ដែលនឹងបន្តតាំងសំណួរដេញដោលដោយក្រុមមេធាវីការពារក្តីលោក អៀង សារី នៅពេលព្រឹក ហើយជាយថាហេតុនៅពេលរសៀល អង្គជំនុំជម្រះអាចនឹងបន្តស្តាប់សក្ខីកម្មសាក្សី ស សៀក ដែលនឹងអាចសួរដេញដោលដោយ -- និងបន្តការតាំងសំណួរដេញដោលដោយតំណាងសហព្រះរាជអាជ្ញា វាអាស្រ័យទៅលើស្ថានភាពសុខភាពរបស់លោក សួង ស៊ីគឿន អាចបន្តផ្តល់សក្ខីកម្មបាន

00837261


ឬមិនបាន។ សូមភាគី និងសាធារណជនជ្រាប។

[១៦:០៣:៤៣]

លោកស្រី ស សៀក ការស្តាប់សក្ខីកម្មរបស់លោក -- លោកស្រីមិនទាន់ចប់នៅឡើយទេ។ សវនាការត្រូវធ្វើបន្តនៅថ្ងៃស្អែកទៀត។ ដូច្នេះអង្គជំនុំជម្រះសូមអញ្ជើញលោកស្រីមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃស្អែកទៀត។ មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនសាក្សីរូបនេះវិលត្រឡប់ទៅកាន់ទីកន្លែងដែលគាត់ស្នាក់នៅវិញ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងរង់ចាំនៅក្នុងបរិវេណនៃ អ.វ.ត.ក នេះនៅព្រឹកថ្ងៃស្អែក។

បង្គាប់ឲ្យអនុរក្សឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងបីរូបទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញ ហើយនិងឲ្យនាំខ្លួនពួកគាត់ត្រឡប់មកកាន់បន្ទប់សវនាការនេះវិញ នៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:០៤នាទី)*